អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jan-2013, 15:14
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៦នាទី**

**សវនាការលើកទី១៥០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក រ៉ូជឺ ហ្វីលីព *(Mr. Roger PHILIPS)*

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោកឃីត រេយ៍ន័រ *(Mr.Keith RAYNOR )*

**ជនជាប់ចោទ៖**

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៅ ជុនធី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធារី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វ៉េង ហ៊ត់ | ខ្មែរ |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការជាបន្តនៅថ្ងៃនេះ ដូចអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនកាលពីម្សិលមិញហើយ គឺជាសវនាការបន្តនូវនីតិវិធីនៃការដាក់បង្ហាញឯកសារគន្លឹះនានា ដែលនឹងពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលអង្គជំនុំជម្រះបានកំណត់នៅក្នុងអនុស្សរណៈរបស់ខ្លួន ឯកសារ E223/3 ត្រង់ចំណុច៤ ដែលនឹងបង្ហាញដោយតំណាងសហព្រះរាជអាជ្ញាជាបន្ត។

លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ដោយមូលហេតុសុខភាព។ ហើយជនជាប់ចោទ នួន ជា និងជនជាប់ចោទ ខៀវ សំផន អវត្តមានដោយមូលហេតុសុខភាព តែជនជាប់ចោទទាំងពីរតាមរយៈឯកសារ E258/2 និងឯកសារ E223/4 បានដាក់នូវលិខិតលះបង់សិទ្ធិមានវត្តមានសម្រាប់សវនាការនៃការដេញដោលលើឯកសារនៅថ្ងៃនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។ បាទជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញនូវឯកសារគន្លឹះនានា ដែលពាក់ព័ន្ធទៅនឹងអង្គហេតុជម្លៀសប្រជាជននៅដំណាក់កាលទី១ និងទីកន្លែងសម្លាប់ទួលពោធិ៍ជ្រៃ។

សូមអញ្ជើញ!

[០៩:០៩:១២]

**លោក ឃីត រេយ៍ន័រ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! ខ្ញុំសូមចាប់ផ្តើមដោយលើកឡើងនូវសំណួរដែលបានលើកឡើងដោយលោកស្រីចៅក្រម ខាតរ៉ាយថ៍ ទាក់ទងទៅនឹងជំហររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងការបង្ហាញឯកសារពាក់ព័ន្ធអំពីសហឧក្រិដ្ឋកម្មរួម និងតួនាទីរបស់ជនជាប់ចោទ។ តួនាទីរបស់សហព្រះរាជអាជ្ញា គឺថាដោយសារពេលវេលាតម្រូវឲ្យយើងខ្ញុំជ្រើសរើសនូវឯកសារដើម្បីយកមកបង្ហាញជាបីភាសានេះ ដូច្នេះតំណាងសហព្រះរាជអាជ្ញាគឺនឹងធ្វើការបង្ហាញនៅថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍នេះ -- ថ្ងៃពុធនិងថ្ងៃព្រហស្បតិ៍ក្រោយ ដើម្បីឲ្យភាគីទាំងអស់មានការរួចរាល់ ហើយ ក.ស.ព ក៏ត្រូវការរៀបចំដើម្បីការសួរនូវសក្ខីកម្ម។ យើងមាន យើងខ្ញុំមានទិដ្ឋភាពពីរ, ទី១ តុលាការអាចនឹងបញ្ចប់ការយកសក្ខីកម្ម TCW--

**អ្នកបកប្រែ៖**

បាទ សូមអធ្យាស្រ័យលោកប្រធាន តាមអត់ទាន់ TCW ទាំងពីរនេះអម្បាញ់មិញនេះ។

[០៩:១០:៣៣]

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញានិយាយឲ្យយឺតជាងនេះបន្តិច ហើយឡើងវិញ ពីព្រោះអំមិញហ្នឹងគឺអ្នកបកប្រែបកប្រែភាសាហ្នឹងមិនទាន់ទេបាទ។ ចាប់ផ្តើមពីសាក្សីដែលលមានរហស្សនាម។

**លោក ឃីត រេយ៍ន័រ៖**

សូមអធ្យាស្រ័យលោកប្រធាន។ រហស្សនាមរបស់សាក្សីនេះគឺ ដែលត្រូវមកផ្តល់សក្ខីកម្ម ប៉ុន្តែយើងៗខ្ញុំប៉ាន់ប្រមាណថា តុលាការអាចនឹងសម្រេចថា នឹងបញ្ចប់ការសួរយកសក្ខីកម្មរបស់សាក្សី TCW-100 ឬក៏អាចសម្រេចនឹងធ្វើការចាប់ផ្តើមសួរយកសក្ខីកម្មសាក្សី TCW-110។ ក.ស.ព ស្ថិតនៅមានជំហរមួយនឹងចាប់ផ្តើមជាមួយនឹងសាក្សីមួយណាក៏បាន ដែលជាការពិតណាស់បើសិនណាត្រូវស្តាប់សក្ខីកម្មសាក្សីនៅថ្ងៃចន្ទ និងថ្ងៃអង្គារ៍សប្តាហ៍ក្រោយនេះ នោះនឹងធ្វើឲ្យតុលាការមានការមមាញឹក ហើយ ក.ស.ព ក៏នឹងត្រូវនិយាយអំពីតួនាទីរបស់ជនជាប់ចោទនៅថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍សប្តាហ៍ក្រោយដែរ។

[០៩:១២:១៣]

ទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួម យើងខ្ញុំសូមស្នើថា នេះគឺជាការបង្ហាញរហូតទៅដល់ពេល

ដែលសួរយកភស្តុតាងឯណោះ។ ដោយសារថាយើងខ្ញុំមានឯកសារត្រូវបង្ហាញជូនទៅសាក្សី ដែលតុលាការមិនទាន់បានកោះហៅនៅឡើយ។ យើងខ្ញុំជៀសវាងមិនឲ្យមានការត្រួតគ្នា មានការជាន់គ្នាទេ។ ដូច្នេះយើងខ្ញុំយល់ឃើញថា ការបង្ហាញសក្ខីកម្មនេះគឺថាមានសារៈសំខាន់ណាស់ទៅដល់ថៅក្រមទាំងអស់ រហូតដល់ការចប់នៃការបង្ហាញភស្តុតាង។

ដូច្នេះនេះយើងខ្ញុំយល់ថា ខ្ញុំនឹងឆ្លើយទៅនឹងសំណួររបស់លោកស្រីថៅក្រមសួរពីម្សិលមិញហើយ។ ដូច្នេះយើងខ្ញុំឥឡូវនេះប្រគល់នាទី ថាក្រែងលោមានបញ្ហាចោទសួរជាសំណួរអីមួយ ហើយខ្ញុំសូមបង្ហាញផ្តល់វេទិកានេះទៅសហការីរបស់ខ្ញុំ លោកតំណាងសហព្រះរាជអាជ្ញាលោក ហ៊ាត់ ដើម្បីបង្ហាញនូវឯកសារ។ សូមអរគុណ។

[០៩:១៣:២៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក វ៉េង ហ៊ាត់៖**

សូមគោរពលោកប្រធាន លោក លោកស្រីនៃអង្គជំនុំជម្រះ។ សួស្តីភាគីទាំងអស់នៃអង្គជំនុំជម្រះ។ សហព្រះរាជអាជ្ញានឹងបង្ហាញជូនអង្គជំនុំជម្រះនូវភស្តុតាងទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំពីដំណាក់កាលទី១ ដែលចាប់ផ្តើមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងដំណាក់កាលទី២ នៃការជម្លៀសប្រជាជនដោយបង្ខំ ដែលចាប់ផ្តើមនៅចុងឆ្នាំ១៩៧៥។

នៅក្នុងការបង្ហាញនេះ យើងនឹងបង្ហាញដល់អង្គជំនុំជម្រះនូវឯកសារដែលមាននៅក្នុងសំណុំរឿង និងបង្ហាញពីព្រឹត្តិការណ៍នានាដែលជាប់ទាក់ទង។ យើងខ្ញុំក៏បានជ្រើសរើសឯកសារវីដេអូ រូបថតនានាដើម្បីបង្ហាញជូនអង្គសវនាការផងដែរ។ ប្រធានបទដែលយើងខ្ញុំត្រូវបង្ហាញនេះ មានដូចតទៅ៖

[០៩:១៤:៥៦]

ទី១ អំឡុងពេលភ្លាមៗ មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ និងស្ថានការណ៍នៅទីក្រុងភ្នំពេញ។

ទី២ ការវាយប្រហារទៅលើទីក្រុងភ្នំពេញពីសំណាក់កងទ័ពខ្មែរក្រហម។

ទី៣ ខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

ទី៤ ការជម្លៀស ការរំដោះប្រជាជនពីទីក្រុង។

ទី៥ ការជម្លៀសប្រជាជនទៅកាន់សហករណ៍នានានៅទីជនបទ។

ទី៦ ការធ្វើអត្តសញ្ញាណកម្ម ការបំបែក ការសម្លាប់អតីតមន្ត្រីរដ្ឋការ ទាហានសាធារណរដ្ឋ និងជាពិសេសព្រឹត្តិការណ៍នៅទីតាំងឧក្រិដ្ឋកម្មទួលពោធិ៍ជ្រៃ។

៧) ការផ្លាស់ទីប្រជាជនដោយបង្ខំលើកទី២ ចំនួនប្រជាជនដែលត្រូវផ្លាស់ទី និងរបៀបនៃការផ្លាស់ទី រួមទាំងផលវិបាកទៅលើប្រជាជន។

[០៩:១៦:២៩]

លោក លោកស្រីចៅក្រមនឹងទទួលបានប្រភេទឯកសារដូចតទៅនេះ៖

ទី១ របាយការណ៍របស់សេវាកម្មផ្សាយព័ត៌មានសម្ងាត់អន្តរជាតិនៃសហរដ្ឋអាមេរិក

ទី២ ឯកសារមកពីបណ្ណសារក្រសួងការបរទេសសហរដ្ឋអាមេរិក

ទី៣ សេចក្តីសង្ខេបដកស្រង់ពីការផ្សាយនានារបស់តំណាងខ្មែរក្រហម

ទី៤ សេចក្តីរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអន្តរជាតិ

ទី៥ សារទូរលេខដែលផ្ញើទៅកាន់ និងផ្ញើចេញពីស្ថានទូតបារាំងនៅក្នុងទីក្រុងភ្នំពេញ

ទី៦ ការបោះពុម្ពផ្សាយនានារបស់បក្សកុម្មុយនីស្តកម្ពុជា ដែលរួមមានកំណត់ហេតុស្តីពីទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍ទៅកាន់ភូមិភាគពាយ័ព្យពីថ្ងៃទី២០ ដល់ថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៧៥ និងរបាយការណ៍របស់ភូមិភាគពាយ័ព្យចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧៧។

នៅក្នុងប្រធានបទបង្ហាញនេះ សហព្រះរាជអាជ្ញាមិនបង្ហាញស៊ីជម្រៅទាក់ទងទៅនឹងភស្តុតាងអំពី៖

ទី១ ប្រវត្តិមនោគមវិជ្ជា សេចក្តីផ្តើម និងការវិវត្តនៃគោលនយោបាយផ្លាស់ទីដោយបង្ខំ និង

ទី២ តួនាទីរបស់ជនជាប់ចោទនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមស្តីពីការជម្លៀសដោយបង្ខំឡើយ។

[០៩:១៨:៣៤]

ដូចចៅក្រម ខាតវ៉ាយថ៍ គាត់បានមានប្រសាសន៍ម្សិលមិញ ហើយអម្បាញ់មិញនេះសហការីរបស់ខ្ញុំក៏បានសុំស្នើអង្គជំនុំជម្រះរួចហើយ។ តទៅនេះសូមលោកប្រធានមេត្តាអនុញ្ញាតឲ្យសហការីខ្ញុំបង្ហាញភស្តុតាង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញបាទ!

**លោក ឃីត រេយ៉ន័រ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបង្ហាញនូវឯកសារដំបូងមួយចំនួនដែលគ្របដណ្តប់ទៅលើអំឡុងពេលនៅចុងខែមេសា និងដើមខែ -- ចុងខែមីនា ដើមខែមេសា ឆ្នាំ១៩៧៥។ ខ្ញុំសូមចាប់ផ្តើមធ្វើការបង្ហាញទៅលើឯកសារ ទៅលើឯកសារ E3/334 ERN ជាភាសាខ្មែរ 0074086 (ស៊ីក), អង់គ្លេស 00413053, និងជាបារាំង 00751935។ ហើយឯកសារជាភាសាខ្មែរនឹងសូមបង្ហាញនៅលើអេក្រង់បន្តិចទៀតនេះ។ បាទ សូមអរគុណ។

[០៩:២០:១៧]

លោកប្រធាន លោក លោកស្រីចៅក្រម នេះគឺជាឯកសារដែលដកស្រង់ចេញពីបណ្ណាល័យនៃសហរដ្ឋ -- បណ្ណសារនៃសហរដ្ឋអាមេរិក។ ជារបាយការណ៍ប្រចាំខែ ដែលរាយការណ៍អំពីស្ថានភាពនៅក្នុងប្រទេសកម្ពុជា។ បាទ ខ្ញុំសូមធ្វើការអានដូចតទៅនេះ "នៅក្នុងប្រទេសដែលយើងត្រូវដឹងអំពីរបាយការណ៍នៃថ្ងៃទី២៤ និង២៥ ខែកុម្ភៈនោះ ខៀវ សំផន បានធ្វើជាអធិបតីភាពនៅក្នុងសន្និបាតស្តីអំពីការរំដោះបូរណភាពដីកដី។ គណៈរដ្ឋមន្ត្រីរបស់ហ្រ្គុងដែលមានតំណាង២២៣នាក់នៃតំណាងរបស់ហ្រ្គុងចូលរួមប្រជុំ រួមទាំងកងទ័ពផងដែរ"។ ពួកគេបានប្រកាស សូមដកស្រង់ "នេះគឺជាការចាំបាច់បំផុតដែលត្រូវប្រហារជីវិតពួកក្បត់ទាំងប្រាំពីរនាក់ មាន លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អិន តាំ, ឡុង បូរ៉េត និងសូស្តែន ហ្វែណង់ដេស។ អ្នកនយោបាយដទៃទៀត និងអ្នកដែលមានឋានន្តរស័ក្តិខ្ពស់ដទៃទៀត អាចនឹងចូលរួមជាមួយរណសិរ្សរួបរួមជាតិ ប្រសិនណាគេឈប់សហការជាមួយពួកក្បត់ទាំងប្រាំពីរនាក់ចាប់ពីពេលនេះតទៅ"។

[០៩:២២:២១]

បាទ បន្ទាប់ទៀត ខ្ញុំសូមចូលឯកសារ E3/3551 ERN ជាភាសាខ្មែរ 00725703, ហើយ ERN ជាភាសាបារាំង 00763934។ យើងខ្ញុំនៅកំពុងតែបង្ហាញចេញឯកសារចេញអំពីក្រសួងការបរទេសសហរដ្ឋអាមេរិកដដែល សម្រាប់ព្រឹត្តិការណ៍ថ្ងៃទី២៨ កុម្ភៈ ៧៥។ នៅក្រោមចំណងជើងដាក់ថា "ឥណ្ឌូចិន" គឺមាននិយាយដូចតទៅនេះ "ជើងយន្តហោះដែលសម្ពោធហើយរបស់សហរដ្ឋអាមេរិកគឺថាត្រូវបានហោះហើរយ៉ាងប្រកបដោយប្រសិទ្ធភាព ឆ្ពោះមកកាន់ទីក្រុងភ្នំពេញដោយមិនមានបញ្ហាអ្វីនោះឡើយ។ ប៉ុន្តែគ្រាប់ផ្លោងរបស់ពួកខ្មាំងបានធ្លាក់នៅជិតព្រលានយន្តហោះ"។ នៅក្នុងឯកសារនេះដដែល គឺនៅទំព័រខ្មែរ 00725704, ជាភាសាបារាំង 00763934 និងអង់គ្លេស 00413033 ដែល

លើកឡើងដូចខាងក្រោយ "នៅពេលដែលប្រជាជនភាគច្រើននៅទីក្រុងភ្នំពេញមានស្បៀងគ្រប់គ្រាន់សម្រាប់បរិភោគ។ ទីភ្នាក់ងារជួយសង្គ្រោះជាច្រើនរាយការណ៍ថា ជនភៀសខ្លួនរាប់ពាន់នាក់កំពុងអត់ឃ្លាន"។

[០៩:២៤:៤១]

សម្រង់បន្ទាប់មកទៀតគឺ E3/334 ERN ជាភាសាខ្មែរ 00740868, បារាំង 00751931, អង់គ្លេស 00413054។ ឯកសារបានសរសេរដូចតទៅនេះ "ឥឡូវនេះ គឺយើងទទួលបានការអនុញ្ញាតដើម្បីឲ្យចែកចាយនូវ -- គឺយើងបានចែកជូនចំនួន២០.០០០តោន ដែលយើងបានផ្ទុកនៅៗវៀតណាមសម្រាប់ការប្រើប្រាស់ជាបន្ទាន់។ នេះគឺជាជំនួយពីទីភ្នាក់ងារស្ម័គ្រចិត្ត និងកាកបាទក្រហម ដែលអាចបង្កើតកម្មវិធីផ្គត់ផ្គង់របស់ខ្លួនបានយ៉ាងច្រើនសម្រាប់ជនភៀសខ្លួន និងប្រជាជនក្រីក្រដែលត្រូវការដទៃទៀត។ អង្ករប្រហែលជា២០តោនក្នុង១ថ្ងៃ គឺថា១៥០តោន ក្នុង១ថ្ងៃ កំពុងត្រូវបានដឹកតាមជើងយន្តហោះ។ នៅថ្ងៃទី២ មីនា អង្ករស្តុកនៅភ្នំពេញមានចំនួនសរុប ៨.៦៩៣តោន ឬស្មើនឹងការផ្គត់ផ្គង់សម្រាប់រយៈពេល១៩ថ្ងៃ តាមអត្រាបែងចែកផ្លូវការនេះ។

[០៩:២៦:២៣]

ខណៈដែលមិនទាន់មានអង្ករមកដល់ភ្នំពេញតាមទន្លេមេគង្គ ឬក៏មកពីការប្រមូលផ្តុំក្នុងស្រុក ការដឹកជញ្ជូនតាមផ្លូវអាកាសពីទីក្រុងសៃហ្គន បានចាប់ផ្តើមនៅថ្ងៃទី២៧ ខែកុម្ភៈ ហើយបានប្រគល់ឲ្យក្នុងចំនួន១៦.០០០ -- ១.៦៩៤តោន សម្រាប់រយៈពេល៤ថ្ងៃដំបូង។ កិច្ចប្រតិបត្តិការកំពុងដំណើរការទៅប្រកបដោយការពេញចិត្ត ដោយមានចំនួនជើងយន្តហោះ កើនឡើងពីប្រាំពីរជើង គឺនៅថ្ងៃ២៨ កុម្ភៈ ទៅដល់ថ្ងៃ១៤ -- ទៅដល់១៤ជើង នៅថ្ងៃទី៣ ខែមីនា"។

បាទ នៅក្នុងឯកសារនេះដដែល គឺនៅទំព័រ ERN ជាភាសាខ្មែរ 00740869, ជាភាសាបារាំង 00751932។ "អង្ករ និងត្រីបានឡើងថ្លៃប្រហែល៧ភាគរយ ក្នុងសប្តាហ៍មុន នាំមុខឲ្យតម្លៃទំនិញទៅប្រហែលជាឡើង១៣ភាគរយ។ ថ្លៃអង្កររបស់សហរដ្ឋអាមេរិកនៅទីផ្សារងងឹតបានឡើង ៥ភាគរយ ហើយនៅបាត់ដំបង ឡើងដល់ ៩ភាគរយ"។ នៅលើ ERN ដដែល ជាភាសាអង់គ្លេស 00413056 "គឺសត្វស្រុកតម្លៃ គឺសត្វស្រុកគឺថានៅតម្លៃដដែល ប៉ុន្តែផលិតផលក្នុងស្រុកឡើងប្រហែលជាកន្លះភាគរយ។ ២-៣សប្តាហ៍ក្រោយមក ពីការបំពេញសកម្មភាពនេះ ខ្មែរក្រហម ពួកកុម្មុយនីស្តខ្មែរក្រហមបានផ្តួចផ្តើមគំនិតម្តងមកទៀត នៅច្រាំងទន្លេប៉ែកខាងទន្លេមេគង្គ ពួកគេបានកាន់កាប់ទីតាំងសំខាន់ៗ

ដូចជា តាជូ និងព្រែកហ្លួង។ បាទ នៅត្រង់ទំព័រដដែល ព្រែកហ្លួង កាន់កាប់ដោយកម្លាំងដែនដីអន្តរាគមន៍ចម្រុះមួយ ហើយត្រូវបានជ្រាបចូលមួយសន្ទប់យកក្រោយពីវាយប្រយុទ្ធយ៉ាងខ្លាំងមួយរយៈ១ថ្ងៃ។ ហើយមានការផ្លោងគ្រាប់ និងមានការបាញ់ប្រហារពីមូលដ្ឋានទ័ពនៅជិតៗនោះ នៅមូលដ្ឋានទ័ពជើងទឹក ដែលស្ថិតនៅខាងកើតនៃរដ្ឋធានី”។

[០៩:២៩:៣៨]

ឯកសារដដែល ERN ជាភាសាខ្មែរ 00740871, ជាភាសាបារាំង 00751933 ហើយនិងអង់គ្លេស 00413057។ “នៅចន្លោះពីថ្ងៃពីថ្ងៃ២៥ កុម្ភៈ ដល់ ០៣ មីនា គ្រាប់ រ៉ុក្កែតចំនួនបួនគ្រាប់បានផ្ទុះនៅក្នុងទីក្រុងភ្នំពេញ”។ បាទខ្ញុំសូមដកស្រង់ឡើងវិញ “នៅចន្លោះពីថ្ងៃទី២៥ កុម្ភៈ ដល់ថ្ងៃទី០៣ មីនា គ្រាប់រ៉ុក្កែតចំនួន ៤៧គ្រាប់បានផ្ទុះនៅក្នុងទីក្រុងភ្នំពេញ សម្លាប់មនុស្សអស់ចំនួន ១៩នាក់ និងរបួសចំនួន ២៩នាក់។ គ្រាប់ផ្លោងចំនួន ១១៩គ្រាប់ទៀតបានធ្លាក់នៅក្នុងតំបន់ពោធិ៍ចិនតុង ប៉ុន្តែមានចំនួនគ្រាប់ផ្លោងចំនួន ពីរបីប៉ុណ្ណោះបានធ្លាក់ដល់ព្រលានយន្តហោះ ដែលធ្វើឲ្យមនុស្សរងរបួសរហូតដល់ ៦១នាក់។ គ្រាប់ផ្លោង ដែលកំពុងផ្លោងច្រើនគឺនៅទីតាំងឈរជើងទាំងពីរមានការកើនឡើងពីរដងប្រៀបធៀបនឹងការផ្លោងលើកមុន”។

ខ្ញុំសូមបង្ហាញទៅឯកសារនេះបន្តទៅទៀត គឺឯកសារដែលខ្ញុំស្នើសុំអានជូនអង្គជំនុំជម្រះចុះថ្ងៃទី០៩ មីនា ជាឯកសារដែលបានមកពីការផ្សព្វផ្សាយរបស់សហរដ្ឋទីភ្នាក់ងារសេវាសហរដ្ឋអាមេរិកដែល មានឈ្មោះកាត់គឺ អេហ្វ.ប៊ី.អាយ.អេស (FBIS) យើងហៅថាហ្វីប៊ីស។ នេះគឺជារបាយការណ៍នៅថ្ងៃទី០៩ មីនា ៧៥ ដែលមាន ចំណងជើងថា “ទីភ្នាក់ងារសារព័ត៌មានបារាំង ដែលរាយការណ៍អំពីការជម្លៀសបុគ្គលិកចេញពីស្ថានទូតជាច្រើន” ហើយឯកសារចុះថ្ងៃទី០៩ មីនា នេះ អានថា “មនុស្ស ១៤នាក់ត្រូវបានសម្លាប់ និង២៣នាក់ទៀត ត្រូវបានរងរបួសនៅក្នុងថ្ងៃនេះ នៅពេលដែលពួកបះបោរខ្មែររ៉ូ បានផ្លោងចូលទីក្រុងភ្នំពេញ និងផ្លោងចូលមកកាន់ព្រលានយន្តហោះពោធិ៍ចិនតុង”។ ឯកសារមួយទៀតគឺ E3/120 ERN ជាភាសាអង់គ្លេស 00166 -- បាទសូមអធ្យាស្រ័យ។

[០៩:៣២:៥០]

ខ្ញុំសូមចាប់ផ្តើមគឺឯកសារ E3/336 ភាសាខ្មែរគឺមានលេខ 00635044 ដល់ 45, ភាសាបារាំងគឺមានលេខ 00599754 ដល់55, និងភាសាអង់គ្លេសគឺមានលេខ 00413126 នេះគឺជារបាយការណ៍របស់ក្រសួងការពារប្រទេស -- ការបរទេសសហរដ្ឋអាមេរិក។ គឺចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៥ គឺ

ក្នុងស្ថានភាពសេដ្ឋកិច្ចគឺថាមានការផ្តល់នូវកម្មវិធីស្បៀងអង្ករសម្រាប់ប្រទេសកម្ពុជា ហើយនៅចំណងជើងគឺនិយាយអំពីផ្នែកនយោបាយ ដែលមានភាសាខ្មែរគឺលេខ 00635045 គឺភាសា បារាំងដដែលមានលេខ ERNដដែល ដូចដែលខ្ញុំបញ្ជាក់ពីខាងមុន។ នៅក្នុងសុន្ទរកថារបស់ប្រធានាធិបតី លន់ នល់ ដែលបានថ្លែងទៅកាន់គណៈប្រតិភូព្រឹទ្ធសភាត្រូវបានរាយការណ៍ឲ្យដឹងថា លោកនឹងចុះចេញពីតំណែងដើម្បីបុព្វហេតុសន្តិភាព ត្រូវបានយល់ថាជាប្រធានបទចម្បងនៃការទាក់ទាញខាងនយោបាយ ហើយនៅខាងក្រោមគឺបានសរសេរថា "លោកនាយករដ្ឋមន្ត្រី ឡុង បូរ៉េត បាននិយាយនៅក្នុងសន្និសីទ កាសែតថា លន់ នល់ រូបលោក និងសមាជិករដ្ឋាភិបាលទាំងអស់បានត្រៀមលក្ខណៈចុះចេញពីមុខតំណែងដើម្បីជួយនាំមកនូវសន្តិភាព"។ នៅក្នុងឯកសារដដែលខ្មែរ ERN មានលេខ 00635049, សម្រាប់ភាសាបារាំងគឺមានលេខ 00599762 និងភាសាអង់គ្លេសគឺមានលេខ 00413132។

[០៩:៣៥:០០]

"សម្តេច សីហនុ ក៏បានប្រទានកិច្ចសម្ភាសន៍ដល់សារព័ត៌មានឡឺម៉ុងដ៍។ ព្រះអង្គបានមានបន្ទូលសំដៅដល់សមាជជាតិរបស់រាជរដ្ឋាភិបាលជាតិកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា ដែលទើបតែបញ្ចប់ទៅថ្មីៗនេះ និងសេចក្តីសម្រេចរបស់សមាជជាតិដែលផ្តល់ការលើកលែងទោសទាំងស្រុងដល់សមាជិកទាំងអស់របស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ លើកលែងតែជនក្បត់ទាំងប្រាំពីរ ដែលត្រូវតែសម្លាប់ឲ្យបាន..." ពីរបីបន្ទាត់នៅខាងក្រោមបានសរសេរថា "សម្តេច សីហនុ បានបដិសេធថា មិនមែនជាអ្នកប៉ះពាល់ទៅនឹងផ្នែកនយោបាយ ផ្នែកការសម្លាប់នោះទេ..." ហើយពីរបីជួរខាងក្រោមទៀតបានសរសេរថា "ចំណុចដែលនិយាយអំពីជនក្បត់ទាំងប្រាំពីរ ដែលត្រូវសម្លាប់ កំពុងតែបានបកស្រាយបញ្ជាក់ជាច្រើនដងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់ខ្មែរកុម្មុយនីស្ត ទង្វើនេះអាចត្រូវបានរៀបចំឡើងដើម្បីបម្រើឲ្យគោលបំណងពីរនៃការអំពាវដល់អ្នកដែលកំពុងតែមានការរារែកក្នុងចិត្តនៅក្នុងប្រទេសកម្ពុជា និងដើម្បីបដិសេធចំពោះការបំផ្លើស ដែលកើនឡើងនៅបរទេស អំពីការកាប់សម្លាប់ដែលអាចកើតមានឡើងបន្ទាប់ពីខ្មែរកុម្មុយនីស្តទទួលបានជ័យជម្នះ"។

[០៩:៣៦:៣៧]

ការដកស្រង់បន្ទាប់គឺមានលេខ ERN 00635050, ភាសាបារាំងគឺមានលេខ 00599763, ហើយនិងភាសាអង់គ្លេសគឺ 00413132 ហើយមានចំណងជើងដែលថា "សេដ្ឋកិច្ច នៅក្រោមកម្មវិធីផ្តល់អង្ករថ្មី ដែលទើបតែត្រូវបានអនុញ្ញាត បានចាប់ផ្តើមដឹកជញ្ជូនអង្ករនៅថ្ងៃទី០៥ ខែមីនា ដោយយន្ត

ហោះទៅរក្សាទុកនៅឃ្លាំង ដែលត្រូវបានកំណត់ជាពិសេស។ ហើយភ្នាក់ងារស្ម័គ្រចិត្តនឹងដឹកចេញដោយផ្ទាល់ បន្ទាប់ពីទទួលបានការអនុញ្ញាតពីក្រសួងជនភៀសខ្លួន។ ការចែកចាយដំបូងនៃកម្មវិធីផ្តល់អង្ករថ្មីត្រូវបានធ្វើឡើងនៅភ្នំពេញ នៅថ្ងៃទី៧ ខែមីនា។ តាមការប៉ាន់ស្មានការផ្គត់ផ្គង់ជនភៀសខ្លួន និងជនស្រេកឃ្លានដទៃទៀត នឹងត្រូវផ្តល់ទៅតាមតម្រូវការដែលមានចំនួន៣.៦០០តោន ក្នុង១ខែ។ នៅថ្ងៃទី១១ ខែមីនា តំណាងទីភ្នាក់ងារជំនួយការទីភ្នាក់ងារអភិវឌ្ឍន៍សហ(ប្រជា)ជាតិសហរដ្ឋអាមេរិក និងភ្នាក់ងារស្ម័គ្រចិត្តដទៃទៀត បានជួបជាមួយរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ដើម្បីរៀបចំផែនការបន្ថែមទៀត សម្រាប់កម្មវិធីផ្តល់អង្ករ"។

ហើយនៅទំព័របន្ទាប់ ខ្ញុំសូមបន្តពីលេខ 501 ទៅដល់ 502 ដែលយើងប្រើប្រាស់លេខERN បន្តភាសាអង់គ្លេសគឺមានលេខ 00413133, និងភាសាបារាំងគឺមានលេខ 00599763។ នេះគឺជាការរៀបរាប់សង្ខេបមួយទៀត។ "អង្ករស្តុកនៅភ្នំពេញនៅថ្ងៃទី១០ ខែមីនា មាន៨.៤៥៤តោន ត្រូវបានបែងចែកដូចខាងក្រោម៖ អង្ករក្នុងស្តុកអាចផ្គត់ផ្គង់បាន១៥,៥ថ្ងៃ ផ្អែកលើអត្រាបែងចែកប្រចាំថ្ងៃ"។

[០៩:៣៩:០៩]

ហើយនៅក្នុងឯកសារដដែលគឺខ្មែរមានលេខ ERN 00635051, ភាសាបារាំងគឺមានលេខ 00599765, ភាសាអង់គ្លេសគឺមានលេខ 00413134 "ចាប់ពីថ្ងៃ២៧ ខែកុម្ភៈ នៅពេលដែលការដឹកជញ្ជូនស្រូវតាមយន្តហោះពីសៃហ្គនបានចាប់ផ្តើម រហូតដល់ថ្ងៃទី០៩ ខែមីនា ការចែកចាយតាមអាកាសមានចំនួន១២៤ជើង ហើយបានចែកចាយអង្ករចំនួន៤.៩៩៨តោន ក្នុងមួយថ្ងៃ ឬជើងហោះហើរអប្បបរមាប្រចាំថ្ងៃមានចំនួន១១ ស្មើ៤៥៤តោន"។

នៅទំព័រដដែលគឺបិទប្រអប់ក្រហមនៅខាងក្រោមបាននិយាយអំពីធ្យូង។ "លើកលែងតែធ្យូងដែលបានឡើងថ្លៃរហូតដល់១៧ភាគរយ ហើយតម្លៃនេះពុំបានប្រែប្រួលនៅក្នុងទីផ្សារភ្នំពេញទេ កាលពីសប្តាហ៍មុន"។ ទំព័រដដែលជាភាសាខ្មែរ ភាសាបារាំងមានលេខ 00599765, ភាសាអង់គ្លេសគឺមានលេខ 00413135 "សកម្មភាពទីផ្សារ មានភាពអត់ថយបន្តិច ដោយសារតែមានការបាញ់គ្រាប់ផ្លោងដោយអន្ទើសំដៅមកលើចំកណ្តាលនៃទីក្រុង"។ នៅទំព័របន្ទាប់ជាភាសាខ្មែរ និងភាសាបារាំង នៅក្រោមចំណងជើងយោធា គឺជារបាយការណ៍ថ្ងៃ១១ មីនា ឆ្នាំ១៩៧៥ ដដែល "ទីក្រុងភ្នំពេញបានទទួលរងនូវការបាញ់គ្រាប់ផ្លោងក្នុងអំឡុងពេលនៃសប្តាហ៍។ ប៉ុន្តែចំនួនគ្រាប់ដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានពួកខ្មែរកុម្មុយនីស្តបាញ់មកលើវាលយន្តហោះពោធិ៍ចិនតុង"។

[០៩:៤១:២១]

ហើយនិងប្រអប់ក្រហមមួយទៀតនៅក្នុងទំព័រដដែលនេះបាននិយាយថា "ស្ថានភាពរបស់រដ្ឋាភិបាលនៅតាមដកទន្លេមេគង្គក្រោមកាន់តែដុនដាបទៅ។ នៅពេលកងទ័ពនៅមូលដ្ឋានមិត្តភាពចុងក្រោយដែលស្ថិតនៅចន្លោះអ្នកលឿង និងព្រំដែនវៀតណាមខាងត្បូងត្រូវបានជម្លៀសនៅថ្ងៃទី៧ ខែមីនា"។

នៅក្នុងឯកសារដដែលភាសាខ្មែរមានលេខ 00635053, ភាសាបារាំងគឺមានលេខ 00599767, និងភាសាអង់គ្លេសគឺមានលេខ 00413136។ "នៅខាងក្រៅភ្នំពេញមានការប្រែប្រួលតិចតួច។ ទីក្រុងនៅភាគនិរតីនៃខេត្តកំពតកំពុងរងសម្ពាធរបស់សត្រូវជាប្រចាំ។ ហើយចំនួនជនស៊ីវិលដែលបានស្លាប់និងរបួសកំពុងតែកើនឡើងនៅពេលការកាន់កាប់ទីតាំងរបស់ខ្លួនដែលកំពុងតែរួញតូច"។

[០៩:៤២:៤០]

ជាបន្តខ្ញុំសូមលើកឡើងនូវឯកសារថ្មីមួយទៀត គឺ E3/120 ឯកសារនេះមិនមានបកប្រែជាភាសាខ្មែរ ឬភាសាបារាំងទេ។ ភាសាអង់គ្លេសមានលេខ ERN 00166810។ នេះគឺជាការដកស្រង់ចេញពីរបាយការណ៍ ហ្វីប៊ីស ចុះថ្ងៃទី១៣ មីនា ឆ្នាំ១៩៧៥ គឺជាការសម្ភាសតាមវិទ្យុ ហើយចំណងមានដូចតទៅនេះ៖ "វិទ្យុបារាំងបានសម្ភាសជាមួយសម្ដេច សីហនុ អំពីស្ថានភាពកម្ពុជា" នេះគឺជារបាយការណ៍នៅថ្ងៃទី១២ មីនា ឆ្នាំ១៩៧៥ ហើយការដកស្រង់គឺដូចតទៅនេះ៖ "ស្ថានភាពនៅក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះអាក្រក់ឡើងៗជារៀងរាល់ថ្ងៃ។ កងកម្លាំងអាមេរិកដែលបានផ្គត់ផ្គង់តាមផ្លូវអាកាសនូវការផ្គត់ផ្គង់ជាចំណីអាហារ ស្បៀង និងគ្រាប់ត្រូវបានកាត់បន្ថយកាលពីម្សិលមិញ ដោយសារតែសម្ពាធនៃការបាញ់ផ្ដោងរបស់សហរដ្ឋអាមេរិកដែលនៅព័ទ្ធជុំវិញទីក្រុង។ លោក លន់ នល់ ខ្លួនលោកផ្ទាល់បាននិយាយថា ស្ថានភាពប្រទេសស្ថិតក្នុងគ្រោះថ្នាក់។ នៅក្នុងទីក្រុងវ៉ាស៊ីនតោន នាយករដ្ឋមន្ត្រី ហ្វូត ត្រូវបានគេបានកៀបសង្កត់ដល់សភាដើម្បីផ្ដល់នូវការជួយជាបន្ទាន់ដល់ទីក្រុងភ្នំពេញ"។ នៅក្នុងឯកសារដដែលនេះ គឺថាមិនមានការបកប្រែជាភាសាខ្មែរ និងបារាំងទេ។ ដូច្នេះ ខ្ញុំនិយាយតែ ERN ជាភាសាអង់គ្លេស គឺមានលេខ 00166821 នេះជាការសម្ភាសជាមួយតំណាងមកពីរណសិរ្សរួបរួមជាតិកម្ពុជា"។ ហើយបុគ្គលនេះមកពីការិយាល័យនយោបាយ ហើយគាត់ឈ្មោះ ចៅ សេង។ ហើយសំណួរនៃការសម្ភាសហ្នឹងគឺមានដូចតទៅ៖

[០៩:៤៥:១៧]

"សំណួរ៖ លោក ហ្វូត តើខ្ញុំអាចសួរ ថាតើសហ -- តើប្រធានាធិបតីអាមេរិកមានការយល់

ឃើញយ៉ាងម៉េចដែរ? លោក ហ្វូត៖ ហាក់ដូចជាប្រហាក់ឈាមបន្ទាប់ពីការដួលរលំនៃរបបទីក្រុងភ្នំពេញ។ សភាជាតិរបស់លោក ផ្ទុយទៅវិញបានចាត់ទុកថា ជនក្បត់ទាំងប្រាំពីរ --បានកំណត់នូវឈ្មោះជនក្បត់ទាំងប្រាំពីរដែលត្រូវតែកម្ទេច តើមានអ្វីកើតឡើង? ចម្លើយ៖ ការបង្ហូរឈាមគឺកើតឡើងឥឡូវនេះ ចាប់តាំងពីរដ្ឋប្រហារ ឆ្នាំ១៩៧០។ វានឹងបញ្ចប់នៅពេលដែលការអន្តរាគមន៍របស់អាមេរិកត្រូវបានបញ្ចប់។ ក្រៅពីជនក្បត់ទាំងប្រាំពីរដែលរៀបចំនូវរដ្ឋប្រហារ ដែលធ្វើឲ្យកម្ពុជាធ្លាក់ទៅក្នុងសង្គ្រាមនោះ ប្រជាជនកម្ពុជាដទៃទៀត រួមទាំងមន្ត្រី និងអ្នករដ្ឋការស៊ីវិល អាចចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា នៅពេលដែលពួកគេធ្វើការសហការ នៅពេលដែលពួកគាត់ទាំងនោះបញ្ឈប់ការសហការជាមួយនឹងរបប ដែលគ្រប់គ្រងដោយលោក លន់ នល់។ សភាជាតិរបស់យើងបានបញ្ជាក់ឡើងវិញជាថ្មីម្តងទៀតថាយើងនឹងគោរពទៅតាមគោលនយោបាយនៃការរួបរួមជារួមរបស់ប្រទេសជាតិទាំងមូល ហើយនិងប្រជាជនទាំងអស់។ ដោយយើងមិនគិតដល់ថ្នាក់ ដល់វណ្ណៈ នយោបាយ ឬក៏សាសនា ហើយយើងក៏មិនគិតអំពីអតីតកាលរបស់ប្រជាជនដែរ លើកលែងតែជនក្បត់ទាំងប្រាំពីររូបនោះ”។

[០៩:៤៧:៣៣]

នៅក្នុងឯកសារដដែល ដែលមានភាសាអង់គ្លេសមានលេខ 0016830 (ស៊ីក) គឺឯកសារ E3/120។ គឺជារបាយការណ៍ដែលធ្វើនៅថ្ងៃទី១៥ មីនា ឆ្នាំ១៩៧៥ គឺការធ្វើការងារជាមួយផ្នែក -- នៅក្រសួងជនភៀសខ្លួនកម្ពុជា ក្រោមការដឹកនាំរបស់គណៈកម្មការអភិវឌ្ឍន៍ និងការពារជនភៀសខ្លួន ដើម្បីបែងចែកនូវស្រូវអង្ករ និងការប្រើប្រាស់នូវជំនួយពិសេសរបស់សហរដ្ឋអាមេរិក ដែលមានអង្ករចំនួន២០.០០០តោន ដើម្បីធ្វើការបែងចែកទៅដល់ជនភៀសខ្លួន និងប្រជាជនអត់ឃ្លានដោយមិនគិតថ្លៃនៅក្នុងរបបសាធារណរដ្ឋខ្មែរ។

ហើយទំព័របន្ទាប់ពីមានលេខ 0016831 (ស៊ីក) ជាភាសាអង់គ្លេស។ ការបែងចែកស្រូវអង្ករទៅដល់ប្រជាជន និងប្រជាជននៅក្នុងទីក្រុងភ្នំពេញ ព្រមទាំងខេត្តជាច្រើនគឺកើតឡើង -- គឺបង្កើនពី១៥០ក្រាម ទៅ៣០០ក្រាមក្នុង១ថ្ងៃសម្រាប់ប្រជាជនម្នាក់។

[០៩:៤៩:០៨]

ហើយនៅក្នុងឯកសារដដែល សូមបង្ហាញនៅលើភាសា -- នៅលើអេក្រង់ ភាសាខ្មែរមានលេខ 00700233 គឺឯកសារ E3/120, ភាសាអង់គ្លេសមានលេខ 00166826 គឺជាការដកស្រង់ពីរបាយ-ការណ៍ព័ត៌មានហ្វីប៊ីស នៅថ្ងៃទី១៧ មីនា ១៩៧៥។ ចំណងជើងនៃអត្ថបទនេះគឺសរសេរថា “ខៀវ

សំផន បាន -- ខៀវ សំផន ហាក់ដូចជា -- ខៀវ សំផន អំពាវនាវឲ្យមានការតស៊ូប្រយុទ្ធថ្ងៃទី១៥ ខែមីនា"។ នេះគឺការផ្សព្វផ្សាយអំពីវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាពីទីក្រុងភ្នំពេញ "គឺល្ងចលាក់" ជាភាសាខ្មែរទៅកាន់ប្រទេសកម្ពុជា ហើយការផ្សព្វផ្សាយនៅម៉ោងប្រាំពីរ ម៉ោងសាកលថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៥។ ហើយអត្ថបទហ្នឹងបានផ្សព្វផ្សាយដូចតទៅនេះ "ពី -- ចំពោះព្រះសង្ឃ ជនរួមជាតិ និងជនបរទេសនៃទីក្រុងភ្នំពេញ និងនៅតាមទីរួមខេត្តនានាកំពុងស្ថិតក្រោមការគ្រប់គ្រងជាបណ្តោះអាសន្នរបស់ខ្មាំង"។ សេចក្តីអំពាវនាវរបស់ឧបនាយករដ្ឋមន្ត្រី ខៀវ សំផន ហើយខ្ញុំសូមដកស្រង់តែមួយឃ្លាដែលមានភាសាអង់គ្លេសមានលេខ 0066828 (ស៊ីក) ខ្ញុំសូមដកស្រង់ "យើងស្នើសុំឲ្យអស់លោកទាំងអស់ជួយធ្វើការតស៊ូប្រយុទ្ធនឹងជនក្បត់ វាយប្រហារពួកក្បត់ពីខាងក្នុង"។

[០៩:៥១:២៧]

ហើយនៅក្នុងឯកសារដដែល E3/120 ឥឡូវនេះខ្ញុំបន្តទៅ គឺឯកសារ E3/3341 ភាសាអង់គ្លេសមានលេខ 00413194, ភាសាបារាំងមាន 00606713។ នេះគឺជារបាយការណ៍របស់ក្រសួងការពារប្រទេសអាមេរិក ថ្ងៃទី -- ការបរទេសអាមេរិកថ្ងៃទី១៨ មេសា ១៩៧៥។ ទី១ ដែលខ្ញុំចង់អាន -- អត្ថបទទី១ ដែលខ្ញុំចង់អាន គឺមានជាភាសាខ្មែរ និងភាសាបារាំង។ "គឺមានការផ្តល់អង្ករដែលមិនគិតថ្លៃដល់ប្រជាជនដែលធ្វើឲ្យកើនឡើងដល់ ៧០០តោនក្នុង១ថ្ងៃ"។

នៅក្នុងឯកសារដដែលហ្នឹង គឺភាសាខ្មែរមានលេខ 00631505, ភាសាបារាំងគឺមានលេខ 00606715 ហើយនេះគឺជារបាយការណ៍អំពីការសម្ភាសជាមួយសម្តេច សីហនុ ជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយរបស់បារាំង។ ព្រះអង្គក្រោយពីការសាក -- ការចាប់ផ្តើមនៅថ្ងៃ -- សម្តេចដែលបានយល់ព្រមយ៉ាងប្រាកដលើសេចក្តីសម្រេចសមាជជាតិលើកទី២ កាលពីខែកុម្ភៈកន្លងទៅបានកត់សម្គាល់ឃើញថាមេដឹកនាំសំខាន់ៗ និងអតីតថ្នាក់ដឹកនាំរដ្ឋាភិបាលសាធារណរដ្ឋខ្មែរទាំងប្រាំពីររូបត្រូវបានកាត់ទោសប្រហារជីវិត ចំពោះអ្នកដឹកនាំដទៃទៀតត្រូវបានលើកលែងទោស"។

ឯកសារមួយទៀត គឺជាឯកសារខ្មែរដែលមានលេខ -- ភាសាបារាំងគឺមានលេខ 00606718 គឺឯកសារ E3/3341 ហើយអង់គ្លេសគឺមាន 00413198។ គឺបានបញ្ជាក់ថា "លោក អៀង សារី បានចាកចេញពីទីក្រុងប៉េកាំងទៅកាន់មាតុភូមិកាលពីថ្ងៃទី១៥ ខែមីនា ជាមួយសមាជិកត្រៀមក្នុងគណៈមជ្ឈិមបក្សនៃរណសិរ្សរួបរួមជាតិកម្ពុជា លោក គាត ឈន់ និងភរិយាតាមយន្តហោះពិសេសរបស់ខ្លួន"។

[០៩:៥៥:៣៦]

ហើយប្រអប់ក្រហមនៅទំព័រដដែលនិយាយថា "នៅថ្ងៃទី១៥ ខែមីនា លោក ខៀវ សំផន បានផ្សព្វផ្សាយនូវសេចក្តីអំពាវនាវឲ្យមានការតស៊ូកាន់តែខ្លាំង ដែលក្នុងនោះលោកបានបង្ហាញពីទស្សនៈផ្ទាល់ខ្លួនរបស់លោកទៅលើការឈឺចាប់របស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ លោកបានកត់សម្គាល់ពីការខាតបង់ដ៏ធ្ងន់ធ្ងរចំពោះកងនាវាសាធារណរដ្ឋ និងបានបញ្ជាក់ពីការគ្រប់គ្រងក្រុមពួកខ្មាំងដ៏រឹងមាំនៅតាមទន្លេមេគង្គ។ លោកបានអះអាងថា រដ្ឋាភិបាលសាធារណរដ្ឋខ្មែរខ្វះកងកម្លាំង និងកំពុងស្ថិតក្នុងស្ថានភាពនៃការដួលរលំជាទូទៅ"។

នៅក្នុងឯកសារដដែល ខ្មែរ ERN មានលេខ 00631506, ភាសាបារាំងមាន 00606719, ភាសាអង់គ្លេសមានលេខ 00413199 ហើយមានចំណងជើងអត្ថបទថា "សេដ្ឋកិច្ច" "ការស្តុកទុកអង្ករត្រូវបានចាប់ផ្តើមនៅថ្ងៃទី១៧ ខែមីនា មានចំនួនរហូតដល់៨.៣៤១តោន ដែលតំណាងឲ្យកម្រិតផ្គត់ផ្គង់រយៈពេល១៣ថ្ងៃ ដោយផ្អែកលើការចែកចាយប្រចាំថ្ងៃគឺ ៥៤៥តោន ទៅដល់ប្រជាជនទូទៅ និង១០០តោនស្ថិតក្រោមកម្មវិធី។ ការផ្គត់ផ្គង់មានការកើនឡើងក្នុងរយៈពេលពីរបីថ្ងៃក្រោយនេះ។ ការផ្គត់ផ្គង់ប្រជាជនបានគ្រប់តម្រូវការ គឺ១២០ម៉ែត្រគូបក្នុង១ថ្ងៃចេញពីអូរតាប៉ាវ និងមាន៤៥គូប បន្ថែមទៀតរៀងរាល់ថ្ងៃពីសៃហ្គន។ នៅថ្ងៃទី១៣ ខែមីនា ទីភ្នាក់ងារជំនួយអន្តរជាតិសហរដ្ឋអាមេរិកបានបន្តកិច្ចសន្ទនារបស់ខ្លួនជាមួយសហរដ្ឋអាមេរិក និងភ្នាក់ងារស្ម័គ្រចិត្តនានា និងបានលើកទឹកចិត្តពួកគេឲ្យខិតខំខ្លាំងជាងនេះតទៅទៀត"។

[០៩:៥៦:៤១]

ហើយបន្តទៅទៀត ភាសាខ្មែរមានលេខ 00631510, ភាសាបារាំង និងភាសាអង់គ្លេសមានលេខ ERN ដដែល គឺនិយាយថា នៅក្នុងឯកសារដដែលគឺនៅតែជារបាយការណ៍របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក គឺឯកសារមានលេខERN 00631514, ភាសាបារាំងគឺមានលេខ 00606722, ភាសាអង់គ្លេសមានលេខ 00413202 គឺចុះថ្ងៃទី១៥ មីនា ឆ្នាំ៧៥ និយាយអំពីគោលជំហររបស់ខ្មែរក្រហម នៅជិតតំបន់អ្នកលឿងក្បែររាជធានីភ្នំពេញ។

ឯកសារបន្ទាប់គឺរបាយការណ៍ ហ្វីប៊ីស មិនមានការបកប្រែជាភាសាខ្មែរ ឬភាសាបារាំងទេ គឺមានតែអង់គ្លេស គឺអង់គ្លេសមានលេខERN 00166851។ នេះគឺជាការដកស្រង់ចេញពីរបាយការណ៍ហ្វីប៊ីស ហើយនិយាយអំពីព្រឹត្តិការណ៍នៅថ្ងៃ២០ មីនា ឆ្នាំ៧៥ ហើយចំណងជើងអត្ថបទនេះ គឺនិយាយ

អំពីគ្រាប់រ៉ុក្កែត បានប៉ះផ្ទះលោក ឡុង បូរ៉េត ហើយបិះប៉ះស្ថានទូតសហរដ្ឋអាមេរិក។ របាយការណ៍និយាយថា "រ៉ុក្កែតថ្ងៃនេះបានផ្ដោងត្រូវផ្ទះលោកនាយករដ្ឋមន្ត្រី ឡុង បូរ៉េត និងលោកមេទ័ព វង្សសារិនឌី ដែលនៅក្នុងទីក្រុងភ្នំពេញ ប៉ុន្តែមិនមានជនដែលត្រូវរបួស ឬស្លាប់ដោយសារការទម្លាក់គ្រាប់បែកនេះឡើយ។ នេះគឺជាការផ្ដោងគ្រាប់បែកប្រហែលជា២០គ្រាប់ ពីសំណាក់ពួកកងកម្លាំងចូលទៅក្នុងទីក្រុងភ្នំពេញ"។

[០៩:៥៩:១៦]

ឥឡូវនេះ ខ្ញុំសូមបន្តទៅឯកសារថ្មី E3/118 មិនមានការបកប្រែជាភាសាខ្មែរ ឬបារាំងទេ។ អង់គ្លេសមាន 00166901 គឺជារបាយការណ៍របស់ ហ្វីប៊ីស ដដែល។ បាននិយាយអំពីព្រឹត្តិការណ៍ថ្ងៃ ០១ មេសា ឆ្នាំ៧៥។ គឺខ្ញុំសូមអាននូវសម្រង់ដូចទៅនេះ "នៅថ្ងៃ០១ មេសា ៧៥ ហើយនេះគឺជាការផ្សព្វផ្សាយតាមវិទ្យុ ដោយវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា ហើយជាការផ្សព្វផ្សាយដោយលួចលាក់ផ្សាយជាភាសាខ្មែរទៅកាន់ប្រទេសកម្ពុជា ហើយបានរៀបរាប់ដូចតទៅនេះ៖ "នៅថ្ងៃ០១ មេសា ៧៥ នៅពេលរសៀល ប្រជាជនកម្ពុជា គឺរណសិរ្សរួបរួមជាតិកម្ពុជា កងបានរំដោះអ្នកលឿង ហើយជោគជ័យនេះ គឺមានសារៈសំខាន់យ៉ាងសំខាន់ ដោយសារនេះគឺជាមូលដ្ឋានដល់សំខាន់របស់ខ្មាំង ហើយជាទីតាំងដ៏មាំរបស់ពួកខ្មាំង។ ការនេះបានន័យថា ពួក -- គឺ ស៊ី.ភី.អិន.អិល.អេ.អេហ្វ គឺប្រជាជនកម្ពុជាបានគ្រប់គ្រងទាំងស្រុងទៅលើតំបន់ទន្លេមេគង្គចាប់ពីទីក្រុងភ្នំពេញ រហូតទៅដល់វៀតណាមខាងត្បូង រហូតទៅដល់ព្រំដែនវៀតណាមខាងត្បូង"។

បាទ យើងខ្ញុំសូមចូលទៅទំព័របន្ទាប់ គឺERN 0016690 ដែលគ្របដណ្ដប់ពេលវេលាពីថ្ងៃ០១ មេសា ជាការផ្សព្វផ្សាយតាមវិទ្យុ។ នៅថ្ងៃទី០៣ មេសា ដែលគ្របដណ្ដប់ព្រឹត្តិការណ៍ថ្ងៃ០១ ខែមេសា ដែលនិយាយដូចខាងក្រោម "នៅថ្ងៃទី០១ មេសា ៧៥ បន្ទាប់ពីសេនាប្រមុខ លន់ នល់ ចាកចេញពីក្រុងភ្នំពេញ កាតព្វកិច្ចរបស់ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែររបស់ សីលល្មីស (តាមសំឡេងបកប្រែ) សូ ខាំខូយ យោងទៅតាមរដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋ ដែលនិយាយអំពីការរិះរកមធ្យោបាយដើម្បីដោះស្រាយបញ្ហាដោយសន្តិវិធី និងសង្គ្រោះជាតិ។ គាត់បានិយាយអំពីរដ្ឋបាលសាធារណខ្មែរ ចង់ធ្វើការទំនាក់ទំនងជាមួយនឹងបងប្អូននៅភាគីម្ខាងទៀត ដើម្បីរៀបចំផែនការបង្រួបបង្រួមជាតិនេះ"។

[១០:០២:៤២]

ខ្ញុំសូមឲ្យមានជំនួយការពីខាងផ្នែក អាយ.ធី.យូ គឺទាក់ទងទៅនឹងសម្រង់នៃបទបង្ហាញនេះ។ ខ្ញុំចង់

ឲ្យអង្គភាព អាយ.ធី.យូ នេះបង្ហាញជូននូវវីដេអូទី១ ដែលមានចំណងជើងថា "ប៉ុល ពត ជាមេឃាតករ" ដែលមានរយៈពេល១៥វិនាទី ជាការដកស្រង់ចេញពីភាពយន្តឯកសារដែលមានឯកសារយោង D108/32.2R នៅក្នុងសំណុំរឿងនេះ គឺនៅក្នុងការបង្ហាញដែលមានរយៈពេល១៥ តែ១៥វិនាទីទេ គឺមានការរៀបរាប់បង្ហាញនៅក្នុងខ្សែភាពយន្តជាភាសាអង់គ្លេស ហើយសុំឲ្យអ្នកប្រែ អាយ.ធី.យូ សុំបកប្រែចេញពីភាសាអង់គ្លេស។

នេះគឺជាសម្រង់តែមួយគត់ដែលនៅក្នុងបទបង្ហាញរបស់យើងខ្ញុំ ដែលមានការធ្វើការរៀបរាប់ជាភាសាអង់គ្លេសនេះ។ ដូច្នេះ ខ្ញុំសូមឲ្យខាង អាយ.ធី.យូ អ្នកចាក់វីដេអូខ្សែទី១ ដែលដកស្រង់ចេញពីខ្សែភាពយន្តថា "ប៉ុល ពត នេះ ជាមេឃាតករ"។

**ប្រធានអង្គជំនុំ៖**

បាទ អ្នកបច្ចេកទេសចាក់ផ្សាយតាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមឲ្យមានការចាកផ្សាយពីខាង អេ.វី នេះ ដោយមានទាំងសំឡេងផង។ សូមអរគុណ។

បាទ សូមឲ្យចាក់ការសាឡើងវិញ ហើយឲ្យមានតាំងសំឡេងផង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អ្នកបច្ចេកទេសចាក់ផ្សាយសាឡើងវិញ ហើយឲ្យមានតាំងសំឡេងផង។

[១០:០៥:៣០]

*(ការបង្ហាញឯកសារជាវីដេអូលេខ១)*

"ខ្មែរក្រហមកំពុងធ្វើការប្រយុទ្ធដោយមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុង -- កងទ័ពសហរដ្ឋអាមេរិកដែលបានដកចេញពីវៀតណាមហើយក៏ចាកចេញពីកម្ពុជា។ ប៉ុល ពត បានបញ្ជាឲ្យមានការប្រយុទ្ធ តែភាគីរបស់ខាងខ្លួននៅដើមខែមេសា ឆ្នាំ៧៥ កងទ័ពលន់ នល់ បានចូលមកក្នុងទីក្រុងភ្នំពេញ។ ប្រជាជនគឺថាមានការហូរចូលពីជនបទ មានការរងរបួសដោយការបាញ់ផ្លោងរបស់ទាហានខ្មែរក្រហមបន្ទាប់មក លន់ នល់ បានភៀសខ្លួនចេញទៅសហរដ្ឋអាមេរិកដោយយកប្រាក់ទៅជាមួយរាប់លានដុល្លារ"។

*(បញ្ចប់ការបង្ហាញឯកសារជាវីដេអូ)*

[១០:០៦:២៨]

**លោក ឃីត វេយ៍ន័រ៖**

បាទសូមអរគុណ។

បាទចូលទៅឯកសារ E3/118 ជាឯកសាររាយការណ៍ដោយ ហ្វីប៊ីស មានតែជាភាសាអង់គ្លេស ERN ជាភាសាអង់គ្លេស 00166919 ជារបាយការណ៍គ្របដណ្ដប់ព្រឹត្តិការណ៍ថ្ងៃទី៤ មេសា ៧៥ ការដកស្រង់គឺមានដូចខាងក្រោមនេះ "នៅក្នុងស្ថានភាពដ៏លំបាកនាពេលបច្ចុប្បន្នហើយនៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការ នៃការចល័តទ័ពទាំងអស់រដ្ឋាភិបាលបានសម្រេចខ្ចីអាវុធយុទ្ធភណ្ឌពីប្រជាពលរដ្ឋទាំងអស់ ទោះបីជាគេមានប័ណ្ណកាន់កាប់អាវុធឬក៏មិនមានក្ដី"។

នៅលើឯកសារ E3/118 ដដែលជារបាយការណ៍ចុះថ្ងៃទី០៦ មេសា ៧៥ ERN ជាភាសាអង់គ្លេស 00166921 ជារបាយការណ៍របស់ ហ្វីប៊ីស ដែលមានចំណងជើងថា "ឡុង បូរ៉េត ឈប់នៅបាងកក នៅពេលធ្វើ ដំណើរមកកាន់ទីក្រុងភ្នំពេញ"។ និយាយអំពីព្រឹត្តិការណ៍នៅថ្ងៃទី០៦ មេសា សូមដកស្រង់ដូចតទៅនេះ "របាយការណ៍របស់ភ្នាក់ងាររ៉យទ័រដែលថា នាយករដ្ឋមន្ត្រី ឡុង បូរ៉េត បានមកដល់បាងកកនៅរសៀលថ្ងៃអាទិត្យ តាមដំណើររបស់គាត់មកពីទីក្រុងហ្សាការតាមកកាន់ប្រទេសកម្ពុជា។ គាត់បាននិយាយ ថាមិនមានការទទួលជោគជ័យដោយយោធានោះទេ គឺត្រូវតែមានការចរចាគ្នា ដែលថាភាគីម្ខាងទៀតមិនចូលរួមក្នុងការចរចាទេ ដូច្នេះត្រូវតែភាគីនោះ ត្រូវតែទទួលខុសត្រូវចំពោះបញ្ហាកម្ពុជានេះ។ ឡុង បូរ៉េត ក៏បានអំពាវនាវឲ្យមានការបោះឆ្នោតតាមបែបប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ដោយមានច្បាប់គ្រប់គ្រង ដើម្បីជ្រើសរើសមេដឹកនាំរបស់ខ្លួន"។

[១០:០៨:០០]

ឃ្លាបន្ទាប់ទៀតគឺគ្រប់ដណ្ដប់ថ្ងៃទី០៩ មេសា ៧៥ ERN ជាភាសាខ្មែរ 00700274 ដល់ 75, ERN ជាភាសាអង់គ្លេស 00166927 ជារបាយការណ៍ផ្សាយ ដោយវិទ្យុរបស់រណសិរ្សរួបរួមជាតិកម្ពុជា នៅក្នុងប្រទេសកម្ពុជាផ្សាយជូនប្រជាជនកម្ពុជាទាំងអស់ ដែលនិយាយថាការបដិសេធរបស់ខៀវ សំផន។ ឯកសារនេះនិយាយដូចតទៅនៅកថាខណ្ឌទី២ "យោង តាមប្រភពពីលោកខាងលិចមួយចំនួន ប៉ុន្មានថ្ងៃមុន អាឡុង បូរ៉េត បានថ្លែងថាខ្លួនបានទំនាក់ទំនងស្វែង រកការចរចាជាមួយភាគីផ្សេងទៀតរួចហើយ។ ប្រភពទាំងនេះបានរាយការណ៍ថា ខ្លួនបានទំនាក់ទំនងជាមួយនឹងរដ្ឋមន្ត្រីការបរទេសក្រិក ដែលនិយាយជាច្រើនដងថា មានការចរចារវាងភាគីកម្ពុជាទាំងពីរនៅក្នុងទីក្រុងបាងកក។ ហើយ

គាត់ក៏បាននិយាយថា អាឡុង បូរ៉េត បានជួបជាមួយអ្នកតំណាងរបស់ភាគីផ្សេងទៀតរយៈពេល៤ម៉ោង ក្នុងបរិយាកាសល្អមួយ។ ក្នុងនាមប្រទេសជាតិ និងប្រជាជនកម្ពុជាទាំងមូល កងទ័ពរំដោះជាតិប្រជាជនកម្ពុជារណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា សូមចេញផ្សាយសេចក្តីថ្លែងការណ៍ ដើម្បីជំទាស់ទៅនឹងឧបាយកលបោកបញ្ឆោតនេះ។ នេះគឺជាឧបាយកលពោរពេញទៅដោយភាពអាម៉ាស់ដែលអ្នកនយោបាយល្អ និងធម្មតាស្អប់ខ្ពើម។ ស្របពេលដែលក្រុមបរិវារដ៏អស់សង្ឃឹមកំពុងតែដង្ហក់ខ្យល់ មានតែបង្កើតឧបាយកលបោកបញ្ឆោតបែបនេះទេ ទើបបោកចៅហ្វាយរបស់ខ្លួនបាន។ ដូចដែលពួកគេបានបង្កើតឧបាយកលនេះឡើងក្នុងឱកាសមួយចំនួនកន្លងមក រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សូមបញ្ជាក់ឲ្យបានច្បាស់លាស់ជាថ្មីជូនដល់មតិជាតិ និងអន្តរជាតិថា យើងខ្ញុំពិតជាមិនធ្លាប់បានចរចាជាមួយពួកគេនោះទេ។ ហើយយើងក៏មិនធ្លាប់ទទួលការចរចាជាមួយពួកក្រុមក្បត់នោះដែរ”។

[១០:១២:០៦]

ចូលទៅដល់ថ្ងៃទី១០ មេសា នៅលើឯកសារ E3/118 ដែល ERN ជាភាសាអង់គ្លេស 0066937 មិនមានការបកប្រែទៅជាភាសាខ្មែរ ឬក៏ជាភាសាបារាំងទេ។ នេះគឺជារបាយការណ៍ហ្វីប៊ីសដែលជារបាយការណ៍ផ្សាយនៅថ្ងៃទី១០ មេសា “ប្រជាជនកម្ពុជា កងទ័ពរំដោះជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជាក៏បានធ្វើការថ្កោលទោសទៅដល់ពួកក្បត់ទាំងប្រាំពីរនាក់ ហើយពួកនេះគឺថា គឺបញ្ឈប់ពួកក្បត់ទាំងប្រាំពីរនាក់មាន សិរិមតៈ, ឡុង បូរ៉េត ដែលឥឡូវនេះរស់នៅក្នុងទីក្រុងភ្នំពេញនៅឡើយ។ នៅក្នុងពេលនេះប្រជាជន និងកងទ័ពប្រជាជនរំដោះជាតិកម្ពុជា កំពុងវាយប្រហារមកលើទីក្រុងភ្នំពេញគ្រប់ទិសទាំងអស់។ ប្រជាជនកម្ពុជា គឺកំពុងវាយប្រយុទ្ធដោយមិនមានការយោគយល់ចរចាអ្វី ហើយជាពិសេសកងកម្លាំងប្រដាប់អាវុធ និងប្រជាជនកម្ពុជា នឹងប្រយុទ្ធប្រឆាំងជាមួយកងទ័ពបដិបក្ស ឬពួកអាក្បត់ ដែលជាមួយពួកក្បត់ទាំងនេះ ក៏ដូចជារបបរបស់ពួកវា។ កងទ័ពប្រជាជនរំដោះជាតិកម្ពុជាកំពុងឈានមកដល់មាត់ទ្វារនៃទីក្រុងភ្នំពេញ ព្រៃវែង កំពង់ស្ពឺ ហើយគេកំពុងតែវាយសម្រុកទៅមុខដើម្បីរំដោះប្រទេសកម្ពុជាឲ្យបាន១០០ ភាគរយតែម្តង”។

[១០:១៤:១៥]

ខ្ញុំសូមចូលទៅឯកសារគ្របដណ្តប់ថ្ងៃទី១២ មេសា ៧៥។ នេះជារបាយការណ៍របស់ហ្វីប៊ីស E3/118 ERN អង់គ្លេស 00166939 ដល់ 40 មិនមានការបកប្រែជាភាសាខ្មែរ ឬបារាំងទេ។ សូម

អានជាភាសាអង់គ្លេសដដែល។ ចំណងជើងគឺថា "ឡុង បូរ៉េត បានថ្លែងសុន្ទរកថាទៅកាន់ជនរួមជាតិ បន្ទាប់ពី សូ ខាំខូយ បានរត់គេចខ្លួន" គឺផ្សាយនៅថ្ងៃ១២ ខែមេសា ឆ្នាំ៧៥។ នៅឃ្លាទី២ នៃឯកសារនេះនិយាយថាដូច្នេះ "នៅព្រឹកនេះ ឧត្តមសេនីយ៍ សូ ខាំខូយ ជាប្រធានាធិបតីស្តីទីនៃរបបសាធារណរដ្ឋខ្មែរបានចាកចេញពីទីក្រុងភ្នំពេញ ដោយមិនបានជម្រាបអ្វីទៅកាន់ជនរួមជាតិ។ ការចាកចេញរបស់គាត់នេះក៏ចេញពីរបបសាធារណរដ្ឋ ដោយមិនមាននូវប្រធានស្តីទីណាទេ ដូច្នេះខ្ញុំសូមកោះអញ្ជើញប្រជុំជាបន្ទាន់នៅវិមានចំការមក ដោយមានអ្នកចូលរួម"។

ហើយនៅខាងក្រោមនៃទំព័រនេះដដែល "នៅក្នុងឱកាសនោះ ខ្ញុំនិងឧត្តមសេនីយ៍ សាក់ ស៊ុតសាខន នាយអគ្គសេនាធិការនៃកងទ័ពប្រជាជនកម្ពុជា បានចេញនូវរបាយការណ៍មួយ ដែលត្រូវប្រជុំធ្វើសេចក្តីសម្រេចដូចខាងក្រោម៖ ទី១ ឧត្តមសេនីយ៍ សូ ខាំខូយ គឺថាមិនត្រូវទទួលស្គាល់ជាប្រធានាធិបតីស្តីទីតទៅទៀតទេ"។

[១០:១៦:០៥]

ហើយនៅទំព័របន្ទាប់នេះគឺជា "សូមឲ្យរដ្ឋសភាផ្ទេរអំណាចមកដល់កងទ័ពរបស់យើងក្នុងរយៈពេល៣ខែ។ កងទ័ពរបស់យើងនឹងបង្កើតនូវស្ថាប័នបណ្តោះអាសន្នមួយដែលយើងហៅថា ឧត្តមក្រុមប្រឹក្សានៃរបបសាធារណរដ្ឋខ្មែរ ដើម្បីជំនួសប្រធានាធិបតីស្តីទីក្នុងរយៈពេលនេះ"។

ចូលទៅឯកសារក្របដណ្តប់ថ្ងៃទី១៧ មេសា ៧៥ នៅលើឯកសារ E3/118 ដដែល, ERN ជាភាសាអង់គ្លេស 00166958។ ចំណងជើងនៃឯកសារនេះ គឺជាទីភ្នាក់ងារសារព័ត៌មានបារាំងរាយការណ៍អំពីស្ថានភាពដុនដាបរបស់កងទ័ពនៅថ្ងៃទី១៤ និង១៥ ខែមេសា។ កងទ័ពរដ្ឋាភិបាលបោះបង់ចោលនូវរោងចក្រតាខ្មៅ ដែលមានចម្ងាយប្រមាណ ៦*ម៉ាយ* ភាគខាងត្បូងនៃទីក្រុងភ្នំពេញ បន្ទាប់ពីពួកកងទ័ពខ្មែរក្រហមបានបាញ់ផ្លោងកាំភ្លើងអាល់ទែរីចូលនៅទីនោះ។

ហើយមានការផ្សាយនៅថ្ងៃដដែលនេះថា នេះគឺជាព័ត៌មានចេញមកពី ហ្សង់-ហ្សាក់ កាហ្សូ ជាអ្នកកាសែតបារាំងម្នាក់ដែលធ្វើការផ្សាយនៅថ្ងៃទី១៥ មេសា "ស្ថានភាពកងទ័ពនៅជួរមុខភ្នំពេញ គឺថាមានការធ្លាក់ចុះយ៉ាងខ្លាំង សម្រាប់ការការពារទីក្រុងក្នុងរយៈពេលប៉ុន្មានម៉ោងនេះ ដែលកងទ័ពរដ្ឋាភិបាលបានបោះបង់មូលដ្ឋានកងទ័ពរបស់ខ្លួនសំខាន់ៗពីរបីកន្លែង"។

[១០:១៨:០២]

ឯកសារដដែលគឺ ERN 00166950 នៅថ្ងៃទី១៥ មេសា ដដែលមានចំណងជើងថា "វិទ្យុរបស់

កងទ័ពរំដោះជាតិកម្ពុជា" និយាយថា "តំបន់ព្រលានយន្តហោះពោធិ៍ចិនតុងត្រូវបានរំដោះទាំងស្រុង"។ គឺមានការផ្សាយដូចខាងក្រោមនេះ "នៅព្រឹកថ្ងៃទី១៥ មេសា នៅម៉ោងដប់ យើងបានរំដោះព្រលានយន្តពោធិ៍ចិនតុងទាំងស្រុង។ មន្ត្រី ទាហាន ក៏ដូចជាអាកាសយានិករាប់រយពាន់ គឺថាបាន ត្រូវបានឡោមព័ទ្ធ និងត្រូវបានចាប់ខ្លួន។ ភូមិទួលគោកនៅថ្ងៃទី១៥ មេសា គឺថាបានវាយប្រហារទៅលើតំបន់ទួលគោក។ ហើយពីគីឡូម៉ែត្រលេខ៦ គឺយើងកំពុងតែវាយសម្រុកឆ្ពោះទៅកាន់ឫស្សីកែវ ហើយនិងក៏កំពុងតែសម្រុកទៅកាន់តំបន់ភាគខាងកើតនៃទីក្រុងភ្នំពេញ"។

ហើយនៅថ្ងៃទី១៥ មេសា នេះដដែល នៅឯក -- 00166950 នេះជា ERN អង់គ្លេស។ នៅថ្ងៃទី១៥ មេសា កងទ័ពខ្មែរក្រហមបានបើកការវាយប្រហារទៅកាន់ជាយក្រុងភ្នំពេញ ប្រហែលជា៤គីឡូម៉ែត្រពីទីក្រុងភ្នំពេញតែម្តង។ ខ្មែរក្រហមបានវាយប្រយុទ្ធទៅលើកងវរៈ -- សូមទោស-- ចំនួនបួនដើម្បីពង្រឹងខ្សែប្រយុទ្ធរបស់ខ្លួន រហូតឈានទៅដល់ស្ពានទន្លេសាបាក់"។

[១០:១៩:៥១]

ERN ជាភាសាអង់គ្លេសដដែល 00166966 គឺព្រឹត្តិការណ៍ថ្ងៃទី១៥ មេសា ដដែល ដែលមានចំណងជើងថា "រដ្ឋាភិបាលអំពាវនាវឲ្យវេជ្ជបណ្ឌិតព្យាបាលដល់អ្នករងរបួស"។ ការផ្សព្វផ្សាយនេះ គឺផ្សព្វផ្សាយនៅថ្ងៃទី១៥ មេសា ហើយអត្ថបទនេះក៏មានរាយការណ៍ដូចខាងក្រោម "ឧត្តមសេនីយ៍ទោ ទឹម ម៉ាម និងនាយអគ្គសេនាធិការដែលជាប្រធានផ្នែកខាងសុខាភិបាលកងទ័ព និង អ៊ុំង សុនសឿន គឺថាឲ្យព្យាបាលអ្នករបួស និងកងទ័ពយោធារាប់រយនាក់។ អំពាវនាវទៅដល់និស្សិតពេទ្យទាំងអស់ ក៏ដូចជាកងទ័ព និងក៏ដូចជាជនស៊ីវិលឲ្យរាយការណ៍នូវ -- ឲ្យចូលរួមជួយព្យាបាលនៅបុរីកីឡា ដើម្បីជួយផ្តល់ការព្យាបាលទៅដល់អ្នករងរបួសទាំងអស់នេះ"។ ឯកសារដដែល ERN ជាភាសាអង់គ្លេស 00166968 គ្របដណ្តប់ព្រឹត្តិការណ៍ថ្ងៃទី១៥ មេសា ដដែលជាសេចក្តីរាយការណ៍មានចំណងជើងថា "សិរិមតៈ សរសេរទៅហ្វូតឌី សហរដ្ឋអាមេរិក សម្តេចសិរិមតៈ អតីតនាយករដ្ឋមន្ត្រី និងជាអ្នករៀបចំរដ្ឋប្រហារប្រឆាំងទៅលើសម្តេចនរោត្តមសីហនុ"។ ថ្ងៃនេះបានផ្ញើសារទូរលេខទៅដល់ប្រធានាធិបតីចូល្ទហ្វូបាននិយាយថា សូមដកស្រង់ "មរណភាពរបស់ប្រជាជនកម្ពុជានាពេលបច្ចុប្បន្នទាំងអស់គឺថា -- គឺវាស្ថិតនៅលើមនសិការរបស់ប្រជាជនអាមេរិក" ដែលមានលេខ ERN 00166969 ដែលនិយាយទីភ្នាក់ងារសារព័ត៌មានកម្ពុជាកាលពីម្សិលមិញនិយាយអំពីឧត្តមសេនីយ៍ លន់ នល់ និយាយឆ្លើយតបទៅនឹងលោក ឌី "ខ្ញុំសូមអរគុណចំពោះលោកដែលបានបង្កឲ្យខ្ញុំមានសេរីភាព ខ្ញុំមិនអាចរស់ក្នុងស្ថានភាព

កំសាកញ៉ីបែបនេះទេ។ ខ្ញុំដែលមិនជឿថា លោក -- ខ្ញុំមិននឹកថាលោកបោះចោលយើងសោះ បើសិន ខ្ញុំស្លាប់នៅទីនេះ នេះគឺដោយសារតែខ្ញុំដែលជាអ្នកធ្វើឲ្យមានកំហុស ខ្ញុំជឿទៅលើរូបលោក”។

[១០:២២:៥១]

ចូលទៅឯកសារថ្មីទៀត E3/3445 ERN ជាភាសាខ្មែរ 00738432 ទៅដល់ខ្មែរ 00737346, ទំព័រខាងមុខជាភាសាអង់គ្លេសគឺមាន ERN 00443342 ហើយបារាំង 00777633។ នេះគឺជាឯកសារដែលមានចំណងជើងថា “អនុស្សរណៈដែលផ្សាយចេញមកពីសេតវិមានវ៉ាស៊ីនតោន ដែលជាកិច្ចប្រជុំគណៈរដ្ឋមន្ត្រី ដែលប្រជុំនៅទីក្រុងវ៉ាស៊ីនតោននៅថ្ងៃពុធ ១៦ មេសា ៧៥ នៅវេលាម៉ោងពីរសាមសិបនាទីរសៀល។ កិច្ចប្រជុំនេះប្រជុំនៅក្នុងបន្ទប់គណៈរដ្ឋមន្ត្រីនៅសេតវិមាន។ សម្រង់ដែលខ្ញុំចង់យោងគឺនៅជា ERN ជាខ្មែរ 00078435 ដល់ 436, ERN ជាភាសាបារាំង 00777636 ហើយជាអង់គ្លេស 00443342 គឺរាយការណ៍ដោយ ឃីស៊ីងហ្គ័រ។

[១០:២៤:២៧]

“ខ្ញុំសូមអានលិខិតមួយដែលយើងបានទទួលពីលោក សិរិមតៈ មេដឹកនាំខ្មែរមួយរូបផ្ញើជូនចំពោះឯកអគ្គរដ្ឋទូតរបស់យើង នៅពេលឯកអគ្គរដ្ឋទូតរបស់យើងបានអញ្ជើញគាត់ឲ្យចាកចេញជាមួយជនភៀសខ្លួន”។ ចប់ការដកស្រង់។

ឯនេះគឺជាសម្រង់ “ជូនចំពោះឯកឧត្តម និងមិត្តជាទីរាប់អាន ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះចំពោះឯកឧត្តមដែលបានដឹកជញ្ជូនខ្ញុំប្រកបដោយសុវត្ថិភាព ប៉ុន្តែគួរឲ្យស្តាយព្រោះខ្ញុំមិនអាចចាកចេញក្នុងរូបភាពដ៏កំសាកបែបនេះឡើយ ចំពោះឯកឧត្តមជាពិសេសគឺចំពោះប្រទេសដ៏មហិមារបស់ឯកឧត្តមវិញ។ ខ្ញុំមិនធ្លាប់ជឿទាល់តែសោះថា អ្នកនឹងមានចិត្តបោះបង់ប្រជាជនដែលបានជ្រើសរើសយកសេរីភាពនោះឡើយ។ អ្នកបានបដិសេធមិនផ្តល់ការការពារដល់យើង ហើយយើងក៏មិនអាចធ្វើអ្វីបានឡើយចំពោះរឿងនេះ។ ពួកអ្នកចាកចេញទៅ យើងខ្ញុំសូមជូនពរអ្នកដែលប្រទេសបានជួបសុភមង្គលនៅក្រោមមេឃនេះ ប៉ុន្តែសូមអ្នកចងចាំឲ្យច្បាស់ថា ប្រសិនបើខ្ញុំត្រូវស្លាប់នៅទីកន្លែងក្នុងប្រទេសរបស់ខ្ញុំជាទីស្រឡាញ់ វាជារឿងគួរសោកស្តាយណាស់ ព្រោះថាមនុស្សយើងដែលកើតមកហើយ ត្រូវតែស្លាប់ទៅវិញនៅថ្ងៃណាមួយមិនខាន។ អ្វីដែលជាកំហុសរបស់ខ្ញុំនោះ គឺខ្ញុំជឿជាក់លើពួកអ្នកដែលជាជនជាតិអាមេរិក”។

[១០:២៥:៥៥]

បាទខ្ញុំសូមចូលទៅឯកសារ E3/118 នៅថ្ងៃទី១៦ មេសា ៧៥ ERN ជាភាសាអង់គ្លេស 00166959។ នេះជារបាយការណ៍ ហ្វីប៊ីស នៅថ្ងៃទី១៦ មេសា ដែលរាយការណ៍ដូចខាងក្រោម “កងទ័ពខ្មែរក្រហម បានកាន់កាប់ប៉មត្រួតពិនិត្យព្រលានយន្តហោះពោធិ៍ចិនតុងនៅម៉ោងបួនរសៀលថ្ងៃនេះ”។ នេះជាការផ្សាយនៅថ្ងៃដដែលដែរ គឺយើងទៅលើសេចក្ដីរាយការណ៍របស់អ្នកកាសែតបារាំង ហ្សង់-ហ្សាក់ ដែលថានៅនាទីចុងក្រោយមានការវាយប្រហារគ្នាយ៉ាងតឹងតែងនៅ មានការ មានភាពរញ៉េរញ៉ៃ ហើយមានការកាប់សម្លាប់គ្នានោះ។ នៅព្រឹក កងទ័ពខ្មែរក្រហមបានវាយមកដល់តំបន់ជាយក្រុង។ នៅពេលការប្រយុទ្ធកាន់តែធ្លាក់ថយមកបន្តិចម្ដងនោះ។ ជាពិសេសគឺប្រភពដែលបានរាយការណ៍ថា មេដឹកនាំទីក្រុងភ្នំពេញ អាចនឹងស្នើសុំឱ្យមានបទឈប់បាញ់ទៅដល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលហៅកាត់ថា អា.ជី.យូ.អិន.ស៊ី ដើម្បីបញ្ឈប់ការប្រយុទ្ធបង្ហូរឈាមចុងក្រោយនេះ។ ទំព័របន្ទាប់ជាភាសាអង់គ្លេស 00166960 ដែលរាយកាករណ៍ដូចតទៅនេះ។

លោកប្រធាន ខ្ញុំបានក្រឡេកទៅមើលនាឡិកា ខ្ញុំសូមបញ្ចប់តែត្រឹមថ្ងៃ១៦ មេសា សិនទេ។ “នៅថ្ងៃនេះ នៅពេលស្ថានភាពកាន់តែអាក្រក់ទៅនៅភាគខាងត្បូង កងទ័ពខ្មែរក្រហម បានចូលមកភាគខាងលិចនៃទីក្រុងភ្នំពេញ។ ពួកគេបានបន្តដំណើរមកកាន់ព្រលានយន្តហៅពោធិ៍ចិនតុង។ ផ្លូវនេះគឺថានៅតែចរាចរណ៍បាននៅឡើយទេ ប៉ុន្តែរដ្ឋាភិបាលបានបិទផ្លូវ កុំឱ្យជនភៀសខ្លួន ភៀសខ្លួនចេញ ហើយនិងមានការស្ទន់ស្ទោ និងដើម្បីទប់ស្កាត់កុំឱ្យកងទ័ពខ្មែរក្រហមចូលទៅ។ នៅម៉ោង០៤:០០៖ វិទ្យុរដ្ឋា-ភិបាលបានរាយការណ៍ថា ប៉មនៅព្រលានយន្តហោះ គឺថាត្រូវបានកាន់កាប់ហើយនៅម៉ោងបួនរសៀល។ មានឮសំឡេងបាញ់បោះនៅទីក្រុងភ្នំពេញនៅក្នុងថ្ងៃនេះ។ រដ្ឋាភិបាលបានទៅដល់ផ្លូវអាកាសយាន -- ផ្លូវអយស្ម័យយាន គឺថាមិនមានការប្រយុទ្ធតបតនោះទេ”។

[១០:២៩:១៨]

កថាខណ្ឌពីរខាងក្រោមទៀតនេះ បន្ទាត់ពីរនេះគឺថានាយករដ្ឋមន្ត្រី ឡុង បូរ៉េត បានទទួលថា ស្ថានភាពកងទ័ពនេះ គឺបានធ្លាក់ដុនដាបហើយ។ ហើយគាត់ក៏បាននិយាយថា ឡុង បូរ៉េត ហាក់បីដូចជាទទួលយកនូវសេចក្ដីសម្រេចណាមួយ ដែលសេចក្ដីសម្រេចចិត្តណាមួយក៏បានឱ្យតែបញ្ឈប់ការវាយប្រយុទ្ធគ្នា។ ហើយនៅក្នុងឯកសារដដែល ERN 00166970 នៃរបាយការណ៍របស់ ហ្វីប៊ីស នៅថ្ងៃទី ១៦ មេសា ដដែល។ ចំណងជើងនៃការផ្សាយគឺថា “មេដឹកនាំភ្នំពេញស្នើសុំឱ្យមានបទឈប់បាញ់ និងមានការផ្ទេរអំណាចទៅ នៅថ្ងៃទី១៦ មេសា” អត្ថបទដែលស្នើសុំដោយទីក្រុងភ្នំពេញថ្ងៃនេះ សុំឱ្យមាន

បទឈប់បាញ់គ្នា និងការផ្ទេរអំណាចទៅឲ្យសម្តេចនរោត្តម សីហនុ ជាប្រមុខនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ព័ត៌មាននេះ គឺត្រូវផ្សព្វផ្សាយដោយគណៈរដ្ឋមន្ត្រីរបស់ព្រះនៅថ្ងៃនេះតែម្តង។ ហើយទាក់ទងទៅនឹងឆ្លើយតបសំណើសុំឲ្យមានបទឈប់បាញ់ ERN 00166971 ជារបាយការណ៍ ហ្វីប៊ីស នៅថ្ងៃទី១៦ មេសា មានចំណងជើងថា "សម្តេច សីហនុ បដិសេធចំពោះការថ្វាយអំណាចនេះ៖ សម្តេចនរោត្តម សីហនុ នៃប្រទេសកម្ពុជាថ្ងៃនេះ បានបដិសេធ និងមិនទទួលយកនូវសំណើពីឧត្តមក្រុមប្រឹក្សានៃទីក្រុងភ្នំពេញរបស់ សាក់ ស៊ុតសាខន និងនាយករដ្ឋមន្ត្រី ឡុង បូរ៉េត ដែលស្នើសុំឲ្យមានបទឈប់បាញ់ និងផ្ទេរអំណាចមកឲ្យព្រះអង្គ"។

[១០:៣១:២១]

ហើយ ERN ជាភាសាអង់គ្លេសបន្ទាប់ គឺ 0016963 (ស៊ីក) ផ្សាយនៅថ្ងៃទី១៦ មេសា មានចំណងជើងថា "កងទ័ពប្រជាជនរំដោះជាតិកម្ពុជា បានចេញសេចក្តីអំពាវនាវដល់ប្រជាជនឲ្យរំដោះទីក្រុងភ្នំពេញ ដែលផ្សព្វផ្សាយដោយរណសិរ្សរួបរួមជាតិកម្ពុជា នៅក្នុងប្រទេសកម្ពុជា ជូនដល់ប្រជាជនកម្ពុជាទាំងអស់នៅថ្ងៃទី១៦ មេសា ៧៥"។ អត្ថបទនេះបានសរសេរថា "កងទ័ពរំដោះជាតិរបស់យើងកំពុងគ្រប់គ្រងពោធិ៍ចិនតុងទាំងស្រុង និងផ្នែកខ្លះនៃផ្លូវជាតិលេខ៤ ចន្លោះពីពោធិ៍ចិនតុង ទៅភ្នំពេញ ហើយពួកយើងបានទៅដល់ទួលគោក និងទៅដល់គីឡូម៉ែត្រលេខ៦។ សមមិត្តរបស់យើង និងជនរួមជាតិកំពុងតែឈានចូលទៅកាន់ទីក្រុងភ្នំពេញ ដែលស្ថិតនៅក្នុងតំបន់របស់បច្ចាមិត្ត ហើយកំពុងតែឈានផ្តោះរុលទៅរកបច្ចាមិត្ត។ យើងមានបំណងរំដោះទីក្រុងភ្នំពេញ បាត់ដំបង និងទីក្រុង ទីរួមខេត្តដទៃទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងទ័ពរណសិរ្សនោះ"។

បាទ លោកប្រធាន នេះគឺរៀបរាប់អំពីព្រឹត្តិការណ៍ថ្ងៃទី១៦ មេសា ៧៥។ហើយ ខ្ញុំគិតថា ពេលវេលាសមស្របសម្រាប់ឈប់សម្រាកហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសមល្មមឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១០:៥៤ នាទី)*

[១០:៥៤:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម ហើយសូមជម្រាបសួរដល់អស់លោកទាំងអស់នៅក្នុង និងនៅខាងក្រៅសាលសវនាការ។ ប្រហែលជាយើងបានសង្កេតឃើញហើយនៅព្រឹកនេះខ្ញុំបានដកខ្លួនចេញពីសាលសវនាការដោយសារខ្ញុំត្រូវទៅជួបកូនក្តីរបស់ខ្ញុំលោក អៀង សារី ដែលនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម។ នៅក្នុងសម្រេចរបស់អង្គជំនុំជម្រះ E254/3 បាននិយាយថា ក្នុងករណីដែលមានការព្រួយបារម្ភទាក់ទងសុខភាពលោក អៀង សារី ត្រូវស្វែងរកការជួយពីផ្នែកសុខភាពគឺចុះថ្ងៃ១២ ខែ១២ ឆ្នាំ២០១២។ ហើយវាមានការថតក៏ដូចជាទាក់ទិនទៅនឹងការថតសំឡេងនៃការសង្កេតរបស់យើងខ្ញុំបាននិយាយជាមួយវេជ្ជបណ្ឌិត ហើយខ្ញុំនឹងដាក់នូវការកត់ត្រានេះចូលទៅក្នុងសំណុំរឿង។

[១០:៥៦:១០]

ខ្ញុំចុះទៅក្រោមទៅជួបលោក អៀង សារី ហើយបានជួបជាមួយវេជ្ជបណ្ឌិត ហើយផ្អែកទៅតាមការសម្រេចរបស់អង្គជំនុំជម្រះគឺថា ហោចណាស់ក៏ត្រូវជួបជាមួយវេជ្ជបណ្ឌិតដើម្បីស្វែងរកឲ្យឃើញថាដើម្បីឲ្យមានជួយផ្នែកវេជ្ជសាស្ត្រទៅដល់កូនក្តីរបស់ខ្ញុំ។

បន្ទាប់ពីបានជួបជាមួយវេជ្ជបណ្ឌិត ហាក់ ដូចជាបង្ហាញថា លោក អៀង សារី ហាក់ ដូចជាមិនមានបញ្ហាអ្វីនោះទេ។ ប៉ុន្តែប្រសិន បើយើងមើលឲ្យច្បាស់លាស់គឺហាក់ដូចជាមិនអាចតាមដាននូវកិច្ចសវនាការនោះទេ។ ហើយនៅពេលដែលខ្ញុំសួរវេជ្ជបណ្ឌិតថាតើគាត់អាចបញ្ចេញមតិយោបល់ដែរឬ

ទេ? គាត់បានបង្ហាញថា លោកវេជ្ជបណ្ឌិត បានឆ្លើយថានេះមិនមែនជាការងាររបស់គាត់ឡើយ ហើយវេជ្ជបណ្ឌិតមិនមានតួនាទីក្នុងការធ្វើការសម្រេច។ ប៉ុន្តែអ្វីៗដែលវេជ្ជបណ្ឌិតបានសរសេរ គឺថាលក្ខណៈសំខាន់ទាំងអស់របស់លោក អៀង សារី គឺមិនមានបញ្ហាអ្វីនោះឡើយ។ ដូច្នេះបញ្ហាសំខាន់គឺថាតើលោក អៀង សារី អាចតាមដានកិច្ចដំណើរការនីតិវិធីដែរឬទេ ប៉ុន្តែគាត់និយាយថា គាត់ទៅនោះគឺដើម្បីត្រួតពិនិត្យសុខភាព។ ខ្ញុំនិយាយជាមួយលោក អៀង សារី ហើយបានសួរលោក អៀង សារី ថាតើគាត់ ចង់លះបង់សិទ្ធិមិនចូលរួមដោយផ្ទាល់ដែរឬទេ? ព្រោះថាតាមគំនិតរបស់យើងគឺថាគាត់មិនអាចតាមដានកិច្ចដំណើរការនីតិវិធីបាននោះឡើយ។ គាត់បានបញ្ជាក់ថា "គាត់មិនមានបញ្ហាអ្វីទេ ដែលនៅខាងក្រោមនោះ"។ ប៉ុន្តែខ្ញុំបកស្រាយថា គាត់ហាក់បីដូចជាមិនច្បាស់អំពីអ្វីនោះទេ ព្រោះគាត់មិនបានស្នើសុំឲ្យមានការបញ្ឈប់សវនាការនោះឡើយ។ ដូច្នេះបានន័យថា គាត់បានលះបង់សិទ្ធិសម្រាប់សវនាការជាក់លាក់មួយនេះ។

[១០:៥៨:១៩]

អ្វីដែលយើង ព្រួយបារម្ភហើយខ្ញុំត្រូវតែបញ្ជាក់នូវការជំទាស់របស់ខ្ញុំចំពោះគំនិតដែលថា ដែលរាយការណ៍ថា បញ្ហាស្ថានភាពទាំងអស់របស់គាត់គឺមិនមានបញ្ហាអ្វី ហើយយើងបកស្រាយថា បកស្រាយនេះថាមានន័យថា គាត់អាចតាមដានកិច្ចដំណើរការនីតិវិធី។

ចំពោះវេជ្ជបណ្ឌិតដែលមិនអាចផ្តល់មតិយោបល់បានទៅលើបញ្ហានេះ យើងគួរតែរកវេជ្ជបណ្ឌិតដទៃដែលអាចមានលទ្ធភាពផ្តល់ដើម្បីជំនួសវេជ្ជបណ្ឌិតនេះ។ នៅពេលដែលយើងទទួលបានរបាយការណ៍សុខភាពនៅពេលព្រឹក លោកវេជ្ជបណ្ឌិតនេះហាក់ដូចជា ផ្អែកតាមការណែនាំរបស់អង្គជំនុំជម្រះ។ វេជ្ជបណ្ឌិតនេះហាក់ដូចជាមិនបានផ្តល់ព័ត៌មានអ្វីថ្មី ឬក៏សំខាន់ទៅអង្គជំនុំជម្រះនោះឡើយ។ លោក អៀង សារី គាត់មានការអស់កម្លាំង ហើយត្រូវការនូវអុកស៊ីហ្សែនជំនួយ។ នេះគឺជាគំនិតរបស់ខ្ញុំដែលមិនមែនជាអ្នកជំនាញខាងវេជ្ជសាស្ត្រនោះឡើយ។

ខ្ញុំសូមបញ្ជាក់ដើម្បីជាការកត់ត្រា ហើយខ្ញុំសូមស្នើអង្គជំនុំជម្រះថា ប្រសិនបើមានវេជ្ជបណ្ឌិតនៅខាងក្រោមជាមួយ លោក អៀង សារី យើងមិនគួរយកវេជ្ជបណ្ឌិតដែលមិនអាចសម្រេចបានអំពីស្ថានភាព ឬក៏មិនអាចវាយតម្លៃអំពីស្ថានភាពរបស់លោក អៀង សារី នោះទេ។ ដូច្នេះរបាយការណ៍របស់វេជ្ជបណ្ឌិតដែលថា ស្ថានភាពរបស់លោក អៀង សារី មិនមានបញ្ហា ហើយអាចតាមដានកិច្ចដំណើរការនីតិវិធីនោះគឺជាការបោកបញ្ឆោតជាការកុហក ជាការបោកប្រាស។

[១១:០០:០២]

ដូច្នេះហើយ ខ្ញុំសូមអភ័យទោសដែលខ្ញុំចំណាយពេលវេលារបស់ព្រះរាជអាជ្ញា ប៉ុន្តែជាការពិតទៅ គឺលោក អៀង សារី បានលះបង់សិទ្ធិមិនចូលរួម ទោះបីថាគាត់មិនមានបញ្ហាក្នុងការតាមដានពីខាងក្រោមនោះឡើយ។ ដូច្នេះ យើងស្នើថា អ្វីៗឲ្យវាបន្តទៅមុខ ហើយលោក អៀង សារី ឥឡូវនេះកំពុងត្រូវការនូវអុកស៊ីហ្សែន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកសហព្រះរាជអាជ្ញាមានមតិយោបល់អ្វីទេ លើការលើកឡើងនិងបង្ហាញអំពីបញ្ហាសុខភាពរបស់លោក អៀង សារី ដោយមេធាវីរបស់គាត់នេះ?

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន តើខ្ញុំអាចបញ្ជាក់បានទេអំពីគោលជំហររបស់ព្រះរាជអាជ្ញា ទាក់ទងទៅនឹងឱកាសកន្លងមកដែលយើងគាំទ្រទៅដល់ព័ត៌មានជាក់លាក់ដើម្បីផ្តល់ដល់អង្គជំនុំជម្រះទាក់ទងទៅនឹងបញ្ហាមួយនេះ។ តើខ្ញុំអាចបញ្ចេញមតិយោបល់ទាក់ទងនឹងបញ្ហានេះបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

[១១:០១:២០]

**លោក ឃីត រេយ៉ន័រ៖**

សូមអរគុណលោកប្រធាន ឥឡូវនេះខ្ញុំសូមបន្តការបទបង្ហាញទៅឆ្នាំ៧៥ ថ្ងៃ១៧មេសា ១៩៧៥ E3/118។ ភាសាអង់គ្លេសមានលេខ 00166972 អ្វីដែលខ្ញុំចង់អាននៅត្រង់ចំណុចនេះគឺជាការផ្សាយសំឡេងនៅពេលព្រឹកថ្ងៃ១៧ មេសា ៧៥ ដោយវិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា។ នេះគឺជាការផ្សាយនៅម៉ោងដំបូងនៃការផ្សព្វផ្សាយនៅថ្ងៃទី១៧ មេសា ៧៥។ អត្ថបទព័ត៌មានពិសេស គឺនៅក្នុងប្រអប់ ក្រហមបានសរសេរដូចតទៅនេះ “នៅព្រឹកថ្ងៃទី១៧ មេសា ៧៥ នៅម៉ោងប្រាំបួនសាមសិបនាទីយើងបានរំដោះទីក្រុងភ្នំពេញជាស្ថាពរ។ ក្រោយពីការវាយប្រហារផ្ទួនៗប្រកបដោយជោគជ័យលើទីក្រុងភ្នំពេញពីគ្រប់ទិសទី ខាងជើងយើងមកដល់ភ្នំពេញ ខាងកើតយើងបានមកដល់សាលាបច្ចេកទេសមិត្តភាពកម្ពុជា-សូវៀត។ ចំណែកខាងត្បូងគឺយើងមកដល់ចំការមន គឺវិមានរដ្ឋ ហើយនិងខាងកើតយើងបានគ្រប់គ្រងដល់ជ្រោយចង្វាទាំងស្រុងតែម្តង។ គឺថាកម្លាំងខ្មាំងបានបែបខ្ចាត់ខ្ចាយអស់ ហើយនៅថ្ងៃ

១៧មេសា យើងបន្តមកដល់ក្រសួងព័ត៌មាន ហើយនិងក្រសួងការពារជាតិ ព្រមទាំងអគ្គសេនាធិការកងទ័ពនៅចំការមន"។ នៅក្នុងឯកសារដដែល E3/118 ភាសាអង់គ្លេសមានលេខ 00166973 គឺមានអត្ថបទនៃការផ្សព្វផ្សាយនៅថ្ងៃ១៧មេសា ៧៥ ដែលពេលព្រឹក ហើយនិយាយអំពីអ្នកស្នេហាជាតិ ដែលស្នើសុំឲ្យមាន។ នេះគឺជាការផ្សព្វផ្សាយទាក់ទងទៅនឹងក្រុមមហានិកាយ សម្តេចសង្ឃមហានិកាយ។ "ខ្ញុំជាសង្ឃនាយកមហានិកាយសូមបិណ្ឌបាតដល់អ្នកប្រយុទ្ធ ក៏ដូចជាទាហានខ្មែរសាធារណរដ្ឋ ក៏ដូចជាទាហាន ខ្មែរក្រហម សូមមេត្តាបញ្ឈប់ការវាយប្រហារ ហើយខ្ញុំសូមឲ្យមេបញ្ជាការទាំងសងខាងចូលរួមការប្រជុំគ្នាដើម្បីជាប្រយោជន៍ ហើយចូលរួមប្រជុំនៅថ្ងៃ១៧ មេសា ៧៥ នៅម៉ោងដប់មួយដើម្បីស្វែងរកសន្តិភាពសម្រាប់ប្រជាជនកម្ពុជាចាប់ពីឥឡូវនេះតទៅ"។ ហើយ២នាទីក្រោយការផ្សព្វផ្សាយនេះ គឺមានការផ្សព្វផ្សាយបន្តទៅទៀត។ "អាត្មាភាពជាសម្តេចសង្ឃនៃគណៈធម្មយុត្ត សូមបិណ្ឌបាតដល់គ្រប់ភាគីទាំងអស់មេត្តាឈប់ បញ្ឈប់ ការបង្ហូរឈាមប្រជាជនកម្ពុជានៅពេលឥឡូវនេះតទៅ"។

[១១:០៥:០០]

ហើយនៅក្នុងរបាយការណ៍ ហ្វីប៊ីស ដដែលនេះគឺនៅព្រឹកថ្ងៃទី១៧ មេសា ដដែល ភាសាអង់គ្លេសមានឯកសារលេខ 00166976 គឺមិនមានខ្មែរ មិនមានការបកប្រែ អ៎! មានការបកប្រែជាភាសាខ្មែរគឺមានលេខ 00846158។ នេះគឺជាការផ្សព្វផ្សាយរបស់រណសិរ្ស វិទ្យុសំឡេងជាតិកម្ពុជា ហើយផ្សព្វផ្សាយដូចតទៅនេះ "ព័ត៌មានពិសេស៖ យើងបានរំដោះភ្នំពេញទាំងស្រុងនៅព្រឹកថ្ងៃទី១៧ មេសា ៧៥ នៅម៉ោងប្រាំបួនសាមសិបនាទី យើងបានរំដោះភ្នំពេញជាស្ថាពរ។ ក្រោយពីការវាយប្រហារផ្ទួនៗប្រកបដោយជោគជ័យលើទីក្រុងភ្នំពេញពីគ្រប់ទិស កងកម្លាំងប្រជាជនរបស់យើងកំពុងគ្រប់គ្រង និងកាន់កាប់គ្រប់ទីតាំងសំខាន់ៗរបស់ខ្មាំងនៅទីក្រុងភ្នំពេញ"។ នៅក្នុងឯកសារដដែល គឺភាសាអង់គ្លេសមានលេខ 00166974 ប៉ុន្តែមិនមានការកបប្រែជាភាសាខ្មែរ ឬបារាំងនោះទេ គឺរបាយការណ៍ ហ្វីប៊ីស គឺនៅថ្ងៃ១៧ មេសា ៧៥ ដដែលបាននិយាយដូចតទៅនេះ "ដោយផ្អែកទៅលើការអំពាវនាវរបស់សម្តេចសង្ឃទាំងពីរគណៈ ហើយនិងដោយសារតែមិនមានគណៈកម្មាធិការអចិន្ត្រៃយ៍ -- ឧត្តមក្រុមប្រឹក្សាអចិអន្ត្រៃយ៍ ហើយដោយសារតែមិនមានរដ្ឋាភិបាលសាធារណរដ្ឋខ្មែរនោះ ដើម្បីបញ្ឈប់ការបង្ហូរឈាមរបស់ប្រជាជនកម្ពុជា ខ្ញុំឧត្តមសេនីយ៍ ម៉ី ស៊ីចាន់ ស្នើសុំដល់កងកម្លាំងប្រដាក់អាវុធទាំងអស់ ក៏ដូចជាអគ្គសេនាធិការមេត្តាបញ្ឈប់នូវការវាយប្រយុទ្ធទាំងកងទ័ពជើងទឹក ជើងគោក និងជើងអាកាស និងការបញ្ឈប់ការបង្ហូរឈាមគ្នាចាប់ពីពេលនេះតទៅ។ ហើយយើងអញ្ជើញឲ្យតំណាងគ្រប់ភាគីទាងអស់មក

ចូលរួមនៅទីក្រុងភ្នំពេញ និងនៅតាមទីរួមខេត្តនានា ដើម្បីពិភាក្សា"។

[១១:០៧:៤៥]

ដូច្នេះ នេះគឺជាការអំពាវនាវរបស់ឧត្តមសេនីយ៍នៃរបបសាធារណរដ្ឋខ្មែរ ដើម្បីអញ្ជើញដល់តំណាងខាងខ្មែរក្រហមមកចូលប្រជុំនៅទីក្រុងភ្នំពេញ។ នៅអត្ថបទនៅទំព័រដដែលនេះ គឺជាការប្រកាសក្រោយពីការប្រកាសមុននេះ៧នាទី ដែលជាការប្រកាសដោយមិនមានចេញឈ្មោះ គឺជាតំណាងកងទ័ពប្រជាជនរំដោះជាតិកម្ពុជា ដែលមិនបានចេញឈ្មោះ ហើយនៅក្នុងការផ្សព្វផ្សាយនេះបានផ្សព្វផ្សាយដូចតទៅ "ខ្ញុំសូមជម្រាបដល់អាក្បត់ លន់ នល់ ហើយនិងមេបញ្ញាការរបស់វា ដែលថាយើងហ្នឹងមិនមកចរចាជាមួយពួកវាឡើយ។ យើងកំពុងតែវាយចូលទីក្រុងភ្នំពេញ"។ ហើយនៅទំព័រដដែល គឺជាការផ្សព្វផ្សាយមួយទៀត ដែលនិយាយអំពី ដែលជាការផ្សព្វផ្សាយប្រហែលជា១នាទី ១ម៉ោងក្រោយនោះ គឺជាការផ្សព្វផ្សាយដោយវិទ្យុក្នុងស្រុកកម្ពុជា។ ហើយនៅក្នុងការផ្សព្វផ្សាយនេះ គឺយើងមិនអាចកំណត់ថាអ្នកណាជាអ្នកផ្សព្វផ្សាយបាននោះទេ គ្រាន់តែបញ្ជាក់ថាជាទាហានខ្មែរសាធារណរដ្ឋ។ "ទាហានបានសម្រេចដាក់អាវុធចុះ ហើយនិងចុះចាញ់ចំពោះរណសិរ្សរួបរួមជាតិកម្ពុជា ចំពោះកងទ័ពប្រជាជនរំដោះជាតិកម្ពុជាដែលបានចូលមកដល់ទីក្រុងភ្នំពេញ"។

[១១:០៩:៣៥]

ជាបន្តទៀត ខ្ញុំសូមទៅឯកសារ E3/2864 គឺមានភាសាខ្មែរលេខ 00712054, ភាសាបារាំងគឺមានលេខ 00391422, និងភាសាអង់គ្លេសគឺមានលេខ 00710311។ នេះគឺជាឯកសារដែលជាការទាក់ទងតាមរយៈទីក្រុងបាងកក តាមរយៈទីភ្នាក់ងារសារព័ត៌មានបារាំង ដែលរាយការណ៍ពីការសង្កេតរបស់អ្នកសារព័ត៌មានបារាំង ហ្សង់-ហ្សាក់ កាហ្សូ ដែលខ្ញុំបានបញ្ជាក់រួចមកហើយនៅការពីពេលមុននេះនៅក្នុងរបាយការណ៍ហ្វីប៊ីស ហើយលោក ហ្សង-ហ្សាក់ បានផ្ដល់នៅព័ត៌មាននេះ។ នេះគឺជាការរៀបរាប់អំពីអ្វីដែលបានកើតឡើង មិនមែនត្រឹមតែថ្ងៃ១៧ មេសា ទេ ប៉ុន្តែរៀបរាប់ពីអ្វីដែលកើតឡើងបន្តបន្ទាប់។

ខ្ញុំសូមអានទូវរបាយាការណ៍របស់លោក ហ្សង់-ហ្សាក់ "ថ្ងៃព្រហស្បតិ៍ ទី១៧ មេសា ម៉ោង ០៧:៣០៖ ទង់ជ័យពណ៌សត្រូវបានបង្ហូតឡើងនៅលើសសរបង្គោលនានា នៅក្នុងមូលដ្ឋានទ័ពជើងទឹកជ្រោយចង្វារដែលស្ថិតនៅទល់មុខនឹងចំណុចកណ្ដាលទីក្រុង និងលើស្ទើរកោះមួយដែលកកើតចេញពីទន្លេមេគង្គ និងទន្លេសាប។ ក្រុមខ្មែររំដោះក្រហមដំបូង គេមកដល់ដែនស្ពានទូតបារាំងតាមភាគខាងជើងនៃ

ទីក្រុងម៉ោងប្រាំបីសាមសិបនាទី។ នៅកណ្ដាលក្រុងភាគខាងត្បូងបក្ខពួកខ្មែរក្រហមដែលបានលបចូលមកច្រើនថ្ងៃហើយនោះ បានដកហូតអាវុធទាហានសាធារណរដ្ឋដំបូងៗ ដោយទាហានទាំងនោះបានទម្លាក់អាវុធចុះដោយគ្មានប្រតិកម្ម។ ម៉ោង០៩:២០នាទី៖ កូនប្រុសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមួយរូបឈ្មោះ ហែម កេតដារ៉ា អាយុ២៩ឆ្នាំ បានកោះអញ្ជើញអ្នកកាសែតបារាំងនានាទៅ ក្រសួងព័ត៌មាន។ ហែម កេតដារ៉ា បានបញ្ជាក់ថា ខ្លួនបានយកទីក្រុង -- យកបានទីក្រុងជាមួយនិងចំនួន សមាជិកចលនាជាតិប្រហែល២០០នាក់។ ចលនានេះ មិនត្រូវបានស្គាល់តែសោះ"។

[១១:១២:១៤]

លោកប្រធាន លោក លោកស្រីចៅក្រម តើខ្ញុំអាចបញ្ជាក់បានដែរឬទេថា ហើយខ្ញុំសូមបញ្ជាក់ថា យើងនឹងមានបញ្ចាខ្សែវីដេអូ នៅពេលក្រោយនេះ ហើយវីដេអូនេះ គឺបានបង្ហាញអំពីបុរសម្នាក់ដែលយើងធ្លាប់ឃើញជាញឹកញាប់ដែលថា នៅក្នុងរូបភាពគាត់កាន់កាំភ្លើងខ្លីមួយនៅឈរកណ្ដាលផ្លូវនៅទីក្រុងភ្នំពេញ។ គេគិតថា គាត់នេះជាសមាជិកខ្មែរក្រហម ប៉ុន្តែតាមពិតទៅគាត់ដូចជាមិនមែនទេ។ បុរសនេះគាត់ឈរកាន់កាំភ្លើងខ្លី ហើយប្រហែលជាបុរសនេះហើយ គឺជាមនុស្សដែលមានឈ្មោះថា ហែម កេតដារ៉ា ដែលជាកូនប្រុសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមួយរូបនោះ នៃរបបសាធារណរដ្ឋខ្មែរ។ ហើយគាត់បាននិយាយកុហកអ្នកសារព័ត៌មាន ដែលថាគាត់យកបានទីក្រុង។

[១១:១៣:១៤]

ឥឡូវនេះ ខ្ញុំសូមបន្តទៅទៀត ដោយអានន្ទូវអត្ថបទបន្ត។

"ម៉ោង១០:០០៖ រថពាសដែកដែលស្ថិតនៅមុខវត្តភ្នំ និងលើមហាវិថីមុនីវង្សបានលើកទង់ជ័យ-ស និងផ្កាអាម៉ង់។ រថពាសដែកទាំងនោះ ត្រូវបានបក្សពួករបស់ ដារ៉ា ហ៊ុមព័ទ្ធជុំវិញ។ ការរាប់រកគ្នាជាបងប្អូនក៏បានចាប់ផ្ដើម"។ ហើយយើងនឹងមានបង្ហាញរូបភាពនេះនៅក្នុងខ្សែវីដេអូដែលយើងនឹងបង្ហាញនៅពេលក្រោយ។ "ប្រជាជនក៏បានសើចសប្បាយរីករាយ និងបានទទួលអ្នករំដោះទាំងនោះយ៉ាងកក់ក្ដៅ។ មានក្បួនដង្ហែនៅគ្រប់ពាសពេញទីក្រុង។ បរិយាកាសនៃពិធីបុណ្យជួយសង្គ្រោះប្រជាជនបានបន្តរហូតដល់ជិតពេលថ្ងៃត្រង់"។

នៅទំព័រដែលជាភាសាខ្មែរ និងទំព័រដែលជាភាសាអង់គ្លេស ចំណែកអង់គ្លេសមានលេខ 00710312។ ឥឡូវនេះ យើងសូមបន្តទៅម៉ោងពីរ ប៉ុន្តែជារបាយការណ៍របស់ ហ្សង់-ហ្សាក់ ដដែល។ "បរិយាកាសនៅក្នុងទីក្រុងបានផ្លាស់ប្ដូរ ខ្មែរក្រហមដែលទទួលការស្វាគមន៍ ឥឡូវនេះបានជំនួសដោយ

ម៉ូណាទីអូ ហើយបានគ្រប់គ្រងតាមផ្លូវ។ ទាហានៗកងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានមកដល់ពីខាងជើងតាមផ្លូវជាតិលេខ៥ ហើយមានប្រដាប់អាវុធយ៉ាងពេញ ហើយអ្នកដទៃទៀត គឺមកពីខាងកើតដោយជិះកប៉ាល់មកពីកងកម្លាំងជើងទឹក។ ម៉ោង០៣:០០៖ ខ្សែទូរស័ព្ទនិងខ្សែទូរសារបានផ្ដាច់ មន្ត្រីរដ្ឋាភិបាលសាធារណរដ្ឋបានមកដល់ក្រសួងព័ត៌មានដើម្បីចុះចាញ់”។ ហើយវីរបុរសដែលបានបង្ហាញពីពេលគឺលោក ហែម កេតដារ៉ា ហ្នឹង គឺមានបង្ហាញរូបភាពនៅខាងក្រោយ។ “នៅម៉ោង០៣:៣០រសៀល៖ ភាគខាងជើងទាំងស្រុងនៃទីក្រុងបានចុះចាញ់ ហើយប្រជាជននៅក្នុងតំបន់នេះត្រូវបានគេបញ្ជាឲ្យចាកចេញពីទីក្រុងភ្នំពេញ។ ម៉ោង០៤:៣០នាទីល្ងាច៖ នាយករដ្ឋមន្ត្រី ឡុង បូរ៉េត គឺនៅក្នុងការិយាល័យរបបសាធារណរដ្ឋបានចុះចាញ់ ហើយគាត់គឺជាមន្ត្រីចុងក្រោយគេដែលបានចុះចាញ់ជាមួយនឹងអាជ្ញាធរដែលបានរង់ចាំគាត់នៅក្រសួងព័ត៌មាន។ ព្រះអង្គម្ចាស់សិរិមតៈ ទទួលបានការផ្ដល់អនុគ្រោះនៅស្ថានទូតបារាំង”។

[១១:១៦:១០]

លោកប្រធាន លោក លោកស្រីចៅក្រម យើងបានទទួលឯកសារពាក់ព័ន្ធទៅនឹងលោក សិរិមតៈ ដែលនិយាយអំពីការជ្រកកោនរបស់គាត់នៅទូតបារាំង ហើយយើងបាននិយាយ -- ហើយយើងក៏មានឯកសារដែលនិយាយអំពីព្រះអង្គម្ចាស់ សិរិមតៈ បានចាកចេញពីស្ថានទូតបារាំង។ បន្តទៅទៀតនេះនៅម៉ោង០៥:០០ល្ងាច៖ កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានបញ្ជាឲ្យមានការជម្លៀសចេញពីសណ្ឋាគារភ្នំ នៅក្នុងរយៈពេលកន្លះម៉ោង។ នៅម៉ោង០៥:៤៥៖ ជនបរទេស អ្នកសារព័ត៌មាន និងតំណាងកាកបាទក្រហម អង្គការសហប្រជាជាតិត្រូវបានបង្ខំឲ្យចាកចេញពីសណ្ឋាគារភ្នំ ហើយនិងជ្រកកោននៅតាមស្ថានទូត។

ហើយបន្តទៅទៀតនេះគឺមិនមានឯកសារជាភាសាខ្មែរទេ ប៉ុន្តែអង់គ្លេសមានលេខ 00010312 ហើយភាសាបារាំងគឺមានលេខ 00391423 គឺជារបាយការណ៍របស់ ហ្សង់ហ្សាក់ ដដែល។ “ម៉ោង០៦:០០៖ របាំងដែលបិទបាំងស្ថានទូតត្រូវបានគេលើកឡើង ហើយច្រកចូលស្ថានទូតត្រូវបានបិទ។ ប្រជាជនកម្ពុជាបានលោតរំលងរបង ហើយនិងលោតកាត់ខ្សែលួស ហើយនិងបោះនូវវ៉ាលីសចូលទៅក្នុងរបងទាំងអស់នោះ។ សួនច្បារនៅក្នុងស្ថានទូតគឺត្រូវបានពេញទៅដោយប្រជាជន។ ជនភៀសខ្លួនបានចាកចេញពីទីក្រុងភ្នំពេញដោយដើរ ហើយធ្វើដំណើរទៅខាងជើង។ ពួកគាត់ដើរកាត់ស្ថានទូតកងកម្លាំង កងទ័ពប្រជាជនរំដោះជាតិកម្ពុជា ដោយមានចងក្រមានៅលើក្បាលផង ហើយមានប្រដាប់

ដោយកាំភ្លើងបាសាកា ហើយនិងអាកា៤៧ បានធ្វើដំណើរមកពីភាគខាងជើងនៃទីក្រុង។ អ្នកជម្លៀសបានដើរនៅខាងស្តាំដៃនៃមហាវិថីក្នុងពេលដែលពួកទាហានខ្មែរក្រហមដើរនៅខាងឆ្វេង។ ពួកគេមិនបាននិយាយទាល់តែសោះ។ ទីក្រុងទាំងមូលគឺស្ងាត់ជ្រងំ។ "នៅម៉ោង០៨:០០ល្ងាច៖ ប្រជាជន ២០០នាក់បានជ្រកកោននៅក្នុងស្ថានទូត ហើយពាក់កណ្តាលនៃពួកគាត់គឺជាជនជាតិខ្មែរ ដែលមានប្រភពដើមជាជនជាតិចិន ឬក៏វៀតណាម"។

[១១:១៩:០៧]

ឥឡូវនេះខ្ញុំសូមអនុញ្ញាតដល់ខាងអេ.វី ខាងសោតទស្សន៍ដើម្បីចាក់បញ្ចាំងនូវខ្សែវីដេអូទី២ ដែលនិយាយអំពីខ្មែរក្រហម ហើយនេះជាការដកស្រង់ដ៏មានរយៈពេលជាង២នាទី ឯកសារមានលេខ D108/32.2R។ ហើយជាឯកសារ៩៨៨ ខ្ញុំនឹងបញ្ជូនឯកសារនេះទៅដល់ភាគីនានា ដើម្បីឲ្យភាគីនានាដែលបានទទួល ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅពេលនេះ។ ខ្ញុំក៏សូមបញ្ជាក់ថា ក្នុងឯកសារវីដេអូទី១ដែលខ្ញុំបានចាក់គឺជាការអត្ថាធិប្បាយ ប៉ុន្តែការអត្ថាធិប្បាយនេះវាមានបន្ថែមលើអ្វីដែលនិយាយអំពីទួលពោធិ៍ជ្រៃ។ ដូច្នេះខ្ញុំគិតថាវាមិនជាការត្រឹមត្រូវនោះទេ ដែលខ្ញុំត្រូវបង្ហាញវីដេអូនេះ ដែលមានសំឡេងព្រោះថាអ្នកសារព័ត៌មានគាត់អាចស្នើឲ្យមានការបកប្រែតាមវិធីសាស្ត្ររបស់គាត់ ប៉ុន្តែវាហាក់ដូចជាការបន្ថែមឲ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរ។ ហើយដោយសារហេតុផលទាំងអស់នេះ ខ្ញុំសូមអនុញ្ញាតថាផ្នែកនេះគឺសូមមេត្តាចាក់ដោយមិនបញ្ចេញសំឡេង។ ដូច្នេះសូមអនុញ្ញាតដល់ខាងសោតទស្សន៍ចាក់នូវវីដេអូលេខ២ ដែលថា "ប៉ុល ពត គឺជាអ្នកសម្លាប់"។

**ប្រធានអង្គជំនុំ៖**

បុគ្គលិកផ្នែកសោតទស្សន៍ ចាក់ផ្សាយនៅលើអេក្រង់ទូរទស្សន៍ និងកំព្យូទ័រនូវរូបភាព និងវីដេអូតាមសំណើសុំរបស់លោកលោកតំណាងសហព្រះរាជអាជ្ញា។

[១១:២១:០៨]

*(ការបង្ហាញឯកសារជាវីដេអូលេខ២)*

[១១:២៣:៣៦]

**លោក ឃីត វេយ៉ន័រ៖**

សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅឯកសារ E3/2687 ភាសាខ្មែរមានលេខ 00490992, ភាសាបារាំងគឺមានលេខ 00391430។ នេះគឺជាទូរលេខដែលបញ្ជូនទៅ និងចេញពីស្ថានទូតបារាំងនៅ

ក្នុងប្រទេសកម្ពុជា។ នេះគឺជាទូរលេខដែលផ្ញើចេញពីក្រសួងការបរទេសនៅក្នុងទីក្រុងប៉ារីស ផ្ញើមកស្ថានទូតបារាំងនៅទីក្រុងភ្នំពេញ ហើយនិយាយអំពីសិរិមតៈ។ ហើយយើងបាននិយាយពីដើមរួចមកហើយថា សិរិមតៈ ត្រូវបានផ្ដល់នូវការជ្រកកោនផ្នែកនយោបាយ។ ហើយក្នុងបញ្ហានេះ គឺនៅចំណុចកណ្ដាលបានសរសេរដូចតទៅនេះ គឺនិយាយអំពីសិទ្ធិជ្រកកោន "ដែលហៅថាសិទ្ធិជ្រកកោនមិនត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ និងដោយសារដំណើរបេសសកម្មរបស់លោកមានលក្ខណៈពិសេសនោះ ដូច្នេះ យើងមិនអាចទទួលយកសំណើសុំទាំងឡាយរបស់អ្នកអង្គម្ចាស់ ស៊ីសុវត្ថ សិរិមតៈនិងលោក អ៊ុំ ប៊ុនហូ ឬអ្នកដទៃទៀត ដែលមានវត្តនៅស្ថានទូតក្នុងស្ថានភាពដូចគ្នានោះបានទេ។ សូមលោកមេត្តាជូនដំណឹងដល់អ្នកទាំងនោះថា យើងពុំអាចផ្ដល់នូវការការពារណាមួយដូចអ្វីដែលពួកគេចង់បាននោះឡើយ។ នៅក្នុងកាលៈទេសៈបែបនេះ ពួកគេទាំងអស់នោះ អាចទទួលបានផលប្រយោជន៍ ប្រសិនណាជាពួកគេស្វែងរកជ្រកកោននៅទីកន្លែងដទៃទៀត ហើយត្រូវចាកចេញជាបន្ទាន់អំពីរង្វង់ដែនដីនៃស្ថានទូតរបស់យើងដោយគ្មានលក្ខខណ្ឌ"។

[១១:២៥:៤៦]

បន្តទៅទៀតនេះ ខ្ញុំសូមបន្តទៅឯកសារ E3/51 នេះគឺជាឯកសារដែលមាននៅក្នុងសំណុំរឿង គឺជាប្រមូលផ្ដុំនូវអត្ថបទរបស់អ្នកកាសែតនៅក្នុងទីក្រុងឡុងដុង។ ឯកសារដែលខ្ញុំនឹងអានបន្តទៅទៀតនេះ គឺជារបាយការណ៍អំពីការសង្កេតឃើញដោយផ្ទាល់របស់អ្នកសារព័ត៌មានអង់គ្លេស គឺលោក ហ្សង់ ស្វេន។ ជាដំបូង ខ្ញុំសូមអាននូវផ្នែកមួយដែលជាភាសាខ្មែរមានលេខ 00644712 ដល់ 707, ភាសាបារាំង គឺមានលេខ 00597831 ដល់ 32 និងភាសាអង់គ្លេសគឺមានលេខ 00003277។ ឯកសារនេះ គឺនិយាយអំពីម៉ោង១១ នៅថ្ងៃទី១៧ មេសា ៧៥ ហើយខ្ញុំសូមដកស្រង់ដូចតទៅនេះ៖ "ម៉ោង១១ ព្រឹក៖ រហូតមកដល់ពេលនេះ ការដើរនៅជុំវិញតំបន់ខ្លះក្នុងទីក្រុងភ្នំពេញ ហាក់ដូចជាមានសុវត្ថិភាពជាងមុន។ កងទ័ពខ្មែរក្រហមដែលបានកាន់កាប់ទីក្រុងភ្នំពេញបានទាំងស្រុង ហាក់ដូចជាមានកន្លែងកក់ក្ដៅគ្រប់គ្រាន់។ ខ្ញុំរួមទាំងមិត្តភក្តិមួយចំនួនទៀត បានដើរទៅកាន់ក្រសួងព័ត៌មាន កន្លែងដែលយើងបានស្ដាប់ថាមានមេដឹកនាំខ្មែរក្រហមជាច្រើនបានប្រមូលផ្ដុំគ្នានៅទីនោះ។ យើងត្រូវបានស្វាគមន៍ដោយក្រសែភ្នែកដែលបង្ហាញពីភាពចង់ដឹង ចង់ឮ។ នៅទីធ្លាខាងក្រៅអគារ ដែលសាងសងឡើងតាមរចនាបទបារាំង យើងឃើញបុរសវ័យក្មេងម្នាក់ស្លៀកសម្លៀកបំពាក់ខ្មៅ រូបរាងសង្ហា និងមានមុខស្រួចឈរនៅវាលស្មៅខាងមុខ។ បុរសម្នាក់នោះ បានណែនាំខ្លួនក្នុងសំនៀងជាភាសាបារាំង ថាគាត់ឈ្មោះ ហែម កេតដារ៉ា

ជាកូនប្រុសអតីតរដ្ឋមន្ត្រីមួយរូប។ លោក ដារ៉ា បានប្រាប់ទៀតថា លោកគឺជាគណៈមេបញ្ជាការដឹកនាំចលនាជាតិនិយម ដែលបានរំដោះទីក្រុងភ្នំពេញ”។

[១១:២៨:១៧]

យើងបន្តទៅកថាខណ្ឌបន្តទៀត “បុរសរូបរាងសង្ហាស្លៀកពាក់ហ៊ឺហាម្នាក់នេះ មិនគួរឲ្យជឿថាជាអ្នកបដិវត្តន៍សោះ។ ហើយវាកាន់តែពិបាកជឿទៅទៀត ថាលោកត្រូវគ្នានឹងចលនាដ៏តឹងរ៉ឹងរបស់ខ្មែរក្រហម។ គ្រប់ពេលបុរសម្នាក់នោះ តែងតែបញ្ជាកូនទាហានក្មេងៗដែលស្លៀកពាក់ឯកសណ្ឋានខ្មៅ ឲ្យដើរចុះដើរឡើងជុំវិញអគារ និងនៅស្ងៀមមួយកន្លែង។ នៅពេលដែលកូនទាហានទាំងនោះ ប្រឆាំងម្តងហើយម្តងទៀត បុរសម្នាក់នេះ នឹងក្រវីកាំភ្លើងតាមពួកហ្វូលីវូត ដើម្បីបញ្ជាក់ឲ្យពួកគេដឹងថា ពួកគេត្រូវតែគោរពតាមបញ្ជារបស់លោក”។ នៅក្នុងប្រអប់ក្រហមដដែលនេះ “ខ្ញុំបានកាន់កាប់ទីក្រុងភ្នំពេញដោយមានកូនទាហានតែ៣០០នាក់ប៉ុណ្ណោះ។ គាត់បានលើកឡើងដោយមោទនភាព។ បន្ទាប់មកទៀតលោកបានបណ្តេញពួកយើងចេញពីកន្លែងនោះ ដោយគ្រវីកាំភ្លើងរបស់លោកមកកាន់ពួកយើង។ លោកបានប្រាប់ពួកយើងឲ្យស្តាប់តាមការប្រកាសវិទ្យុ។ លោកនិយាយថា ទីក្រុងភ្នំពេញត្រូវតែរៀបចំឡើងវិញ មុនពេលលោកអ្នកអាចបញ្ជូនសំបុត្រចេញក្រៅ។ អាការៈរបស់ពួកគាត់ និងកូនទាហានរបស់គាត់បង្ហាញពីភាពក្លែងក្លាយមួយ។ ពួកគេមានរូបរាងស្អាតបាត និងរាក់ទាក់ពេក រហូតធ្វើឲ្យពួកយើងមិនជឿថា អ្នកទាំងនេះជាខ្មែរក្រហមមកពីភ្នំពេញពិតប្រាកដនោះឡើយ”។

[១១:២៩:៤៨]

ហើយបន្ទាប់មកទៀត នៅក្នុងប្រអប់ក្រហមបន្ទាប់ នៅទំព័របន្ទាប់។ ភាសាខ្មែរមានលេខ 0064496 (ស៊ីក) គឺបាននិយាយថា “បើតាមការសន្និដ្ឋាន លោក ដារ៉ា និងក្រុមរបស់គាត់ ជាជនឱកាសនិយមដែលបានវិនិច្ឆ័យខុសអំពីលក្ខណៈពិតប្រាកដរបស់ខ្មែរក្រហម”។ ត្រង់ចំណុចនេះខ្ញុំសូមអនុញ្ញាតឲ្យខាងសោតទស្សន៍ចាក់នូវវីដេអូ លេខ៣គឺជាការដកស្រង់ចេញពីឯកសារដែលមានចំណងជើងថា “កម្ពុជាឆ្នាំសូន្យ” គឺជាឯកសារដែលមានរយៈ១នាទី ២៧វិនាទី គឺឯកសារ D108/32R សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បុគ្គលិកផ្នែកសោតទស្សន៍ចាក់ផ្សាយនូវវីដេអូនៅលើអេក្រង់ទូរទស្សន៍ទៅតាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា។

[១១:៣២:៤៥]

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនតំណាងសហព្រះរាជអាជ្ញាមានការក្រោកឈរឡើងរបស់មេធាវីការពារក្ដី លោក ខៀវ សំផន ។ សូមអញ្ជើញលោកស្រីមេធាវី។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រមជាទីគោរព និងភាគី។ ខ្ញុំសុំស្នើបំភ្លឺមួយនៅពេលដែលសហព្រះរាជអាជ្ញាបានចាក់ផ្សាយសម្រង់វីដេអូលើសពី -- យោងអត់បាន បង្ហាញ គាត់អត់បានបង្ហាញពីនាទីណាដល់នាទីណាទេ អ៊ីចឹងសូមឲ្យគាត់បង្ហាញនាទីផង លោកប្រធាន។ សូមអរគុណ។

**លោក ឃីត វេយ៍ន័រ៖**

គឺថាមានកំណត់ត្រា ខ្ញុំសុំឲ្យបង្ហាញពេលវេលានៅលើឯកសារនេះដើម្បីបង្ហាញជូនទៅភាគីទាំងអស់នៅថ្ងៃរសៀលនេះ។ ខ្ញុំនឹងបង្ហាញថាតើវីដេអូនេះដកស្រង់ចេញមកពីណា ហើយពេលវេលាដែលត្រូវកាត់មក កាត់តនេះនៅម៉ោងប៉ុន្មានដែរ ហើយជាផ្នែកណានៃខ្សែវីដេអូអ្វីនោះ? ខ្ញុំអត់មានពេលវេលាដែលត្រូវបង្ហាញអំពីការកាត់តនៃខ្សែវីដេអូនេះបានទេ នៅពេលនេះ តែសុំនៅពេលរសៀល។

[១១:៣៤:១០]

ឥឡូវយើងនៅតែលើឯកសារ E3/51 ដដែលពី ចន ស្វេន ERN ជាភាសាខ្មែរ 00644704, ភាសាបារាំង 00597832 ហើយអង់គ្លេស 00003277។ “នៅម៉ោង១២:៣០នាទីរសៀល៖ នេះជាពេលវេលាដ៏ក្ដៅគគុក ហើយក៏ថ្ងៃដែលប្រជាជនរាប់រយនាក់ដែលកំពុងប្រឈមមុខនឹងការស្លាប់ដោយគ្មាននរណាដឹងនៅក្នុងមន្ទីរពេទ្យព្រះកេតុមាលា។ គ្រូពេទ្យមិនបានរាយការណ៍អំពីការងាររបស់ខ្លួនរយៈពេល២ថ្ងៃមកហើយមិនមានអ្នកណាថែទាំអ្នករបួសចំនួន២.០០០នាក់ នៅក្នុងមន្ទីរពេទ្យនេះឡើយ”។

នៅក្នុងឯកសារដដែលនេះ នៅថ្ងៃរសៀល ERN ជាភាសាខ្មែរ 00644709, បារាំង 00597835, អង់គ្លេស 00003278។ “នៅម៉ោង០៣:៣០នាទីរសៀល៖ ទាហានម្នាក់ក្នុងចំណោមទាហានមួយចំនួនបានដោះលែងពួកយើង ហើយប្រគល់របស់របរមួយចំនួនមកយើងវិញ។ យើងបានបើកសំដៅទៅក្រសួងព័ត៌មានដែលយើងយល់ថានឹងមានការប្រឈមមុខគ្នានៅទីនោះ។ “នៅម៉ោង០៤:០០រសៀល៖ រហូតមកដល់ពេលនេះវាជាឈុតឆាកមួយផ្សេងពីពេលព្រឹក។ លោក តារា ដែលស្លៀកពាក់ឆើតឆាយក៏

ស្ថិតនៅទីនេះ ប៉ុន្តែមិនមែនជាទាហានដូចកាលពីមុនឡើយ។ លោកគ្មានកាំភ្លើងផ្ទាល់ខ្លួន ហើយក៏ក្លាយជាអ្នកទោសពាក់កណ្តាលហើយដែរ។ លោកហាក់ដូចជាអស់កម្លាំង ហើយមានអារម្មណ៍មិនស្រួលសោះ។ មានអ្នកទោស៥០នាក់ កំពុងឈរតម្រង់ជួរនៅខាងមុខអគារ។ អ្នកទាំងនោះរួមមានលោក លន់ នន់ ជាប្អូនប្រុសរបស់លោក លន់ នល់ និងជាមនុស្សម្នាក់ទៀត ក្នុងចំណោមពួកជនពុករលួយគួរឲ្យស្អប់ខ្ពើមបំផុតពីរបបចាស់ ក្នុងនោះក៏មានឧត្តមសេនីយមួយឈ្មោះ ហ៊ូ ហង់សិន ប្រធានខុទ្ទការល័យរបស់លោក ឡុង បូរ៉េត ផងដែរ។ ទោះបីយ៉ាងណានាយករដ្ឋមន្ត្រីមិនមានវត្តមាននៅទីនោះទេ។ មិនមានអ្នកណាម្នាក់ដឹងច្បាស់ថាតើលោកកំពុងស្ថិតនៅទីណានោះទេ”។

[១១:៣៧:០៧]

ហើយនៅក្នុងប្រអប់ខាងក្រោម “ឥឡូវនេះមេដឹកនាំនិយាយទៅកាន់អ្នកទោស គាត់បានប្រាប់ពួកគេថាមានពួកក្បត់តែប្រាំពីរនាក់ប៉ុណ្ណោះ ហើយអ្នកទាំងនោះមិនអាចចាត់ទុកខ្លួនឯងថាជាអ្នកទោសដែលចាប់បានឡើយ។ ប៉ុន្តែពួកគេបែរជាទុកខ្លួនឯងថាជាអ្នកចុះចាញ់ទៅវិញ។ មេដឹកនាំរូបនោះបានសន្យាមិនសងសឹកអ្វីឡើយ”។

ខ្ញុំសូមចូលឯកសារ E3/2689 ERN ជាភាសាខ្មែរ 00490995, បារាំង 00391434, ហើយអង់គ្លេស 00486884 ជាសារទូរលេខមកពីឯកអគ្គរដ្ឋទូតស្ថានទូតបារាំងផ្ញើជូនក្រសួងការបរទេសបារាំងនៅទីក្រុងប៉ារីស ដែលនិយាយអំពីព្រឹត្តិការណ៍ថ្ងៃ១៧ មេសា ៧៥។ ហើយសារទូរលេខនេះគឺសរសេរដូចតទៅ “កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជាបានប៉ុនប៉ងចូលស្ថានទូតចំនួនបីដង ដើម្បីធ្វើការឆែកឆេរ។ ខ្ញុំសូមឲ្យលោករដ្ឋមន្ត្រីមេត្តាធ្វើអន្តរាគមន៍ជាបន្ទាន់។ ខ្ញុំនិយាយថា នេះជាហេតុការណ៍ដែលយើងចង់ឲ្យគោរពដល់អព្យាក្រឹតភាពនៃស្ថានទូត។ មានអំពើប្លន់ជាច្រើនកើតឡើងនៅក្នុងទីក្រុង សូមឲ្យទាក់ទងជាមួយអាជ្ញាធរថ្មី ឲ្យមានផ្តល់នូវសន្តិសុខឲ្យបានត្រឹមត្រូវដល់ជនរួមជាតិរបស់យើង”។

[១១:៣៩:០៤]

ឯកសារបន្ទាប់គឺ E3/2688 ជាសារទូរលេខមួយទៀត នេះជាសារទូរលេខគ្របដណ្តប់ព្រឹត្តិ-ការណ៍ ១៧មេសា ដែរ គឺនិយាយអំពីស្ថានភាពនៅក្នុងទីក្រុងភ្នំពេញ។ ERN ជាភាសាខ្មែរ 00490993 ហើយខ្លឹមសារនៃសារទូរលេខគឺនិយាយថា “ស្ថានភាពនៅទីក្រុងភ្នំពេញវេលាម៉ោងម្ភៃមួយ នៅរំលងអធ្រាត្រទាហានរបស់រណសិរ្សរួបរួមជាតិកម្ពុជាហ្នឹង បានចល័តនៅតាមវិថីសំខាន់ៗក្នុងទីក្រុង ដោយបានស្រែកបញ្ជាតាមឧគ្ឃោសនស័ព្ទឲ្យប្រជាជនទាំងអស់ មិនថាសញ្ជាតិអ្វីឡើយឲ្យជម្លៀសខ្លួនចេញពី

ក្រុងភ្នំពេញជាបន្ទាន់ក្នុងចម្ងាយ១៥គីឡូម៉ែត្រ ដោយពួកគេប្រកាសថាទីក្រុងត្រូវប្រឈមមុខនឹងការបំផ្លិចបំផ្លាញដោយការទម្លាក់គ្រាប់បែក។ សេចក្តីប្រកាសនេះគឺមានការភ័យខ្លាចទូទៅនៅក្នុងស្រទាប់មហាជន។ មានមនុស្សជិត ១.០០០នាក់បានផ្តោះរបងរត់ចូលជ្រកកោននៅក្នុងបរិវេណស្ថានទូតរបស់យើង"។ ហើយនៅក្នុងប្រអប់ក្រហមបន្ទាប់គឺ ERN ខ្មែរ 00490994 ដែលនិយាយថា "ទាហានក៏បានចូលមកកន្លែងមន្ទីរពេទ្យកាល់ម៉ែតរបស់យើង ហើយថែមទាំងបានប៉ុនប៉ងជម្លៀសបុគ្គលិក និងអ្នកជំងឺចេញពីមន្ទីរពេទ្យនោះទៀតផង"។

[១១:៤១:០៥]

ឯកសារបន្ទាប់ E3/2696 នេះជាសារទូរលេខផ្ញើចេញពីស្ថានទូតបារាំងនៅភ្នំពេញទៅ ជូនទៅក្រសួងការបរទេសបារាំងនៅទីក្រុងបារីស ដែលរួមមានរបាយការណ៍ ដែលស្នើសុំឱ្យបញ្ជូនទៅសារព័ត៌មានឡឺម៉ុងដ៍ ហើយសម្រង់គឺនៅក្នុងខ្មែរ 00491977 "ប្រជាជននៅទីក្រុងភ្នំពេញបានទទួលបញ្ជាឱ្យចេញក្រៅទីក្រុងភ្នំពេញក្នុងកម្រិតចម្ងាយមួយ ហើយដើម្បីឱ្យដោះ បញ្ហាដើម្បីដោះស្រាយបញ្ហាស្បៀងអាហារ។ ចុងក្រោយដែលជាការធ្វើបដិវត្តន៍មួយពិបាកសម្រាប់របបសាធារណរដ្ឋ។ ដំបូងពួកទាហានៗដែលជាអ្នកស្រែចម្ការមានវ័យក្មេងៗមិនធ្លាប់ស្គាល់ទីក្រុង ឬអារម្មណ៍ថាវង្វេង មានចិត្តខ្វល់ខ្វាយ។ ចំនួនកម្មាភិបាលតិចតួច តែសង្កេតមើលការរៀបចំ និងគម្រោងរៀបចំជាបែបផែន។ បរិយាកាសប្រែប្រួលនៅថ្ងៃរសៀល ដែល -- ហើយក៏ចាប់មានសេចក្តីសម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញបានកើតឡើងដល់ទៅបួនដង"។

[១១:៤២:៥៨]

សម្រង់បន្ទាប់មកទៀតនៅទំព័រខ្មែរ 00491278, បារាំង 00391444 "នៅព្រឹកថ្ងៃព្រហស្បតិ៍មានតែក្រុមយើងដែលបានធ្វើ ប្រហែល៤០គីឡូម៉ែត្រចេញពីទីក្រុងតម្រង់ទៅទិសពាយ័ព្យ។ យើងបានឃើញប្រជាជនមានសេចក្តីរីករាយខ្លាំងរកពណ៌នាមិនបាន ហើយយើងឃើញមានវត្តមានរបស់បារាំងជូរទាហានហែរវែងអន្លាយប្រដាប់ដោយអាវុធនៅសហរដ្ឋអាមេរិកដើរតម្រង់ទៅភ្នំពេញ។ យើងឃើញមានអង្គភាពយោធានៅក្នុងស្ថានភាពពណ៌ខ្មៅ ទិដ្ឋភាពតំបន់រំដោះមានការប្រែប្រួល"។ ហើយបន្ទាត់ក្រហមបន្ទាប់មកទៀតនៅទំព័រដដែល "នៅពេលវិលត្រឡប់មកវិញនៅថ្ងៃ ព្រឹកថ្ងៃព្រហស្បតិ៍ យើងត្រូវបានគេឃាត់រាប់ម៉ោងមុននឹងត្រូវទៅកាន់ក្រសួងព័ត៌មាន ដើម្បីធ្វើការអំពាវនាវតាមវិទ្យុរកអ្នកទទួលខុសត្រូវនៃរបបសាធារណរដ្ឋ។ បរិយាកាសធូរស្បើយ អ្នកទោសសើចសំណេះសំណាលជាមួយអ្នក

ទទួលមុខមាត់ លន់ នល់ ឧត្តមសេនីយ៍ជាច្រើនរូប និង ឡុង បូរ៉េត។

[១១:៤៣:៥៤]

ប្រអប់ក្រហមចុងក្រោយនៅក្នុងឯកសារជាភាសាខ្មែរនិយាយអំពីសារទូរលេខដដែលនេះ “ការរង់ចាំមកដល់នៃអ្នកដឹកនាំរដ្ឋាភិបាលក្នុងពេលឆាប់ៗខាងមុខ មិនដឹងថាអង្គាល់ទ្រង់ សីហនុ ត្រឡប់មកវិញ ឬ ខៀវ សំផន ប្រហែលជាមកដល់ហើយ។ នៅទីបញ្ចប់ការជម្លៀសប្រជាជនឆាប់រហ័សដូចជានៅមានការបារម្ភខ្លះៗនៅព្រឹកថ្ងៃសុក្រ នៅទីក្រុងហូថាន(តាមសំឡេងបកប្រែ) បរិយាកាស និងភាពតានតឹង”។

ខ្ញុំសូមចូលទៅឯកសារ E3/684 បាទ E3/2684 មិនមានការបកប្រែជាភាសាខ្មែរទេ និងជាបារាំង ERN 00391423 ខ្ញុំសូមចូលទៅអ្នកកាសែតឈ្មោះ ហ្សង់-ហ្សាក់ កាហ្សូ ដដែល ដែលបន្តអំពីការវិវត្តន៍នៃព្រឹត្តិការណ៍ថ្ងៃនោះនៅថ្ងៃ១៧ មេសា។ យើងនិយាយពីថ្ងៃ១៨ មេសា ៧៥ ហ្សង់-ហ្សាក់ កាហ្សូ ខ្លួនឯងបានរាយការណ៍ដូចតទៅនេះ “ការជម្លៀសប្រជាជនគឺបន្តធ្វើទៅភាគខាងជើង ទៅទិសខាងជើងដោយមានប្រដាប់អាវុធនៅជុំវិញទីក្រុងភ្នំពេញ។ នៅម៉ោង០៩:០០ព្រឹក៖ ព្រឹត្តិការណ៍ទី១ គឺលោកបានកត់ត្រាពាក់ព័ន្ធទៅនឹងការឡោមព័ទ្ធផ្ទះ ដោយពួកទាហានប្រជាជនរំដោះជាតិខ្មែរក្រហមមកពីជនបទ។ ផ្ទះទាំងអស់ត្រូវបានបើក ហើយនិងបោសសម្អាតទាំងស្រុង យោងទៅតាមដំណើររឿងដដែលផ្ទះជាច្រើនគឺត្រូវបានគេដុតដោយការបោះគ្រាប់បែកដើម្បីដុតផ្ទះទាំងនោះ។ នៅម៉ោង១០:០០ព្រឹក៖ មានការទាក់ទងជាមួយនឹងទីប្រឹក្សាស្ថានទូតឈ្មោះ ហ្សង់ហ្សេរ៉ាក់ ដែលទាក់ទងជាមួយនឹងអាជ្ញាធរយោធាដែលគ្រប់គ្រងទីក្រុង ដែលថាស្ថានទូត គឺថាមានការរំលោភមកដល់ស្ថានទូតនេះ។ នៅម៉ោង០១:០០រសៀល៖ វេជ្ជបណ្ឌិតជនជាតិបារាំងនៅមន្ទីរពេទ្យកាល់ម៉ែត ត្រូវបញ្ជាឲ្យចេញពីបន្ទប់វះកាត់។ នៅម៉ោង០១:៣០រសៀល៖ បន្ទាប់ពីការនិយាយគ្នាបីម៉ោង ស្ថានទូតបារាំងឥឡូវនេះគឺថាត្រូវចាត់ទុកថាតំបន់មានសុវត្ថិភាពអន្តរជាតិតែម្តង ប៉ុន្តែកុងស៊ុលស្ថានទូតបារាំងនេះគឺផ្តល់នៅបញ្ជីប្រជាជនទាំងអស់ ដែលត្រូវជ្រកកោននៅស្ថានទូត។ នៅក្នុងដំណើរការនេះ ជនជាតិខ្មែរទាំងអស់ដែលស្ថិតនៅក្នុងស្ថានទូតបារាំងត្រូវតែចេញពីបរិវេណស្ថានទូត”។

ឯកសារបន្ទាប់នេះ គឺនិយាយពីថ្ងៃ១៨ មេសា គឺ E3/2694 សូមកែប្រែ 2692 ដែលមាន ERN ជាភាសាខ្មែរ 00490997 ជាសារមកពីកុងស៊ុលស្ថានទូតបារាំងនៅទីក្រុងភ្នំពេញទៅកាន់ក្រសួងការបរទេសបារាំងនៅទីក្រុងប៉ារីស ដែលនិយាយអំពីស្ថានភាពនៅទីក្រុងភ្នំពេញនៅម៉ោងដប់សាបនាទីព្រឹក

នៅថ្ងៃទី១៨ មេសា ៧៥ ថ្ងៃសុក្រ។ សារទូរលេខនិយាយដូចតទៅ "មនុស្សមួយចំនួនរបស់ហ្វុង គឺមានវត្តមានជាថ្មីនៅមុខក្លោងទ្វារនៃស្ថានទូត ពួកគេស្នើសុំចូលក្នុងបរិវេណស្ថានទូតរបស់យើង ដើម្បីធ្វើការឆែកឆេររថយន្តរបស់យើង ពួកយើងបានជម្លៀសនៅឧប្បត្តិហេតុយ៉ាងប៉ផាប់ពភីងបំផុត។

[១១:៤៧:៤០]

ឯកសារ E3/2693 ERN ជាភាសាខ្មែរ 00490998 ជាសារទូរលេខនិយាយពីព្រឹត្តិការណ៍ថ្ងៃទី ១៨ មេសា ទាក់ទងទៅនឹងស្ថានទូតបារាំងដែលទាក់ទងទៅនឹងក្រសួងបរទេសបារាំង ដែលនិយាយអំពីស្ថានទូតនៅទីក្រុងភ្នំពេញនៅម៉ោងដប់បួន ថ្ងៃទី១៨ មេសា។ សារទូរលេខនិយាយថា "បន្ទាប់ពីខ្ញុំបានធ្វើសំណើសុំផ្ទាល់ខ្លួនពីព្រឹកមិញនេះ នៅវេលាថ្ងៃត្រង់ខ្ញុំបានទទួលស្វាគមន៍ដំណើរទស្សនកិច្ចរបស់ប្រតិភូបីរូបដែលតំណាងមុខរដ្ឋធានី ដែលមកពី យូអ៊ិនឌីភី, យូនីសេហ្វ កិច្ចសន្ទនា ប្រព្រឹត្តទៅ -- ប្រតិភូនិយាយថា"ទី១ កាជម្លៀសប្រជាជនចេញពីទីក្រុងត្រូវចាត់ទុកជាការចាំបាច់ពុំត្រូវអនុវត្តចំពោះស្ថានទូតជាពិសេសពុំត្រូវអនុវត្តទៅលើជនជាតិបារាំងឡើយ។ ២) ពួកគេសម្តែងនៅការពេញចិត្តជាខ្លាំងចំពោះរដ្ឋាភិបាលបារាំងដែលទទួលស្គាល់រដ្ឋាភិបាលរួបរួមជាតិកម្ពុជា ទទួលស្គាល់រណសិរ្ស និងកងទ័ពរំដោះជាតិ។ ៣) ដើម្បីផ្តល់ហេតុផលសន្តិសុខពួកគេណែនាំឲ្យយើងប្រមូលផ្តុំក្នុងបរិវេណស្ថានទូត ហើយពួកគេធានាផ្តល់នូវការការពារសុវត្ថិភាពដល់ជនជាតិបារាំង ក៏ដូចបុគ្គលិកសុខាភិបាល និងជនជាតិបារាំងទាំងអស់។

[១១:៤៩:០៩]

៤) ពួកគេប្រកាសយ៉ាងច្បាស់ថា នៅក្នុងកាលៈទេសៈទាំងអស់ ពួកគេពុំត្រូវការសេវាសុខាភិ-បាលរបស់យើង ឬគឺត្រូវការការបណ្តុះបណ្តាលណាមួយនោះឡើយ។ ៥) ពួកគេមានការព្រួយបារម្ភចង់ដឹងថា តើមន្ទីរពេទ្យកាល់ម៉ែត មានគ្រូពិនិត្យព្យាបាលកងទ័ពសង្គមចាស់ដែរឬទេ? រួមទាំងទាហានមកពីមកពីរបបសង្គមចាស់ដែរ។ បន្ទាប់ពីសំណើសុំដ៏ទទូចនេះមក យើងត្រូវផ្តល់បញ្ជីអ្នកជំងឺទៅឲ្យពួកគេ។ ៦) មកដល់ចំណុចនេះ ពួកហាក់ដូចជាចាប់អារម្មណ៍ភ្លាមតែម្តង ដោយចង់ទៅទស្សនានៅមន្ទីរពេទ្យកាល់ម៉ែត និងស្ថានទូតរបស់យើង។

ទាក់ទងនឹងបញ្ហា យើងបានឆ្លើយតបទៅគេវិញ ដែលថានឹងផ្តល់បញ្ជីវត្តមានអ្នកទាំងអស់នៅក្នុងរយៈពេល៣ថ្ងៃ ទាំងនៅកន្លែងទាំងពីរ គឺ នៅកាល់ម៉ែត និងស្ថានទូត។ ឯកសារបន្ទាប់គឺ E3/2694 ជាសារទូរលេខមកពីស្ថានទូតបារាំងនៅភ្នំពេញផ្ញើជូនក្រសួងការបរទេសបារាំងនៅប៉ារីស គឺនៅក្នុងប្រអប់

ក្រហមដែលមាន ERN ខ្មែរ 00491363 ដល់ 1364។ នេះជាសារទូរលេខចុះថ្ងៃទី១៨ មេសា ដែលនិយាយអំពីការសុំសិទ្ធិជ្រកកោនខាងនយោបាយ ដែលសារទូរលេខនិយាយដូចតទៅ "បន្ទាប់ពីបានទទួលឱសានវាទនៃប្រតិភូរបស់គណៈកម្មាធិការនៃទីក្រុង ដើម្បីធានាការពារសុវត្ថិភាពជនរួមជាតិយើង ខ្ញុំមានកាតព្វកិច្ចបង្ហាញបញ្ជីឈ្មោះជនទាំងឡាយដែលមានវត្តមាននៅក្នុងស្ថានទូត គឺដែលមានវត្តមាននៅស្ថានទូតដូចតទៅនេះ ទី១ ព្រះអង្គម្ចាស់ទ្រង់ សិរិមតៈ រួមនឹងទាហានរបស់ទ្រង់ពីររូប"។

[១១:៥១:២២]

ហើយនៅប្រអប់ដដែល ហើយយើងបន្ទាប់ពីស្នើសុំឱ្យខ្ញុំផ្ដល់នូវសិទ្ធិជ្រកកោនខាងនយោបាយ យើងខ្ញុំត្រូវបានបង្ខំឱ្យបញ្ជូនឈ្មោះទាំងអស់នេះទៅឱ្យគេក្នុងរយៈពេល ២៤ម៉ោង។ ឯកសារបន្ទាប់មកទៀត E3/2697 និយាយពីព្រឹត្តិការណ៍នៅថ្ងៃដដែល ដើម្បីជាការសង្ខេបឱ្យខ្លី គឺថាខ្ញុំបន្តទៅឯកសារ E3/37691 នេះជាសារទូរលេខមកពីស្ថានទូតបារាំងនៅភ្នំពេញផ្ញើជូនក្រសួងការបរទេសបារាំងនៅទីក្រុងប៉ារីស ចុះថ្ងៃទី១៨ មេសា។

E3/2691សារទូរលេខបានសរសេរដូចតទៅ, នៅ ERN ជាភាសាខ្មែរ 00490996 "ស្ថានភាពនៅទីក្រុងភ្នំពេញនៅថ្ងៃ១៨ មេសា នៅម៉ោងប្រាំបី មនុស្ស១លាននាក់កំពុងភៀសខ្លួនចេញ អ្នកជំងឺបានចាកចេញពីមន្ទីរពេទ្យកាល់ម៉ែត ទាំងនៅលើគ្រែរបស់ខ្លួន។ ខ្ញុំមានអារម្មណ៍ខ្លាចស្ថានទូតជួបជោគវាសនាអាក្រក់"។

ឯកសារបន្ទាប់គឺ E3/51 ជាការចងក្រងនូវសម្រង់សារព័ត៌មាននៅពេលនោះ ERN ជាភាសាខ្មែរ 00644713, បារាំង 003568 (ស៊ីក), អង់គ្លេស 00003279។ នេះជាអត្ថបទព័ត៌មានរបស់អ្នកសារព័ត៌មានរបស់អ្នកសារព័ត៌មានដែលដកស្រង់និយាយអំពីទុក្ខវេទនាដ៏ធ្ងន់ធ្ងរនៃការជម្លៀសប្រជាជនចេញពីទីក្រុងនៅថ្ងៃទី១៨ មេសា គឺរាយការណ៍នៅម៉ោងប្រាំពីរព្រឹក។ កងទ័ពខ្មែរក្រហមកំពុងជម្លៀសប្រជាជនចេញពីទីក្រុងទាំងអស់ និងពីទីមន្ទីរពេទ្យនានា។

[១១:៥៤:១១]

អ្នកជំងឺប្រៀបបាននឹងសំរាមដែលគេបោះចោលនៅតាមដងផ្លូវ បុរសស្ត្រីដែលកំពុងរុំរបួសបានដើរទ្រេតទ្រោតទៅកាន់ស្ថានទូតបារាំង។ ភរិយាបានគ្រាប្ដីរបស់ខ្លួនដែលជាទាហានរងរបួសចុះចេញពីគ្រែពីមន្ទីរពេទ្យដាក់លើរទេះរុញ ហើយអ្នកជំងឺមួយចំនួនកំពុងព្យួរសេរ៉ូមជាប់នៅដៃនៅឡើយ។ ក្នុងសង្គ្រាមរយៈពេល៥ឆ្នាំនេះជាទុក្ខវេទនាដ៏ធ្ងន់ធ្ងរបំផុត នៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែល

ធ្លាប់បានជួបប្រទះ។ ខ្មែរក្រហមត្រូវតែដឹងថា អ្នករបួសមួយចំនួនក្នុងចំណោម២០.០០០នាក់ត្រូវការការសង្គ្រោះ។ គេអាចសន្និដ្ឋានថា ពួកខ្មែរក្រហមគ្មានសភាវគតិជាមនុស្សឡើយ។ ទីក្រុងទាំងមូលកំពុងក្លាយជាកន្លែងស្ងប់ស្ងាត់គ្មានមនុស្សរស់នៅ ទោះជាមនុស្សចាស់ ជាអ្នកជំងឺក្តី ជាមនុស្សទន់ខ្សោយ ជាអ្នកអត់ឃ្លាន និងជាក្មេងកំព្រា ក៏ពួកគេមិនត្រូវបានលើកលែងដែរ។

ខ្ញុំសូមឲ្យផ្នែក អេ.វី ចាក់បង្ហាញនូវសេចក្តីសង្ខេបខ្សែវីដេអូ គឺសម្រង់មកពីឯកសារ "កម្ពុជាឆ្នាំសូន្យ" ជាសម្រង់ចេញពីឯកសារ D108--

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធានតាមអត់ទាន់។ ERN ញាប់ពេក។

**លោក ឃឹត វេយ្យន័រ៖**

*(គ្មានការបកប្រែ)*

[១១:៥៦:៣៣]

**ប្រធានអង្គជំនុំ៖**

សូមបញ្ជាក់ម្តងទៀតលោកតំណាងសហព្រះរាជអាជ្ញា លេខERN -- លេខឯកសារអំមិញ គឺអ្នកបកប្រែ បកមិនទាន់ទេ។

**លោក ឃឹត វេយ្យន័រ៖**

សូមអធ្យាស្រ័យ នេះគឺជាវីដេអូដែលមានចំណងជើងថា "កម្ពុជាឆ្នាំសូន្យ ១៥" ជាឯកសារលេខ D108/32.2R ហើយនៅក្នុងឯកសារនេះ ចំណុចទី១ គឺមានចំណងជើងដែលដាក់ថា 1012 សូមឲ្យ អេ.វី ចាក់នៅត្រង់ចំណុចនេះតែម្តង។

**ប្រធានអង្គជំនុំ៖**

សូមបុគ្គលិកផ្នែកសោតទស្សន៍ចាក់ផ្សាយនូវវីដេអូផ្នែកពាក់ព័ន្ធ ទៅនឹងការស្នើសុំលោកតំណាងសហព្រះរាជអាជ្ញា។

[១១:៥៧:៤០]

*(ការបង្ហាញឯកសារជាវីដេអូ "កម្ពុជាឆ្នាំសូន្យ")*

[១១:៥៨:០២]

**លោក ឃីត រេយ៉ន័រ៖**

បាទ គោលបំណងនេះគឺមានមនុស្សពីរនាក់ ដែលអ្នកជំងឺពីរនាក់នៅលើគ្រែ យោងទៅលើខ្សែភាពយន្តឯកសារដែលថតនៅមន្ទីរពេទ្យនោះ។

ឯកសារបន្ទាប់គឺ E3/118 ERN ជាភាសាអង់គ្លេស 00166983 មិនមានការបកប្រែជាភាសាខ្មែរ ជាភាសាបារាំងទេ។ ជារបាយការណ៍របស់ហ្វីប៊ីសៗ ដែលរាយការណ៍ពីអ្នកកាសែតដែលបានមកដល់បាងកក មកតាមជើងហោះហើរមកពីហុងកុង។ "ទាហានខ្មែរក្រហមបានចូលមកដល់មន្ទីរពេទ្យកាល់ម៉ែត ហើយបានអំពាវនាវបានហៅឲ្យបញ្ជាវេជ្ជបណ្ឌិត ឬអ្នកជំងឺចេញមកក្នុងរយៈពេលតែ១ម៉ោង"។ ERN ជាភាសាអង់គ្លេស 001669834 "មន្ទីរពេទ្យកាល់ម៉ែត ដែលក្រុមគ្រូពេទ្យរះកាត់ជនជាតិបារាំងកំពុងតែបំពេញកាតព្វកិច្ចរបស់ខ្លួន គឺត្រូវបានបញ្ជាឲ្យចេញគ្រប់គ្នាទាំងអស់ ទាំងបុគ្គលិកពេទ្យ អ្នកជំងឺ ហើយនិងជនបរទេសមួយចំនួនទៀត ជាពិសេសជាជនជាតិបារាំង"។

[១១:៥៩:៥១]

ឯកសារបន្ទាប់ ខ្មែរ ERN 00664009, បារាំង 00664007, អង់គ្លេស 00445203។ នេះជាអត្ថបទព័ត៌មានរបស់អ្នកកាសែតឡូសអែនជឺឡេស គឺនៅថ្ងៃទី០៨ ឧសភា ៧៥។ ភាសាខ្មែរ 00664010 វេជ្ជបណ្ឌិតជនជាតិបារាំងនិយាយថា "ខ្មែរក្រហមឲ្យជម្លៀសអ្នកជំងឺចេញពីមន្ទីរពេទ្យទាំងអស់ ទោះបីអ្នកនោះឈឺធ្ងន់ធ្ងរ ឬក៏កំពុងរង់ កំពុងតែហៀបនឹងស្លាប់ក៏ដោយ"។

លោកប្រធាន ខ្ញុំសូមបង្ហាញខ្សែវីដេអូខ្លីទេ ដើម្បីឲ្យខាងផ្នែក អេ.វី --

សូមអធ្យាស្រ័យលោកប្រធាន ដោយសារ ថាតើពេលវេលានេះ ល្មមអាចឈប់សម្រាកសិនបាន ឬក៏យ៉ាងណាដែរ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០២:២៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោកប្រធាន បានស្នើសុំឲ្យខ្ញុំធ្វើការកត់ត្រាតាមប្រតិចារឹកអំពីការលះបង់សិទ្ធិជំនួសឲ្យលោក អៀង សារី ដែលធ្វើ ដែលលះបង់សិទ្ធិចូលរួមនៅក្នុងសាលសវនាការ ហើយយើងសូមកត់សម្គាល់ផងដែរថា ក្នុងពេលឥឡូវនេះ គាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម។ លោកប្រធាន ក៏បានស្នើមកខ្ញុំដើម្បីបង្គាប់ដល់វេជ្ជបណ្ឌិតដែលព្យាបាលដើម្បីផ្ដល់នូវព័ត៌មានថ្មីៗផ្នែកសុខភាពឲ្យបានមុនម៉ោងមួយសាមសិបនាទីថ្ងៃនេះ -- ឲ្យបានមុនម៉ោងមួយដប់ប្រាំនាទីថ្ងៃនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀល សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារ។

**លោក ឃីត រេយ៍ន័រ៖**

បាទសូមគោរពលោកប្រធាន! សូមបន្តបង្ហាញឯកសារទាក់ទងទៅនឹងថ្ងៃសុក្រ ទី១៨ មេសា ៧៥ បាទឥឡូវនេះចូលទៅដល់ឯកសារចុះថ្ងៃសៅរ៍ ១៩ មេសា ៧៥។

ឯកសារទី១ គឺ E3/3367 ERN ជាភាសាអង់គ្លេស 00448590 មិនមានការបកប្រែជាភាសាខ្មែរ ភាសាបារាំងទេ។ មានការដកស្រង់ឯកសារនេះដោយសារព័ត៌មានឈីកាហ្គោ នៅថ្ងៃទី១៩ មេសា

៧៥។ ចំណងជើងឯកសារនេះគឺ របាយការណ៍ពាក់ព័ន្ធដែលមានដូចខាងក្រោមនេះ “ខ្មែរក្រហមបានឡោមព័ទ្ធទីក្រុងភ្នំពេញ ហើយមានការរាយការណ៍ថា ជម្លៀសប្រជាជនស៊ីវិលចេញពីទីក្រុងនៃប្រទេសកម្ពុជានេះ។ វិទ្យុផ្សាយសំឡេងរបស់ខ្មែរក្រហម ដែលត្រូវបានតាមដាននៅទីក្រុងបាងកកនោះបានប្រកាសកាលពីថ្ងៃសៅរ៍ថា មេដឹកនាំ កំពូលៗភាគច្រើននៃអតីតរដ្ឋាភិបាលរដ្ឋធានីភ្នំពេញត្រូវបានគេកាត់ក្បាល ត្រូវបានគេកាត់កហើយ”។

ឯកសារបន្ទាប់ គឺE3/118 ERN ជាភាសាអង់គ្លេស 0016988 (ស៊ីក) ជារបាយការណ៍របស់ ហ្វីប៊ីស ដែលរាយការណ៍អំពីសេចក្ដីរាយការណ៍នេះ។ រាយការណ៍អំពីការផ្សាយសំឡេងពីវិទ្យុរបស់កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា ដែលរាយការណ៍នៅក្នុងអត្ថបទដូចខាងក្រោមនេះ៖

[១៣:៣៤:៥៥]

“ជាមហាជ័យជម្នះនៃការរំដោះទីក្រុងភ្នំពេញគឺ ដោយសារតែខ្សែបន្ទាត់បដិវត្តន៍ មាគ៌ាដ៏រឹងមាំនិងកងទ័ពដ៏រឹងមាំរបស់យើង។ កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជាមានការរួបរួមគ្នាយ៉ាងរឹងមាំជាមួយប្រជាជននៅទូទាំងប្រទេស គឺគោលបំណងដើម្បីបណ្ដេញចក្រពត្តិអាមេរិក ហើយនិងកម្ចាត់ពួកអាក្បត់ទាំងប្រាំពីរនាក់ និងកសាងកម្ពុជាថ្មី ដែលឯករាជ្យ សន្តិភាព អព្យាក្រឹត អធិបតេយ្យ ប្រជាធិបតេយ្យ និងមានការជឿនលឿននៅក្នុងបូរណភាពដែនដីរបស់ខ្លួន”។

នៅក្នុងឯកសារដដែល E3/118 ERN ជាភាសាអង់គ្លេស 00166989 នេះជាការផ្សាយបន្ថែមទៀតដោយវិទ្យុផ្សាយសំឡេងរបស់រណសិរ្សរួបរួមជាតិកម្ពុជា គឺ៤នាទីក្រោយពីការផ្សាយមុនដែលខ្ញុំទើបតែអានជូនអម្បាញ់មិញនេះ។ បាទ អត្ថបទរាយការណ៍គឺដូចខាងក្រោម “បន្ទាប់ពីកងទ័ព និងប្រជាជនរបស់យើងបានរំដោះទីក្រុងភ្នំពេញ នៅម៉ោងប្រាំបួន សាមសិបនាទីពេលព្រឹក នៅថ្ងៃទី១៧ មេសា ៧៥ មន្ត្រី បុរស ស្ត្រីនៅតាមបណ្ដាទីរួមខេត្តផ្សេងៗបានដាក់អាវុធរបស់គេចុះ និងសុំចុះចាញ់កងទ័ពរណសិរ្សរំដោះជាតិកម្ពុជា។ ហេតុដូច្នេះឯង យើងបានរំដោះក្រុងកំពង់ចាមនៅថ្ងៃ១៧ មេសា ទីរួមខេត្តបាត់ដំបងនៅថ្ងៃ១៧ មេសា ទីរួមខេត្តកំពង់ស្ពឺនៅថ្ងៃ១៧ មេសា ទីរួមខេត្តស្វាយរៀងនៅថ្ងៃ១៧ មេសា ទីក្រុងកំពតនៅថ្ងៃ១៧ មេសា ក្រុងព្រះសីហនុនៅថ្ងៃទី១៨ មេសា ទីរួមខេត្តតាកែវនៅថ្ងៃ១៨ មេសា ក្រុងកំពង់ធំនៅថ្ងៃ១៨ មេសា និងទីរួមខេត្តកំពង់ចាមនៅថ្ងៃ១៨ មេសា។

[១៣:៣៧:២៤]

បន្ទាប់មកទៀត គឺសេចក្ដីរាយការណ៍នៅថ្ងៃទី១៩ មេសា ដែលឯកសារគឺជាការដកស្រង់ពី

E3/51 ជាកម្រងរបាយការណ៍នាពេលនោះ។ ERN ជាភាសាខ្មែរគឺ 00644720, បារាំង 00597841, អង់គ្លេស 00003280។ នេះជាផ្នែកមួយនៃរបាយការណ៍នាពេលនោះ ដែលមានចំណងជើង “មិនមានតែស្រូវដែលត្រូវបរិភោគតែប៉ុណ្ណោះ ដែលគេរាយការណ៍នៅថ្ងៃ១៩ មេសា នៅម៉ោងប្រាំពីរព្រឹក”។ តាមសំណើរបស់ខ្មែរក្រហម គឺកុងស៊ុលបានរៀបចំបញ្ជីឈ្មោះមនុស្ស ដែលនៅក្នុងបរិវេណស្ថានទូត។ អាមេរិកាំងមានការព្រួយបារម្ភ ដែលមានការភ័យខ្លាចថា ខ្មែរក្រហមនឹងមកចូលយកពួកគេចេញពីស្ថានទូត។ នៅម៉ោង១០:០០ព្រឹក៖ គឺថាមានការភ័យខ្លាច គឺវេជ្ជបណ្ឌិតដែលថាគាត់ត្រូវធ្វើការវះកាត់ទាហានមានរបួសនៅនឹង-កដោយសារតែការប្រយុទ្ធគ្នា។ ទាហានខ្មែរក្រហមបដិសេធមិនឲ្យវេជ្ជបណ្ឌិតនេះប្រើប្រាស់មន្ទីរពេទ្យកាល់ម៉ែតទេ ហើយនិងមន្ទីរពេទ្យរបស់ស្ថានទូតបារាំងនៅជាប់នោះដែរ។

[១៣:៣៩:២២]

នៅទំព័រដដែលភាសាអង់គ្លេស ERN ជាភាសាខ្មែរ 00644722, និងបារាំង 00597842។ ឯកសារនេះគឺនិយាយអំពីអ្នកឈឺនៅម៉ោងបួន -- រាយការណ៍នៅម៉ោងបួនរសៀលអំពីអ្នកជំងឺ។ បុគ្គលិកគឺជនជាតិបារាំងនៅមន្ទីរកាល់ម៉ែតបានមក បានរៀបរាប់អំពីដំណើររឿងដ៏ឃោរឃៅក្នុងរយៈពេល២ថ្ងៃ ពួកគេថាបានវះកាត់ទៅលើពួកកុម្មុយនីស្តដែលរងរបួស ដែលគេឃើញមានយកមកទាំងពីអាវុធផង។ ខ្មែរក្រហមគំរាមកំហែងសម្លាប់ខ្ញុំ បើសិនណាជាខ្ញុំមិនសង្គ្រោះជីវិតរបស់មនុស្សម្នាក់ឈ្មោះ ប៊ុនណាត ពីការនោះទេ។ ដំណើររឿងផ្សេងទៀត ក៏ស៊ីសង្វាក់ទៅនឹងដំណើររឿងនេះដែរ សូមដកស្រង់ “គេភ្ជង់កាំភ្លើងមកក្បាលរបស់ខ្ញុំ ហើយមានទាំងគ្រាប់ផ្លោង ហើយខ្មែរក្រហមបន្ទាប់ពីកម្ទេចចោលនូវថ្នាំពេទ្យទាំងអស់ គឺថាគេជាមួយនឹងបន្ទាប់ពីការបាញ់រះទៅលើរបស់ពួកគេ”។

[១៣:៤០:៥៩]

បាទ សេចក្តីរាយការណ៍ E3/118 ដដែលរាយការណ៍១៩ មេសា ដដែល អង់គ្លេស 00166992 គឺថាមិនមានបកប្រែជាភាសាខ្មែរ ឬអង់គ្លេសទេ ជារបាយការណ៍របស់ហ្វីប៊ីស គឺការកាត់ក្បាល ឡុង បូរ៉េត នៅទីក្រុងភ្នំពេញ អត្ថបទដូចខាងក្រោមនេះ “អតីតនាយករដ្ឋមន្ត្រី ឡុង បូរ៉េត គឺថាគឺត្រូវបានដាក់ទៅក្នុងឧទ្ធម្ភាគចក្រ ហើយត្រូវបានខ្មែរក្រហមចាប់នៅថ្ងៃព្រហស្បតិ៍ យោងទៅតាមទីភ្នាក់ងារយោធាសម្ងាត់របស់ថៃ។ ឡុង បូរ៉េត សម្រេចចិត្តថាចេញពីប្រទេសកម្ពុជា គឺជាសេចក្តីសម្រេចចុងក្រោយ ដោយពេលគាត់ឃើញថា ទាហានឋានៈជាន់ខ្ពស់មួយចំនួនត្រូវបានទាហានខ្មែរក្រហមសម្លាប់នៅមុខក្រសួងការពារជាតិ”។ បានសេចក្តីរាយការណ៍១៩ មេសា ដដែលគឺ E3/2698 សម្រង់ ERN ខ្មែរ

00810736 ជាទូរលេខមកពីស្ថានទូតបារាំងនៅភ្នំពេញទៅកាន់ក្រសួងការបរទេសនិយាយអំពីស្ថានភាពនៅស្ថានទូតរបស់យើង។ បាទ អត្ថបទគឺដូចខាងក្រោម "ចាប់តាំងពីពេលល្ងាចម្សិលមិញស្ថានទូតត្រូវបានឡោមព័ទ្ធដោយកងទ័ពរបស់រណសិរ្សរួបរួមជាតិកម្ពុជា ពុំមាននរណាម្នាក់អាចចូល និងចេញពីរង្វង់ស្ថានទូតដោយគ្មានការអនុញ្ញាតពីពួកគេបានទេ។ គេសង្កេតឃើញមានតែកងទ័ពរបស់ហ្វុង និងសមាសភាពដែលក្តាប់មិនបាន កំពុងតែចល័តចេញពីក្រុងភ្នំពេញ។ យើងបានជួបប្រទះនូវបញ្ហាខ្វះស្បៀងអាហារ ហើយបញ្ហាសុខាភិបាលរបស់ស្ថានទូតនៅកំពុងតែចោទជាបញ្ហា"។ ខ្ញុំសូមសង្កត់ធ្ងន់ទៅលើស្ថានភាពនេះគឺថា ស្ថានភាពមានបញ្ហាធ្ងន់ធ្ងរ។

[១៣:៤៣:៣៧]

បាទ សូមចូលទៅឯកសារដែលបង្ហាញម្តងមកហើយ គឺ E3/2684 បាទ ជាសេចក្តីរាយការណ៍ពី ហ្សង់-ហ្សាក់ កាហ្សូ គឺនិយាយអំពីព្រឹត្តិការណ៍នៅថ្ងៃ១៩ មេសា។ មិនមានការបកប្រែទៅជាភាសាខ្មែរ និងភាសា -- គឺ ERN ជាភាសាអង់គ្លេស 00710314 "១០:00ព្រឹក៖ មានការទាក់ទងរវាងកុងស៊ុលបារាំង ស្ថានកុងស៊ុលបារាំង ឈ្មោះ ហ្សាក់ហ្សេវ៉ាក់ និងគណៈកម្មាធិការទីកក្រុង កុងស៊ុលគឺថាចង់ឲ្យអាជ្ញាធរកងទ័ពដែលគ្របដណ្តប់ទីក្រុងទាំងអស់យល់ឃើញថា ស្ថានទូតមិនត្រូវមានការរំលោភស្ថានទូតឡើយ។ នៅម៉ោង០១:00៖ វេជ្ជបណ្ឌិតជនជាតិបារាំងនៅមន្ទីរពេទ្យកាល់ម៉ែតត្រូវបានគេបញ្ជាឲ្យចាកចេញពីបន្ទប់វះកាត់។ នៅម៉ោងមួយសាមសិបនាទីរសៀល--"

លោកប្រធាន ខ្ញុំសូមចាប់ផ្តើមនៅថ្ងៃទី១៩ មេសា ឡើងវិញម្តងទៀតខ្ញុំអាននូវកាលបរិច្ឆេទខុសទៅវិញទេ។ គឺនៅថ្ងៃសៅរ៍ ១៩ មេសា និយាយពីរបាយការណ៍របស់អ្នកសារព័ត៌មាន ហ្សង់-ហ្សាក់ កាហ្សូ នៅថ្ងៃសៅរ៍ ១៩ មេសា "នៅម៉ោង០៩:00៖ ស្ថានទូតបារាំងហ្នឹងគឺថាមានភាពអាក្រក់ណាស់ ដោយមានពាក្យចចាមអារ៉ាមអំពីការឆក់ លួចឆក់អំពីការចាប់រំលោភ ការដុតឲ្យឆេះ ហើយនិងអំពើហិង្សា និងការសម្លាប់។ នៅម៉ោង -- នោះគឺជនភៀសខ្លួននិយាយអំពី និយាយយ៉ាងខ្សោយៗ ហើយមានដោយលាយឡំដោយទឹកភ្នែក។ នៅម៉ោង០៤:00រសៀល៖ ការផ្គត់ផ្គង់ទឹកនៅក្នុងទីក្រុងត្រូវបានកាត់ផ្តាច់ស្ថានទូតគឺមិនមានទឹកប្រើប្រាស់ទេ។ ប្រជាជនគឺថាត្រូវដោះស្រាយខ្លួនឯងចំពោះបញ្ហាដាំស្ល ហើយនិងត្រូវជីកអណ្តូង"។

[១៣:៤៥:៣៨]

សូមចូលទៅថ្ងៃបន្ទាប់ គឺថ្ងៃអាទិត្យ ទី២០ មេសា។ ឯកសារមួយគឺ E3/2701 ERN ជាភាសា

ខ្មែរ 00492868 ជាទូរលេខមកពីស្ថានទូតបារាំងក្នុងទីក្រុងភ្នំពេញជូនទៅក្រសួងការបរទេសបារាំងនៅទីក្រុងប៉ារីស។ ចំណងជើងគឺ "ស្នើសុំឲ្យមានការជម្លៀសទូទៅជាបន្ទាន់"។ អត្ថបទសារទូរលេខនេះនិយាយថា "អំណឹះតទៅក្នុងទីក្រុងគ្មានមនុស្សមួយរស់នៅទាល់តែសោះ ពោលគឺជាទីក្រុងខ្មោច យើងត្រូវបានគេដាក់ឲ្យនៅដាច់ពីគេ ហើយចាមកាមដោយពួកយោធា គ្មានស្បៀង គ្មានថ្នាំសង្កូវ ហើយស្ថានភាពអនាម័យកាន់តែយ៉ាប់យឺនឡើង។ ភាពជ្រួលច្របល់អាចនឹងកើតមានឡើង ដោយមិនអាចបដិសេធបានក្នុងចំណោមហ្វូងមនុស្សដែលមានវត្តមានក្នុងស្ថានទូត។ មិនមានការទំនាក់អី ក្រៅពីសន្ទនាដ៏កម្រជាមួយអ្នកទទួលខុសត្រូវអនាមិក ដែលមានឋានៈបន្ទាប់បន្សំប៉ុណ្ណោះ។ មិនទំនងជាមានអំណាចនយោបាយ ឬរដ្ឋបាលណាមួយបង្កើតឡើង ឬកំពុងត្រូវបានរៀបចំបង្កើតឡើយ។ អន្តរាគមន៍របស់ប៉េកាំងហាក់ដូចជាមិនមានប្រសិទ្ធភាពឡើយ គ្មានក្ដីសង្ឃឹមទាល់តែសោះក្នុងការត្រឡប់មករកភាពប្រក្រតីវិញ។ ក្នុងអនាគតខាងមុខយ៉ាងខ្លី មានជំនឿជឿជាក់ថា យើងត្រូវមានវត្តមាននៅទីនេះទៀតទេ។ យើងក្លាយជាសាក្សីដែលទើប -- ចំពោះសាក្សីដែលនៅរស់ជាជនជាតិបារាំង និងជនជាតិដទៃនៅក្នុងស្ថានទូតបារាំង ក្រោយពីខ្ញុំពិគ្រោះជាមួយយោបល់ជាអនាមិកនោះ យើងខ្ញុំសូមស្នើឲ្យប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ដើម្បីជម្លៀសទូទៅ និងជាបន្ទាន់។

[១៣:៤៧:៤៥]

ឯកសារបន្ទាប់ទៀត នៅថ្ងៃទី២០ មេសា ដដែល គឺឯកសារ E3/2702 ERN ជាភាសាខ្មែរ 00492870 ទូរលេខបន្ទាប់មកទៀត គឺពីភ្នំពេញ ទៅប៉ារីស នៅថ្ងៃទី២០ មេសា។ កម្មវត្ថុ៖ ការចេញដំណើររបស់ -- ការចាកចេញរបស់ជនភៀសខ្លួន។ អត្ថបទនៃសារទូរលេខនិយាយថា "ទ្រង់សិរិមតៈ និងមនុស្សដែលខ្ញុំរាយការណ៍នៅក្នុងទូរលេខ រាយការណ៍នៅរសៀលនេះ នៅចំពោះមុខគណៈកម្មការអនាមិកមួយ ក្រុមរណសិរ្សរួបរួមជាតិកម្ពុជា ឬក៏កងទ័ពរំដោះជាតិកម្ពុជាដែលបានយករថយន្តហ្ស៊ីបមកទទួលពួកគេនៅមុខខ្លោងទ្វាររបស់ស្ថានទូត។ ជនជាតិកម្ពុជាប្រហែលជា១០០នាក់ទៀត បានប្រុងប្រៀបចូលខ្លួនឲ្យគេចាប់នៅវេលាព្រឹកស្អែក"។

ខ្ញុំសូមឲ្យអង្គភាព អេ.វី បង្ហាញនូវវីដេអូលេខ១១។ វីដេអូមានចំណងជើងថា "កម្ពុជា៖ ប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍" ជាសម្រង់ដែលមានតែ១នាទី និង១២វិនាទី។ និយាយអំពីព្រឹត្តិការណ៍នៅក្នុងស្ថានទូតបារាំង។ លោកប្រធាន លោក លោកស្រីចៅក្រម កាលពីពេល យើងខ្ញុំនឹងផ្ញើអ៊ីម៉ែលមកឲ្យភាគីទាំងអស់នៅរសៀលនេះ ដូចដែលខ្ញុំស្នើសុំនៅពេលមុនពិសាបាយថ្ងៃត្រង់ និយាយ

អំពីប្រភពវីដេអូទាំងអស់នេះ។ ខ្ញុំសូមពេលវេលាពន្យល់អំពីបញ្ហានេះ។ នៅពេលមួយនោះ វីដេអូដែលលោក លោកស្រីត្រូវឃើញនេះ គឺនិយាយអំពីបុរសកម្ពុជាម្នាក់ដកអាវធំរបស់គាត់ប្រុងប្រៀបនៅក្នុងបញ្ហាចូលប្រយុទ្ធក្នុងសង្គ្រាម។ គឺចេញពីខ្សែភាពយន្តនេះ គឺជាទ្រង់ សិរិមតៈ នេះឯង។ អ៊ីចឹងខ្សែវីដេអូលេខ១១ សុំឱ្យអង្គភាពសោតទស្សន៍មេត្តាចាក់ផ្សាយខ្សែវីដេអូលេខ១១នេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ បុគ្គលិកខាងផ្នែកសោតទស្សន៍ចាក់ផ្សាយនូវវីដេអូលើអេក្រង់ទូរទស្សន៍ តាមការស្នើសុំរបស់លោកតំណាងសហព្រះរាជអាជ្ញា!

[១៣:៥០:៣១]

*(ការបង្ហាញឯកសារជារូបភាពវីដេអូ “កម្ពុជា៖ ប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍”)*

[១៣:៥០:៤០]

**លោក ឃីត រេយ៍ន័រ៖**

បាទ ខ្ញុំសូមឱ្យបញ្ឈប់ការចាក់ផ្សាយនេះបន្តិចសិន។ ចំណងជើងសម្រាប់ឃ្លីបវីដេអូនេះគឺ “ប្រទេសកម្ពុជា ប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍” ប្រហែលជាពិបាកនៅក្នុងការរកលេខ ប៉ុន្តែយកចំណងជើងទៅឃើញដាក់ថា “ប្រទេសកម្ពុជា ប្រវត្តិនៃអំពើប្រល័យពូជសាសន៍”។ ឃ្លីបដែលទើបតែចាក់អម្បាញ់មិញនេះ គឺជាសម្រង់ គឺថតមកពីទួលពោធិ៍ជ្រៃដែលខ្ញុំបង្ហាញនៅពេលក្រោយ។ ដំបូងយើងបញ្ចាំងអំពីកម្ពុជា “ប្រវត្តិនៃអំពើប្រល័យពូជសាសន៍”។

លោកប្រធាន លោក លោកស្រីចៅក្រម ខាងសោតទស្សន៍គឺមិនអាចរកឃើញទេ ខ្ញុំសូមការអនុញ្ញាតការបង្ហាញនូវខ្សែវីដេអូនេះ នៅពេលក្រោយវិញ។

ខ្ញុំនៅតែនិយាយពីព្រឹត្តិការណ៍ថ្ងៃទី២០ មេសា E3/2684។ នេះគឺជាសេចក្តីរាយការណ៍របស់ហ្សង់-ហ្សាក់ កាហ្ស។ ERN ជាភាសានេះ 00391426, អង់គ្លេស 0010319 (ស៊ីក)។ នេះគឺជាសេចក្តីរាយការណ៍នៅថ្ងៃទី២០ មេសា ERN ជាភាសាអង់គ្លេស គឺថាដាក់ខុសទេ ដាក់ថា ថ្ងៃ២៨ គឺតាមពិតជាថ្ងៃចន្ទ ទី២០ មេសា។ បាទ រាយការណ៍ដូចខាងក្រោម “គណៈកម្មាធិការទីក្រុងបានចាត់តាំងឆ្មាំពិសេស ដើម្បីឱ្យមើលនៅតំបន់ជុំវិញស្ថានទូតទាំងអស់ ដែលកំពុងតែមានការរំលោភបំពាននេះ”។ កុងស៊ុល ហ្សង់សេរ៉ាក់ នេះ ប្រាប់ប្រជាជនកម្ពុជាថា នេះគឺជាពេលវេលាល្អហើយ ដែលត្រូវតែចាកចេញដើម្បីជៀសវាងកុំឱ្យគេត្រួតពិនិត្យនៅរបងនេះ។ ប្រជាជនកម្ពុជាគឺមានការភ័យខ្លាច ជនជាតិបារាំង

គ្រប់រូប ទាំងប្រុស ទាំងស្រី គឺថាស្នើសុំឲ្យមានការរៀបការ។ នៅម៉ោង០៩:១០ព្រឹក៖ ទ្រង់សិរិមត: ខ្លួនគាត់គឺបាននិយាយទៅកាន់កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជានៅចំពោះមុខស្ថានទូតបារាំង ហើយក៏បានចាកចេញទៅតាមរថយន្តហ្ស៊ីបមួយ។ ប្រធានរដ្ឋសភាក៏ធ្វើដូចគ្នាដែរ។ ឥឡូវនេះ គេយល់ឃើញថាតំណាងរបស់គណៈកម្មាធិការទីក្រុងនឹងបដិសេធមិនផ្តល់ស្បៀងអាហារនិងទឹកមកឲ្យពួកយើងទេ លើកណាតែជនភៀសខ្លួនកម្ពុជានៅក្នុងស្ថានទូតចាកចេញសិន។ ទី១ គឺថាត្រូវតែសម្រេចធ្វើបែបនេះ។ មានការរន្ធត់ញាប់ញ័រយ៉ាងខ្លាំង មានការភ័យខ្លាច ស្រក់ទឹក នៅថ្ងៃទី២០ ហ្នឹង គឺមានដំណើររឿងអំពីការកាប់សម្លាប់យ៉ាងវង្គាលនៅតាមផ្លូវ មានការភ័យខ្លាចយ៉ាងខ្លាំង។ ដុកទ័រមន្ទីរពេទ្យកាល់ម៉ែតក៏មានស្រក់ទឹកភ្នែកចំពោះបញ្ហានេះដែរ។ អ្នកកាសែតបារាំងក៏បានស្នើសុំរៀបការ"។

[១៣:៥៤:៣៦]

បាទ នៅទំព័រនៃឯកសារនេះ ទៅថ្ងៃទី -- សូមតទៅថ្ងៃ២១ មេសា ជាសេចក្តីរាយការណ៍របស់ហ្សង់-ហ្សាក់ កាហ្ស៊ូ ដែរ នៅថ្ងៃចន្ទ ២១ មេសា។ "ម៉ោង០៧:០០ព្រឹក៖ ចំនួនជនភៀសខ្លួនកម្ពុជាយ៉ាងច្រើនបានចេញដំណើរ អ្នកខ្លះមានការភ័យខ្លាចយ៉ាងខ្លាំង ខ្លះអង្វរសុំឲ្យវេជ្ជបណ្ឌិតឲ្យជួយទៅដល់កូនចៅនិងរបស់ពួកគេ និងជួយដល់ពួកគេផង"។

នៅថ្ងៃទី២១ មេសា ដដែលនេះដែរ គឺឯកសារ E3/118 មានការបកប្រែភាសាERN ខ្មែរគឺ 00846160 ដល់ 61, អង់គ្លេស 00166994 នេះគឺជាវិទ្យុផ្សាយសំឡេងដោយ ខៀវ សំផន ទីក្រុងភ្នំពេញ សារនិយាយអំពីជ័យជម្នះ រាយការណ៍ដោយសេវាផ្សាយសំឡេងទីក្រុងភ្នំពេញ ដែលមានចំណងជើងថា "អបអរសាទរជ័យជម្នះដោយ-- រាយការណ៍ដោយឧបនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលរួបរួមជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជាពី ខៀវ សំផន ទៅកាន់អង្គភាពនានានៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជានិងប្រជាជន" ផ្សាយបន្តផ្ទាល់។

[១៣:៥៦:២១]

ខ្ញុំសូមចាប់ផ្តើមជាមួយនឹងកថាខណ្ឌដែលជានៅត្រង់កថាខណ្ឌ២ ប្រអប់ក្រហម "នេះគឺជាជ័យជម្នះដ៏មហាអស្ចារ្យរបស់ប្រជាជនយើង និងប្រជាជាតិយើង។ កងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជាប្រជាជន និងប្រជាជាតិទាំងមូល ក៏ដូចជាប្រជាជនពិភពលោកក្នុងប្រទេសជិតឆ្ងាយទាំងអស់ស្វាគមន៍យ៉ាងកក់ក្តៅចំពោះមហាជ័យជម្នះនេះ។ ជ័យជម្នះនេះបានបើកផ្លូវដ៏ភ្លឺស្វាង និងត្រឹមត្រូវបំផុតក្នុងការដឹកនាំប្រជាជនកម្ពុជា និងកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ក្នុងការកម្ទេចទាំងស្រុង

នូវសង្គ្រាមឈ្លានពានរបស់ពួកចក្រពត្តិ និងវាយខ្ទាំងគ្រប់សមរភូមិ ទាំងផ្នែកយោធា នយោបាយ សេដ្ឋកិច្ច និងក្នុងការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីអូសទាញប្រជាជនចេញពីតំបន់ដែលខ្មាំងកាន់កាប់"។

សូមឱ្យអង្គភាពសោតទស្សន៍មេត្តាចាក់ខ្សែវីដេអូ។ ខ្សែវីដេអូលេខ៧ បាទខ្សែវីដេអូលេខ៧ ហើយក្រោយពីលេខ៧ សូមឱ្យចាក់លេខ៨។

**ប្រធានអង្គជំនុំ៖**

បុគ្គលិកផ្នែកសោតទស្សន៍ ចាក់ផ្សាយវីដេអូតាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១៣:៥៩:១៧]

*(ការបង្ហាញឯកសារជាវីដេអូលេខ៧)*

[១៣:៥៩:៣៥]

**លោក ឃីត វេយ៍ន័រ៖**

ពាក់ព័ន្ធទៅនឹងកាលប្បវត្តិ ខ្ញុំនៅតែបង្ហាញឯកសារថ្ងៃទី២១ ខែមេសា ដដែល។ ឯកសារបន្ទាប់មួយទៀតនោះគឺ E3/2707 ខ្មែរមានលេខ 00492871។ សារទូរលេខបញ្ជូនមកក្រសួងការបរទេសគឺស្ថានទូតបារាំងបញ្ជូនទៅក្រសួងការបរទេសនៅក្នុងប្រទេសបារាំង។ គេបានលើកឡើងថា "មានជនជាតិខ្មែរប្រហែលជាង ១.០០០នាក់ នៅក្នុងឧទ្យាន ឥឡូវនេះដោយដឹងថា គ្មានដំណោះស្រាយអ្វីទៀតក្រៅពីចាកចេញ អ្នកស្ម័គ្រចិត្តមុនគេបានប្រមូលផ្តុំគ្នានៅក្នុងទីធ្លា ហើយត្រៀមខ្លួនទទួលយកជីវិតថ្មីរបស់ពួកគេ ដែលនឹងចាប់ផ្តើមដោយការធ្វើដំណើរថ្មី ថ្មើរជើងលើចម្ងាយផ្លូវដ៏សែនឆ្ងាយ។ ពួកគេទាំងអស់គ្នាកំពុងទទួលរងនូវការឈឺចាប់ដែលមិនអាចទ្រាំទ្របាន អ្នកខ្លះត្រូវបែកគ្នា។ បន្ទាប់ពីមានការឈឺចាប់ យើងឃើញថាមានការបែកខ្ញែកគ្នានេះ មិនអាចទ្រាំបាននោះទេ។ ស្ថានភាពនេះ គឺវាមើលទៅទំនងជាមិនអាចកើតឡើងបាននោះទេ"។ នៅចុងសារទូរលេខនេះ គឺបានសរសេរថា "ម្សិលមិញទារកមួយបានកើតនៅក្នុងស្ថានទូត ម្តាយគេត្រូវចាកចេញពីស្ថានទូតថ្ងៃនេះ។ ក្មេងប្រុសនេះ ក្លាយជាកូនខ្ញុំថ្ងៃនេះ យើងបានយកគេធ្វើជាកូនចិញ្ចឹម"។ សារទូរលេខនេះ បញ្ជូនពីឈ្មោះ ឡឺរ៉ុន ដែលជាសរសេរសារសម្ងាត់ប្រចាំស្ថានទូត។

[១៤:០១:២៤]

នៅពេលនេះ ខ្ញុំសូមបង្ហាញឯកសារចុះថ្ងៃទី២២ ខែមេសា វិញម្តងលោកប្រធាន។ ឯកសារទី១ គឺឯកសារ E3/2714 គឺជាសារទូរលេខភ្នំពេញបញ្ជូនទៅប៉ារីស ដដែលថ្ងៃទី២២ ខែមេសា ខ្មែរលេខ

ERN គឺ 00555739 គឺឯកសារ E3/2714 "ភ្នំពេញគ្មានប្រជាជន រស់នៅ អគារជាច្រើនត្រូវបានដុតបំផ្លាញចោល។ លើសពីការឆក់ប្លន់ទៅទៀត ពួកខ្មែរក្រហមបានធ្វើការបំផ្លាញខ្ទេចខ្ទីនូវរាល់របស់ទ្រព្យនានាដែលតំណាងឲ្យសង្គមមូលធន។ រាល់លំនៅដ្ឋានឯកជន ព្រមទាំងហាងលក់ទំនិញនានាត្រូវបានបំផ្លិចបំផ្លាញ ផ្លូវថ្នល់ពោរពេញទៅដោយសម្ភារៈនានា ដូចជាកម្ទេចកម្ទី ម៉ាស៊ីនចាក់ថាសចម្រៀង ទូរទស្សន៍ ទូរទឹកកក។

[១៤:០២:៣៤]

ផ្ទុយទៅវិញពួកខ្មែរក្រហមប្រមែប្រមូលយកម៉ូតូ កង់ ប្រដាប់ប្រដា នាឡិកា អង្ករ។ ពួកគេក៏បានកម្ទេចរថយន្តនានា ដែលម្ចាស់បានបោះបង់ចោលនៅស្ទើរគ្រប់ទីកន្លែង"។ សារទូរលេខនេះ នៅខាងក្រោមសរសេរថា "កងទ័ពខ្មែរក្រហមមិនថាឋានៈណានោះទេ បានធ្វើដំណើរមកដល់ខេត្តកំពង់ចាមនៅថ្ងៃទី២១ ខែមេសា ដោយធ្វើដំណើរតាមរយៈយន្តហោះ DC-3 ។ ឯកសារមួយទៀត គឺ E3/2715 ខ្មែរ ERN គឺ 00813074 ជាសារទូរលេខផ្ញើពីភ្នំពេញទៅទីក្រុងប៉ារីស។ ចំណងជើងនៅក្នុងនេះសរសេរថា "ជនភៀសខ្លួននៅក្នុងស្ថានទូតបារាំង" ហើយនៅក្នុងនេះសរសេរថា "ស្ថានទូតបារាំង គឺកំពុងតែទុកទីជម្រកឲ្យជនជាតិបរទេសនៅក្នុងនោះ"។ នៅក្នុងប្រអប់ក្រហមសរសេរថា "ខ្មែរក្រហមបានបំបែកជនជាតិបរទេសចេញពីស្វាមី ខ្មែរក្រហមមិនអនុញ្ញាតឲ្យជនជាតិខ្មែរចូលជ្រកកោននៅក្នុងបរិវេណស្ថានទូតឡើយ បុគ្គលិកជាតិនៃស្ថានទូតត្រូវបានពួកខ្មែរក្រហមយកចេញពីស្ថានទូត"។

[១៤:០៤:១៣]

នៅពេលនេះ ខ្ញុំចូលទៅដល់ឯកសារចុះថ្ងៃទី២៦ ខែមេសា ឯកសារលេខ E3/118 គឺជាឯកសារហ្វ៊ីប៊ីស មិនមានការបកប្រែជាភាសាខ្មែរ ឬបារាំងនោះទេ។ អង់គ្លេស ERN គឺ 00167019 នេះគឺជារបាយការណ៍ចេញមកពីសារព័ត៌មានបារាំង ចំណងជើងគឺ "ជនភៀសខ្លួន" និយាយថា "ខ្មែរក្រហម -- ការកាប់សម្លាប់របស់ខ្មែរក្រហមបានចាប់ផ្តើមហើយ"។ សន្តិភាព -- ឯកសារនេះសរសេរដោយ ដែលអង់រី អត្ថបទសរសេរឡើងថា "ខ្មែរក្រហមបានធ្វើការបាញ់ប្រហារទៅលើអ្នកមាន និងអ្នកដែលជាសាសនា យោងតាមជន ភៀសខ្លួន ហើយចាប់ផ្តើមធ្វើការកាប់សម្លាប់។ ការធ្វើការបាញ់ កាប់សម្លាប់នេះគឺជាយន្តការមួយក្នុងរបបបដិវត្តន៍ ដែលត្រូវបានគេបង្កើតឡើងតាមវិធីដ៏លឿនបំផុតមួយ"។

នៅទំព័របន្ទាប់អង់គ្លេស ERN 00167020 ខ្ញុំបន្តអានរបាយការណ៍នេះ "អ្នកជនភៀសខ្លួននិយាយថា ក្រោយពេលជម្លៀសពីភូមិកំណើតរបស់ខ្លួន អ្នកស្រុកត្រូវបានគេសម្រិតសម្រាំងដោយខ្មែរ

ក្រហម -- អ្នកធ្វើការនយោបាយក្នុងក្រុមខ្មែរក្រហម។ អ្នកគាំទ្រទៅលើរបប លន់ នល់ ដែលត្រូវបានដួលរលំ អភិជន អ្នកជាពាណិជ្ជករមានៗ និងពុទ្ធសាសនិក និងអ្នកមានឥទ្ធិពលនៅក្នុងភូមិទាំងឡាយត្រូវបានគេចាប់ខ្លួន។ យើងឃើញមានការកាប់សម្លាប់ជាង១០០នាក់ នៅក្នុងខេត្តបាត់ដំបងតែមួយប៉ុណ្ណោះ។ អ្នកជាជនភៀសខ្លួនបានលើកឡើងដូច្នេះ។

[១៤:០៦:៣៩]

សង្ឃប្រាំបួននាក់ បួនអង្គត្រូវបានគេបាញ់សម្លាប់ចោលនៅលើជណ្ដើរវិហារក្នុងតំបន់ប៉ោយប៉ែត ដោយសារព្រះសង្ឃទាំងអស់នោះបដិសេធមិនចាកចេញពីវត្ត។ ជនជាតិភាគតិចដែលកាន់សាសនាម៉ូស្លីម គឺជនជាតិចាមនៅក្នុងខេត្តកំពង់ចាម គឺជាក្រុមជនរងគ្រោះដំបូងបំផុតដែលជាជនរងគ្រោះនៃការកាប់សម្លាប់ប្រឆាំងនឹងសាសនា។ នេះបើតាមជនភៀសខ្លួន។ ហើយជនភៀសខ្លួនគឺបានឆ្លងព្រំដែននៅថ្ងៃព្រហស្បតិ៍”។ យើងដឹងហើយថាមានវិហារមួយចំនួនត្រូវបានគេបាញ់បំផ្លាញចោលដោយកាំភ្លើងយន្តនៅចំពោះមុខជនជាតិថៃ ដែលនៅម្ខាងនៃព្រំដែន។

ឯកសារមួយទៀតគឺ E3/2684 របាយការណ៍មកពី ហ្សង់-ហ្សាក់ កាហ្ស បារាំងមានលេខ ERN 00391424, អង់គ្លេសមានលេខ 00710315, អត់មានការបកប្រែជាភាសាខ្មែរនោះទេ។ ថ្ងៃសៅរ៍ ថ្ងៃទី២៦ ខែមេសា។ “តាមលើកដំបូងបំផុតយើងដឹងថាកុងស៊ុល បារាំងធ្វើការទាក់ទងហើយជាមួយនឹងអនុសេនាធិការដើម្បីជួបគ្នានៅព្រឹកស្អែក ហើយបានសម្រេចថា នៅថ្ងៃទី៣០ ជនជាតិបរទេសទាំងអស់ត្រូវតែដឹកជញ្ជូនជម្លៀសតាមឡានក្បួនទៅកាន់ប៉ោយប៉ែត ដែលជាភូមិមួយនៅជិតព្រំដែនថៃ។ ក្បួនរថយន្តនោះត្រូវរៀបចំនៅក្នុងថ្ងៃបន្តបន្ទាប់ ជនជាតិបរទេសត្រូវចាក ចេញពីប្រទេសដោយក្រុមជាតិនិយម ឬក៏ដោយអង្គការជាក់លាក់ណាមួយ”។

[១៤:០៩:០០]

នៅពេលនេះ គឺខ្ញុំចូលទៅដល់ឯកសារថ្ងៃទី២៨ ខែមេសា ឆ្នាំ៧៥ ឯកសារលេខ E190.1.302 ខ្មែរមានលេខ 00858667, បារាំងមានលេខ 00777553, អង់គ្លេសមានលេខ ERN 00002603 នេះគឺជាអត្ថបទសារព័ត៌មានចុះក្នុង កាសែតថៃមស៍ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៥។ ប្រអប់ពណ៌ក្រហមមានសរសេរជាភាសាខ្មែរ គឺមានសរសេរដូចតទៅ៖

“ដោយដឹងខ្លួនច្បាស់ថាមិនអាចតស៊ូទៅទៀតបាន ថ្នាក់ដឹកនាំដែលនៅសេសសល់នៃរបបសាធារណរដ្ឋខ្មែរ បានចូលរួមការប្រជុំមួយដែលរៀបចំទុកជាមុននៅគីឡូលេខ៦ តាមបណ្ដោយផ្លូវជាតិលេខ៥

ដោយនៅទីនោះ ពួកគេបានសុំចុះចូលជាមួយកងទ័ពខ្មែរក្រហមកុម្មុយនីស្ត”។

[១៤:១០:៤២]

នៅក្នុងឯកសារដដែលនេះ ត្រង់ខ្មែរ ERN លេខ គឺទំព័រចុងក្រោយ ឯកសារនេះគឺអ្នកកាសែតបាននិយាយអំពីអនាគតកាល “ខៀវ សំផន សង្ឃឹមថានឹងផ្លាស់ប្តូរប្រទេសរបស់ខ្លួនទៅជាប្រទេសដែលគ្រប់គ្រងដោយកុម្មុយនីស្ត។ នៅក្នុងកន្លែងដែលត្រូវបានគ្រប់គ្រងដោយជនបះបោរក្នុងរយៈពេលមួយចំនួន។ យើងឃើញមានការប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីបោសសម្អាត ទម្លាប់រួសរាយរាក់ទាក់របស់ប្រជាជនកម្ពុជា។ យើងឃើញថា ជាមួយនឹងការបញ្ជាក់អំពីជីវិតដែលពាក់ព័ន្ធនឹងនយោបាយខ្លាំង និងស្ថិតនៅក្រោមការគ្រប់គ្រង ប្រជាកសិករត្រូវបានប្រមូលឲ្យរស់នៅផ្តុំគ្នា នៅក្នុងសហគមន៍ដោយរដ្ឋអំណាចត្រួតត្រាលើសកម្មភាពឯកជនរបស់ពលរដ្ឋ”។

នៅក្នុងអត្ថបទដដែលនេះចុងក្រោយបានលើកឡើងថា “គុណសម្បត្តិរីករាយ តែមួយគត់ដែលខ្មែរក្រហមមាន គឺប្រជាប្រិយភាពរបស់ពួកគេក្នុងចំណោមប្រជាជនទូទៅ ប្រហែលជាដោយសារតែជឿជាក់ និងការដឹងគុណដែលបានធ្វើឲ្យសង្គមចប់។ ប្រជាប្រិយភាពរបស់ពួកគេត្រូវបានបាត់បង់ភ្លាមប្រសិនបើថ្នាក់ដឹកនាំថ្មីនៃរបបនេះបានចាប់ផ្តើមឲ្យមានការសងសឹកទូទៅ និងផ្លាស់ទៅបង្កើតរដ្ឋនៃការរស់នៅប្រមូលផ្តុំ ដ៏ឃោរឃៅឆាប់រហ័សមួយនោះ។

[១៤:១២:៣០]

ដោយលើកឡើងពីបញ្ហាគ្រោះថ្នាក់ដែលអាចមាន សមាជិកភាពផ្នែកនយោបាយរបស់ខ្មែរក្រហមលោក ចៅ សេង បានអះអាងនៅចំពោះមុខសន្និសីទសារព័ត៌មានក្នុងទីក្រុងប៉ារីសប្រទេសបារាំងកាលពីសប្តាហ៍មុនថា នៅពេលដែល សូមដកស្រង់សម្តី “មានការកាត់ទោសនៅទីក្រុងភ្នំពេញ ពួកយើងនឹងជម្រះសេចក្តីដោយមនុស្សធម៌”។ បិទការដកស្រង់សម្តីវិញ។ ហើយរបបថ្មីនេះនឹងត្រូវបានវិនិច្ឆ័យដោយប្រជាពលរដ្ឋរបស់ខ្លួនផ្ទាល់ និងប្រជាជនលើពិភពលោកទាំងមូល ផ្អែកលើការប្រព្រឹត្តយុត្តិធម៌ដែលខ្លួនមាន។

ចូលទៅដល់ឯកសារចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ ឯកសារលេខ E3/2684 ឯកសារហ្សង់-ហ្សាក់ កាហ្សូ។ បារាំង ERN គឺមានលេខ 003911425 (ស៊ីក), អង់គ្លេសមានលេខ 00710317 គ្មានការបកប្រែជាភាសាខ្មែរ។ ឯកសារនេះគឺចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ៧៥។ “ថ្ងៃពុធ ថ្ងៃទី៣០ ខែមេសា ប្រជាជនប្រមូលផ្តុំគ្នានៅម៉ោងពីរសាមសិបរសៀលនៅច្រកចេញ នៅខាងមុខទ្វារ

ស្ថានទូត។ ឡានចិន២៥ឡាន ត្រូវបានគេចតនៅក្នុងទីតាំងនោះ ហើយរហូតទៅដល់ម៉ោងប្រាំ ទើបជនដែលត្រូវបានគេជម្លៀសឡើងជិះរថយន្តទាំងអស់នោះ”។ ខ្ញុំសូមពន្យល់ថានេះគឺជាស្ថានទូត ហើយប្រជាជននៅទីនោះត្រូវបានគេជម្លៀសតាមរយៈឡានចិនចេញទៅ។

[១៤:១៤:៤៥]

ខ្ញុំសូមចូលទៅដល់ឯកសារថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៧៥ ឯកសារ E3/51។ ខ្មែរ ERN មានលេខ 00644734, បារាំងមានលេខ 00597850, ឯកសារអង់គ្លេសមានលេខ 00644734។ អត្ថបទនេះចុះថ្ងៃទី៣០ មេសា ឆ្នាំ៧៥ មានចំណងថា “យើងវង្វេងវង្វាន់ និងច្របូកច្របល់”។ ឯកសារខ្មែរមានលេខ 00644734 ឯកសារសរសេរដោយអ្នកកាសែតបារាំងចេញមកពីស្ថានទូតបារាំង។ ខ្ញុំសូមដកស្រង់សម្តី “វាបានចំណាយពេល២ថ្ងៃ ដ៏ធុញទ្រាន់ក្នុងការធ្វើដំណើរលើចម្ងាយផ្លូវ១២៨ គីឡូម៉ែត្រដំបូងដោយសារស្ថានភាពផ្លូវដ៏គួរឲ្យរន្ធត់ និងការរៀបចំមិនបានល្អដោយអ្នកនាំផ្លូវរបស់យើង”។

[១៤:១៦:១២]

ទំព័រមួយទៀតនៅក្នុងភាសាខ្មែរគឺ 00644735 “យើងបានមកដល់ចំណុចដែលនឹកស្មានមិនដល់សោះថា នៅក្រៅទីក្រុងភ្នំពេញស្ទើរតែនៅគ្រប់ទីក្រុង ទីប្រជុំជន ភូមិ និងតាមក្រុមតូចៗដែលមិនព្រមចុះចូលជាមួយបក្សកុម្មុយនីស្តបានជម្លៀសខ្លួនចេញទៅតាមទីជនបទ។ ភាគច្រើននៃប្រជាជន៧លាននាក់នេះដែលបានស៊ូទ្រាំនឹងអំពើយង់ឃ្នង និងសង្គ្រាមឥតន័យនៃសម័យទំនើបត្រូវបានដកទាំងឫសហើយប្រជាជនធ្លាក់ក្នុងភាពអត់ឃ្លាន និងឡប់សតិ។ រាត្រីនេះ យើងបានមកដល់ទីរួមខេត្តកំពង់ឆ្នាំង និងបានឃើញថាប្រជាជន៥០០.០០០នាក់ បានចាកចេញទៅអស់រលីង។ នៅក្បែរទីជនបទយើងមានឱកាសបាននិយាយមួយភ្លែតជាមួយបុរសគិលានុបដ្ឋាយិកាម្នាក់ដែលមានឈ្មោះថា តុង សាន មកពីមន្ទីរពេទ្យកំពង់ឆ្នាំង។ ក្រុមគ្រូពេទ្យស្កុតឡែនបានស្គាល់គាត់ដោយពួកគេជាគ្រូបានបង្ហាត់គាត់។ លោកបាននិយាយថា កាលពីខែមេសា ខ្មែរក្រហម២០នាក់បានយកអ្នកជំងឺនៅតាមមន្ទីរពេទ្យទាំងអស់ចេញទៅតាមឡូរី និងទម្លាក់ពួកគេចោលនៅក្នុងព្រៃចម្ងាយ២៨គីឡូម៉ែត្រ ជាកន្លែងដែលគ្មានអាហារ ឬទឹក”។

[១៤:១៨:០៥]

ឯកសារមួយទៀតគឺ E3/3366 ការដកស្រង់ចេញនៅក្នុងភាសាខ្មែរដំបូងបំផុតគឺ 00631524, បារាំងៗមានលេខ 00606727, ខ្មែរ -- អង់គ្លេសមានលេខ 00445231។ អត្ថបទនេះសរសេរដោយហ្សង់-ហ្សាក់ កាហ្សូ បានបោះពុម្ពផ្សាយនៅកាសែតឡូសអេនជីឡេស ថ្ងៃទី០៨ ឧសភា ឆ្នាំ៧៥។ គាត់

បានរៀបរាប់អំពីដំណើរចាកចេញពីស្ថានទូតបារាំងទៅតាមទីព្រំដែន ដូចដែលបានលើកឡើងមុននេះដែរ។

“នៅទូទាំងប្រទេសកម្ពុជាដែលទើបតែត្រូវបានរំដោះថ្មីៗនេះ គេនៅតែឃើញមានផ្លូវដែលគ្មានចរាចរណ៍ ភូមិដែលត្រូវបានគេដុតឆេះ និងទីជនបទដែលត្រូវបានគេបោះបង់ចោល ដែលមានតែក្របីដែលគ្មានម្ចាស់ពីរបីប៉ុណ្ណោះកំពុងស៊ីស្មៅ។ គ្រប់ទីកន្លែងមានសុទ្ធតែខ្ទមបាក់បែក ក្រដាសប៉ើងរាយប៉ាយ បំណែកពូករហែករយ៉េររយ៉ៃ គ្រឿងសង្ហារឹមបាក់បែក និងឆ្កែដែលស្គមសល់តែឆ្អឹងគួរឲ្យខ្លាច។ ចំណែកជ្រូកវិញឈ្មុសកកាយដី រកចំណីអាហារនៅក្នុងសួនច្បារ។ នៅពេលធ្វើដំណើរឆ្លងកាត់ទីក្រុងនានា គេឃើញសភាពស្ងប់ស្ងាត់នៅមាន នៅតែមានដដែល។ ទាំងទឹកទាំងភ្លើងសុទ្ធតែត្រូវបានកាត់ផ្ដាច់អស់។ នៅតាមផ្លូវនានាមិនមានអ្វីសោះក្រៅអំពីក្រដាសប្រាក់ ដែលប៉ើងរសាត់តាមខ្យល់ម្ដងម្កាលតែប៉ុណ្ណោះ។ សភាពការណ៍គឺដូចគ្នាទាំងនៅក្នុងខេត្តកំពង់ចាម ពោធិ៍សាត់ និងបាត់ដំបង”។

ដូច្នេះនៅពេលនេះ ខ្ញុំសូមឲ្យអង្គភាពសោតទស្សន៍ ដោយសុំអនុញ្ញាតពីលោកប្រធាន សុំឲ្យសោតទស្សន៍ចាក់ខ្សែវីដេអូលេខ៩។ សូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! បុគ្គលិកសោតទស្សន៍ចាក់ផ្សាយនូវវីដេអូលើអេក្រង់ទូរទស្សន៍ នូវខ្សែវីដេអូលេខ៩ តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១៤:២០:៣០]

*(ការបង្ហាញឯកសារជាខ្សែវីដេអូលេខ៩)*

[១៤:២០:៥១]

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតចាក់ខ្សែវីដេអូលេខ៦ផងដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ បុគ្គលិកសោតទស្សន៍ចាក់ផ្សាយខ្សែវីដេអូលេខ៦ តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា។

[១៤:២១:១៧]

*(ការបង្ហាញឯកសារជាខ្សែវីដេអូលេខ៦)*

[១៤:២២:៣៦]

**លោក ឃីត វេយ៍ន័រ៖**

នៅពេលនេះ ខ្ញុំសូមបន្តទៅមុខទៀត តាមកាលបរិច្ឆេទនៃឯកសារ គឺនៅពេលនេះ សូមបង្ហាញឯកសារចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ៧៥។ ឯកសារដំបូង គឺ E3/2666។ ខ្មែរយោង លេខយោងខ្មែរគឺ 00499661, បារាំងមានលេខ 00386856, អង់គ្លេស ERN គឺមានលេខ 00517763។ អត្ថបទនេះ គឺជាសារទូរលេខមកពីកន្លែងមួយផ្សេងទៀត "នៅពេលនេះ គឺយើងឃើញមានសារទូរលេខបញ្ជូនមកពីស្ថានទូតបារាំងប្រចាំនៅប្រទេសថៃ ដែលបញ្ជូនទៅក្រសួងការបរទេសនៅក្នុងប្រទេសបារាំង។ សារទូរលេខនេះ គឺបានបញ្ជូននៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ៧៥ ក៏ប៉ុន្តែខ្ញុំយកមកដាក់ក្នុងកាលបរិច្ឆេទឯកសារថ្ងៃទី២៧ ខែឧសភា ឆ្នាំ៧៥។ ចំណងជើងសារទូរលេខនេះមានដូចតទៅ "សក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន អតីតឧត្តមសេនីយ៍នៃកងកម្លាំងប្រដាប់អាវុធជាតិខ្មែរ"។

[១៤:២៤:២៥]

ទីប្រឹក្សាអមស្ថានទូតបារាំងប្រចាំនៅប្រទេសថៃ ទើបនឹងទទួលបានសក្ខីកម្មរបស់លោកឧត្តមសេនីយ៍ត្រី សរ ប៊ុន ដែលលោកជាអតីតប្រធានផ្នែកបញ្ជូនព័ត៌មាននៃកងកម្លាំងប្រដាប់អាវុធជាតិខ្មែរ។ លោកឧត្តមសេនីយ៍ សរ ប៊ុន បានឆ្លងកាត់នូវបទពិសោធន៍យ៉ាងអស្ចារ្យ ដោយលោកបានធ្វើដំណើរដោយថ្មើរជើងអស់រយៈពេល៣៩ថ្ងៃ ក្នុងចម្ងាយផ្លូវប្រហែលជា៦០០គីឡូម៉ែត្រ ដើម្បីរត់គេចពីខ្មែរក្រហម និងធ្វើការភៀសខ្លួនចូលទៅក្នុងប្រទេសថៃ។ លោកបានធ្វើដំណើរមកដល់ប្រទេសថៃនាថ្ងៃទី២៧ ខែឧសភា មុននេះ។ សក្ខីកម្មរបស់លោកនាយឧត្តមសេនីយ៍នៃអតីតកងទ័ពសាធារណរដ្ឋខ្មែរម្នាក់នេះ មានសារៈសំខាន់ខ្លាំងណាស់ ដោយហេតុថានាយឧត្តមសេនីយ៍ម្នាក់នេះអាចធ្វើដំណើរឆ្លងកាត់តំបន់ភាគខាងជើងនៃប្រទេសកម្ពុជាទាំងមូលបាន។

ចូលទៅដល់កថាខណ្ឌបន្ទាប់មួយទៀតដែលក្នុងប្រអប់ នៅក្នុងប្រអប់ក្រហមនេះដដែល "ឧត្តមសេនីយ៍ សរ ប៊ុន មានវាសនាចាកចេញពីភ្នំពេញបានដោយលោកត្រូវបានកម្មាភិបាលមូលដ្ឋានរបស់ពួកខ្មែរក្រហមប្រគល់លិខិតដើរផ្លូវ លើឈ្មោះក្លែងបន្លំ។ ឯកសារដដែល គឺត្រង់លេខ 00499662 បានសរសេរឡើងថា សក្ខីកម្មរបស់លោកបានបែងចែកចេញជាបីផ្នែក ទី១ គឺនិយាយអំពីការជម្លៀសប្រជាជន។ ទី២ និយាយអំពីការកាប់សម្លាប់ និងផ្នែកទី៣ និយាយអំពីអង្គការចាត់តាំងនយោបាយ និងវត្ថុបំណងនៃបដិវត្តន៍កម្ពុជា។

[១៤:២៦:១៩]

ចូលទៅដល់ទំព័រមួយទៀត គឺ 00499663 ក្រោមចំណងជើងថា "ការជម្លៀសប្រជាជនចេញពីទីក្រុង"។ អត្ថបទនោះសរសេរឡើងដូចតទៅថា "លោកឧត្តមសេនីយ៍ សរ ប៊ុន បានអះអាងអំពីការជម្លៀសប្រជាជនទាំងហ្វូងចេញពីទីក្រុង និងពីភូមិស្រុកនានា ដោយគ្មានលក្ខខណ្ឌ មិនថានរណាជានរណាឡើយ។ ប្រជាជននៅទីក្រុងភ្នំពេញ និងអ្នកភៀសខ្លួនមានចំនួនជាង២លាននាក់ គិតត្រឹមខែមេសា មុននេះត្រូវបានជម្លៀសចេញតាំងពីថ្ងៃទី១៨ ខែមេសា មកម្ល៉េះ"។ ត្រង់ទំព័រនេះ ដដែល ប៉ុន្តែប្រអប់ខាងក្រោមមួយទៀតបានសរសេរថា "លោកឧត្តមសេនីយ៍ សរ ប៊ុន បានបន្ថែមថា ជនណាដែលរឹងរូស និងដែលមិនបានស្តាប់តាមបញ្ជាឲ្យធ្វើការជម្លៀសចេញនេះ នឹងត្រូវសម្លាប់ចោលភ្លាមបន្ទាប់ពីត្រូវបានគំរាមចំនួនពីរដងរួចមក។ គាត់បានឃើញផ្ទាល់នឹងភ្នែកនូវព្រឹត្តិការណ៍បាញ់សម្លាប់មនុស្សម្នាក់នឹងកាំភ្លើងខ្លីដោយពួកខ្មែរក្រហមនៅចំពោះមុខគ្រួសាររបស់ជននោះ បន្ទាប់ពីជននោះបានប្រកែកមិនព្រមចេញពីគេហដ្ឋានរបស់ខ្លួនចំនួនបីដងជាប់ៗគ្នា។ នៅតាមផ្លូវពេលជម្លៀសចេញ ជនណាដែលមិនចង់ ឬមិនអាចជម្លៀសបាន ក៏ត្រូវបានពួកខ្មែរក្រហមសម្លាប់ចោលផងដែរ"។

[១៤:២៧:៥៩]

នៅពេលធ្វើដំណើរតាមផ្លូវពីភ្នំពេញទៅព្រែកក្តាមលោកឧត្តមសេនីយ៍ក៏បានប្រទះឃើញសាកសពជាច្រើនដេកស្លាប់រណែលរណ្ឌូកតាមផ្លូវចម្ងាយប្រហែល ២០គីឡូម៉ែត្រពីភ្នំពេញផងដែរ។ ត្រង់ផ្នែកមួយទៀត គឺឯកសារ 00499666, បារាំងមានលេខ 00386859។ អត្ថបទនេះសរសេរឡើងថា៖

"នៅចន្លោះពីព្រែកក្តាមរហូតទៅដល់សៀមរាប នៅតាមផ្លូវជាតិលេខ៦ តំបន់នានានៅតាមផ្លូវចម្ងាយ៤០០គីឡូម៉ែត្រ ត្រូវបានជម្លៀសទាំងអស់ រួមបញ្ចូលទាំងភូមិមួយចំនួនធំផងដែរ។ លោកឧត្តមសេនីយ៍ សរ ប៊ុន បានសង្កត់ធ្ងន់ចំពោះករណីព្រះសង្ឃដែលមានចំនួនច្រើននៅប្រទេសកម្ពុជា និងដែលជាសសរគ្រឹះនៃព្រះពុទ្ធសាសនាក្នុងសង្គមកម្ពុជា។ ព្រះតេជគុណពុំបានទទួលនូវការប្រណិប័តន៍ពិសេសណាមួយឡើយនាសម័យនោះ។ ព្រះសង្ឃត្រូវបានជម្លៀសចេញដូចជាប្រជាជនទូទៅដែរ។ វត្តអារាមដែលជាធម្មតាជាទីកន្លែងពុំអាចប៉ះពាល់បាន ត្រូវបានពួកខ្មែរក្រហមយកធ្វើជាកន្លែងផ្ទុកសម្ភារៈផ្សេងៗទៅវិញ"។

ដូច្នេះ ខ្ញុំសូមស្នើឲ្យអង្គភាពសោតទស្សន៍ដោយសូមអនុញ្ញាតពីលោកប្រធានសូមឲ្យសោតទស្សន៍ចាក់បញ្ចាំងខ្សែវីដេអូលេខ៥។

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍ចាក់វីដេអូលេខ៥ នៅលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១៤:៣០:៣១]

*(ការបង្ហាញឯកសារជាវីដេអូលេខ៥)*

[១៤:៣២:៤២]

**លោក ឃីត វេយ្យ័នរ៖**

សូមអនុញ្ញាតបន្តការបង្ហាញអត្ថបទរបស់ឧត្តមសេនីយ៍ សរ ប៊ុន ដដែល។ ត្រង់ខ្មែរលេខ 00499664, លោកឧត្តមសេនីយ៍ សរ ប៊ុន បានចង្អុលបញ្ជាក់ថា "ការជម្លៀសទ្រង់ទ្រាយធំបែបនេះ បានបង្ហាញអំពីគោលបំណង បញ្ជូនប្រជាជនទៅកាន់ស្រែចម្ការបានហេតុផលតិចតួចបំផុត។ ពោលគឺពុំដូចទៅនឹងអ្វីដែលគេរំពឹងទុកថា ពួកគេរំពឹងទុកនោះទេ។ ចំពោះលោក លោកយល់ឃើញថាការធ្វើដូច្នេះគឺជាការដាក់ទណ្ឌកម្មទៅលើប្រជាជនក្នុងទីក្រុង ដែលពុំបានឱបក្រសោបអនុវត្តទៅតាមបដិវត្តន៍របស់គេ ហើយការធ្វើដូច្នេះដើម្បីឲ្យប្រជាជននៅតាមទីក្រុងនោះផលិតនូវលទ្ធផលកសិកម្ម។ ដូច្នេះ យើងឃើញថា គេមិនរៀបចំការសម្របសម្រួលណាមួយដើម្បីជម្លៀសប្រជាជននោះទេ។ គ្មានចប គ្មានរបស់របរ គ្មានគ្រាប់ពូជ គ្មានអ្វីសម្រាប់ឲ្យប្រជាជនដាំដុះនោះទេ។ ហើយយើងឃើញថា ឧបករណ៍សម្ភារៈទាំងអស់នេះត្រូវបានគេបោះបង់ចោល នៅតាមទីកន្លែងផ្សេងៗ។ បន្ទាប់ពីពួកគេត្រូវបានអនុញ្ញាតសម្រាករយៈពេលមួយចំនួន យើងឃើញថាការជម្លៀសនោះ ត្រូវបានគេជម្លៀស"។ ហើយលោក សរ ប៊ុន បានបញ្ជាក់ថា "ការជម្លៀសនោះគឺមានស្ថានភាពធ្ងន់ធ្ងរ។ អ្នកដែលត្រូវបានគេជម្លៀស ត្រូវបានទទួលអង្ករម្ដង ឬពីរដងក្នុងមួយសប្ដាហ៍ ហើយអ្នកខ្លះរស់ ដើម្បីរស់ខ្លួនឯងព្យាយាមហូបបន្លែបន្ទុក ឬក៏ដើមចេកជាមួយនឹងបបរ។ បានន័យថា ក្រៅពីទាហានខ្មែរក្រហមដែលបានចូលរួមជាមួយនឹងបដិវត្តន៍រួចហើយនោះ ប្រជាជនកម្ពុជាទទួលរងនូវការអត់ឃ្លាន ដែលបានបង្កឲ្យមានជំងឺគ្រុនចាញ់រាគត្បាតធ្ងន់ធ្ងរ ដោយគ្មានអ្វីទប់ស្កាត់ ឬក៏មិនមានថ្នាំព្យាបាល ថ្នាំសង្កូវអ្វីឡើយ។

[១៤:៣៥:៣៣]

នៅក្នុងឯកសារដដែលនេះ ខ្មែរលេខ 00496665 រហូតដល់ទៅ 66, បារាំងមានលេខ 00386861, អង់គ្លេសមានលេខ 00517767។ អត្ថបទនេះសរសេរថា "ឧត្តមសេនីយ៍ សរ ប៊ុន បានបែងចែកការកាប់សម្លាប់ពួកខ្មែរក្រហមជាបីប្រភេទ។ ១) ការកាប់សម្លាប់ភ្លាមៗនៅនឹងកន្លែង។ ២)

ការសម្លាប់ជាប្រព័ន្ធ និង ៣) ការសម្លាប់ដោយផ្តាច់ជីវិតសន្សឹមៗ”។ យោងតាមលោកឧត្តមសេនីយ៍ នៅពេលដែលភ្នំពេញត្រូវបានចាប់យកភ្លាមនោះ ការកាប់សម្លាប់នៅនឹងកន្លែងឃើញមានច្រើន។ គាត់ត្រូវបានគេប្រាប់ថា ជនទាំងឡាយដែលប្រឆាំងនឹងបញ្ជាឲ្យចាកចេញពីលំនៅដ្ឋានជាច្រើនលើកច្រើនសានឹងត្រូវសម្លាប់ចោល។ ដូចគ្នានេះដែរ ជនទាំងឡាយណាដែលមិនចង់ ឬមិនអាចធ្វើការជម្លៀសជាមួយគេបាន ក៏ត្រូវសម្លាប់ចោលដែរ។ អតីតទាហានរបស់ លន់ នល់ ក៏ត្រូវបានគេជម្លៀសក្រោយពេលបែកភ្នំពេញផងដែរ។ អតីតទាហានរបស់ លន់ នល់ ដែលជម្លៀសចេញទៅជាមួយគ្រួសារត្រូវបានគេស្គាល់អត្តសញ្ញាណយ៉ាងស្រួលបំផុត នៅពេលដែលពួកគេឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យជាហូរហែរបស់ពួកខ្មែរក្រហម។ ពួកគេត្រូវបានបញ្ជាឲ្យដោះស្បែកជើង និងឯកសណ្ឋានចេញ បន្ទាប់មកត្រូវបានបាញ់សម្លាប់ភ្លាមៗតែម្តង”។

[១៤:៣៧:៤២]

“លោកឧត្តមសេនីយ៍ សរ ប៊ុន ក៏ធ្លាប់ឃើញផ្ទាល់ភ្នែកនៅពេលដែលលោកត្រូវជម្លៀសពីភ្នំពេញទៅព្រែកក្តាម នូវការសម្លាប់នាយទាហានរបស់លោកជាច្រើន ដោយនារីវ័យជំទង់កុម្មុយនីស្ត ដែលមានអាយុពី១៥ ទៅ ២០ឆ្នាំ ដែលពួកនាងត្រូវបានប្រើកាំភ្លើងយន្តបាញ់សំដៅទៅលើខ្នងរបស់នាយទាហានអស់ទាំងនោះ បន្ទាប់ពីពួកគេត្រូវបានបញ្ជាឲ្យដើរទៅមុខប្រហែល២០ម៉ែត្ររួចមក”។

ការកាប់សម្លាប់ប្រភេទទី២ គឺការសម្លាប់ជាប្រព័ន្ធ។ “រាល់នាយទាហានទាំងឡាយ ដែលមានឋានៈ ឋានន្តរស័ក្តិចាប់ពីអនុសេនីយ៍ឡើងទៅ ហើយដែលមិនត្រូវបានសម្លាប់នៅទីកន្លែងនានា ត្រូវបានប្រមូលផ្តុំនៅតាមជំរំនានា។ ក្នុងចំណោមជំរំទាំងអស់នោះ លោកឧត្តមសេនីយ៍ សរ ប៊ុន បានស្គាល់ជំរំពីរដែរ គឺមួយមានទីតាំងនៅក្បែរកំពង់ធំ និងមួយទៀតមានទីតាំងនៅសៀមរាប។ នៅជំរំតាំងក្រសាំងដែលស្ថិតនៅចម្ងាយ១៥គីឡូម៉ែត្រភាគខាងកើតខេត្តកំពង់ធំ តាមផ្លូវជាតិលេខ៦ ការកាប់សម្លាប់មានស្ទើរជារៀងរាល់ថ្ងៃ ទៅលើក្រុមទាហានដែលមានគ្នាពីបីទៅប្រាំនាក់ក្នុងមួយក្រុម ដោយពួកគេត្រូវបានបាញ់សម្លាប់នៅជុំវិញបន្ទាយ។ នៅទីនោះក៏ដូចជានៅកន្លែងដទៃផ្សេងទៀតដែរ សាកសពត្រូវបានបន្សល់ទុកនៅនឹងកន្លែងតែម្តង ដោយពុំត្រូវបានយកទៅធ្វើបុណ្យបូជាអ្វីឡើយ”។

[១៤:៤០:០៥]

បន្ទាប់មកយើងមើលប្រភេទកាប់សម្លាប់ទី៣វិញម្តង អត្ថបទនេះសរសេរឡើងថា “ការកាប់សម្លាប់នេះធ្វើឡើងព្រមគ្នាទៅនឹងការកាប់សម្លាប់មួយទៀត ដែលលោកឧត្តមសេនីយ៍ ឲ្យឈ្មោះថា ការ

សម្លាប់ដោយផ្តាច់ជីវិតសន្សឹមៗ។ រាល់បណ្តានាយទាហានត្រូវបានដាក់ទណ្ឌកម្មឲ្យធ្វើការងារកសិកម្ម បើទោះបីជាការងារនេះពុំត្រូវបានកំណត់ច្បាស់លាស់ក៏ដោយ។ តាមការពិតការងារទាំងនេះមានលក្ខណៈជាការបង្ខំឲ្យមនុស្សឲ្យធ្វើការងារ ជាជាងមានគោលដៅបម្រើឲ្យកសិកម្ម។ ការងារនោះត្រូវបានបញ្ជាឲ្យធ្វើក្នុងលក្ខខណ្ឌដ៏សែនលំបាកវេទនា ក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីសំណាក់ក្មេងជំទង់ជាយោធារបស់ខ្មែរក្រហម។ លោកឧត្តមសេនីយ៍បានឃើញផ្ទាល់នឹងភ្នែកនៅក្នុងជំរំមួយដែលស្ថិតនៅជិតសៀមរាប ដែលជំរំនោះប្រមូលផ្តុំសុទ្ធតែនាយទាហានរង និងមនុស្សដែលចងភ្ជាប់ទៅនឹងរទេះសម្រាប់អូសរទេះ ដោយក្នុងមួយរទេះមានគ្នាពីប្រាំមួយទៅប្រាំបីនាក់។ គេទាំងអស់គ្នានោះធ្វើការងារក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហមប្រដាប់ដោយអាវុធដែលមានអាយុពី១០ ទៅ ១៥ឆ្នាំ ពួកគេមើលទៅជាកូនក្មេងច្រើនជាងក្មេងជំទង់។ នៅទីនោះនាយទាហានទាំងអស់នេះត្រូវបានបង្អត់អាហារ ឬត្រូវបានឲ្យអាហារដែរ ប៉ុន្តែមានលក្ខណៈស្ងួចស្តើងបំផុត ពោលគឺគេទទួលបានអង្ករ៣០០ក្រាមសម្រាប់មនុស្ស ១០នាក់”។

[១៤:៤២:០៦]

លោកឧត្តមសេនីយ៍បានមានប្រសាសន៍យ៉ាងដូច្នេះ “ចំនួននៃអ្នកស្លាប់មានទំហំធំធេង លោកឧត្តមសេនីយ៍បានប៉ាន់ប្រមាណមើលថា តែក្នុងប៉ុន្មានខែទៅមុខទៀតប៉ុណ្ណោះ រាល់មន្ត្រីនៃអតីតកងកម្លាំងប្រដាប់អាវុធជាតិខ្មែរនឹងត្រូវបានកម្ទេចអស់គ្មានសល់ឡើយ”។ ពាក្យពេចន៍ចុងក្រោយនៃសក្ខីកម្មនេះគឺចេញពីតំណាងរបស់ស្ថានទូតបារាំងប្រចាំនៅប្រទេសថៃ “ចុងក្រោយ ខ្ញុំបានកត់សម្គាល់ឃើញថាសក្ខីកម្មពីជនភៀសខ្លួនមួយចំនួន ដែលអាចភៀសខ្លួនឆ្លងចូលមកក្នុងទឹកដីថៃ គឺវាស៊ីសង្វាក់គ្នាទៅនឹងគ្រប់ចំណុចទាំងអស់នៃសក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន”។

សរុបសេចក្តីមកមន្ត្រីកាទូតបានសរុបនូវការវាយតម្លៃរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន អង់គ្លេស 0051774 (ស៊ីក), ខ្មែរ 00499662, ហើយបារាំង 00386857។ អ្នកកាទូតបាននិយាយដោយយោងទៅលើសម្តីរបស់ឧត្តមសេនីយ៍ត្រីរូបនេះ “គាត់គឺជាជនជាតិខ្មែរដើម ហើយកម្រិតនៃការកាប់សម្លាប់ដែលគាត់និយាយដោយមានការយកចិត្តទុកដាក់នៅតែពីអ្វីដែលគាត់បានឃើញផ្ទាល់នឹងភ្នែក គឺគាត់មិននិយាយបំផ្លើស ឬក៏ពន្លើសទេ ឬក៏និយាយចំពោះភាពជាទូទៅនោះទេ”។

សុំការអនុញ្ញាតបន្តិចលោកប្រធាន។

[១៤:៤៥:០១]

លោកប្រធានដោយខ្ញុំភ្លេចពីពេលឈប់សម្រាកនៅថ្ងៃរសៀល ឥឡូវនេះខ្ញុំបានបញ្ចប់ការបង្ហាញអំពីការជម្លៀសនៅដំណាក់កាលទី១ ហើយ។ តែខ្ញុំត្រូវលើកឡើងអំពីបញ្ហាទួលពោធិ៍ជ្រៃ និងការជម្លៀសនៅដំណាក់កាលទី២។ តើពេលនេះល្មមនឹងសមឈប់សម្រាក ឬយ៉ាងណាដែរលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ដល់ពេលវេលាសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥ នាទី ដល់ម៉ោង ១៥:០៩ នាទី)*

[១៥:០៩:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់ឯកសារ។ ដាក់បង្ហាញឯកសារ បាទ សូមអញ្ជើញ។

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន ខ្ញុំសូម -- ខ្ញុំបានស្នើសុំឲ្យអង្គភាពសោតទស្សន៍គឺថាបង្ហាញខ្សែវីដេអូពីរដែលមិនបានបង្ហាញកាលពីមុននេះ ខ្ញុំដឹងថាពីមុននោះ គឺថា អេ.វី មិនអាចរកឃើញបាន ដូច្នេះពេលនេះសូមឲ្យបង្ហាញវីដេអូលេខ១០ ជាការដកស្រង់ចេញពីខ្សែភាពយន្តនិយាយអំពីកម្ពុជាឆ្នាំសូន្យ១៥ ដែលនិយាយអំពីការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ហើយបន្ទាប់មកបានមាននិយាយបញ្ជាំងអំពីឧបទ្ទវហេតុកើតឡើងនៅតាមដងផ្លូវទៅកាន់ទីជនបទ។ ដូច្នេះ សូមស្នើសុំការអនុញ្ញាតដើម្បីបញ្ចាំងឃ្លីបវីដេអូលេខ១០។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ្នកបច្ចេកទេសខាងសោតទស្សន៍ដាក់បញ្ចាំងនូវវីដេអូលេខ១០ នៅលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា។

[១៥:១០:៤៥]

*(ការបង្ហាញឯកសារជាខ្សែវីដេអូលេខ១០)*

[១៥:១១:១៥]

**លោក ឃីត រេយ៉ន៍រ៖**

សូមអរគុណ ហើយវីដេអូបន្ទាប់គឺលេខ១១ ដកស្រង់ចេញពីឯកសារនិយាយអំពី "កម្ពុជា៖ ប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍" មានរយៈពេលតែ ១នាទី ១២វិនាទីទេ ដែលបង្ហាញពីព្រឹត្តិ-ការណ៍ដែលកើតឡើងនៅស្ថានទូតបារាំង។ ដូចដែលខ្ញុំបានជម្រាបជូនខាងដើម គឺថាអ្នកដែលពាក់អាវធំហ្នឹងនៅដំណាក់កាលមួយនោះគឺថា គឺទ្រង់ សិរិមតៈ នេះឯងហើយក៏មានការបង្ហាញជាសង្ខេបនិយាយអំពីអ្នកកាសែតការទូតបារាំងមួយនិយាយនៅតាមដំណើររបស់គាត់ឆ្ពោះទៅកាន់ព្រំដែន។ ដូច្នេះ ដោយមានការអនុញ្ញាតពីអង្គជំនុំជម្រះសុំចាក់បង្ហាញឃ្លីបវីដេអូលេខ១១ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ្នកបច្ចេកទេសសោតទស្សន៍ ចាក់បង្ហាញនូវវីដេអូឃ្លីបលេខ១១ តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា។

[១៥:១២:១៧]

*(ការបង្ហាញឯកសារជាខ្សែវីដេអូលេខ១១)*

[១៥:១៣:៥២]

**លោក ឃីត រេយ៉ន៍រ៖**

សូមអរគុណលោកប្រធាន ខ្ញុំចូលទៅផ្នែកមួយទៀតនៃឯកសារមួយទៀត ផ្នែកពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃ។ ខ្ញុំសូមពន្យល់អំពីទម្រង់នៃឯកសារនៃការបង្ហាញឯកសារនេះ។ ខ្ញុំបានអានសម្រង់ចេញពីឯកសារផ្សេងៗ ហើយបន្ទាប់មកសូមបញ្ចាំងឃ្លីបខ្សែភាពយន្តរួចហើយខ្ញុំនឹងពន្យល់អំពីខ្សែភាពយន្តនេះ។ ឯកសារទី១ E3/51 ជាកម្រងឯកសារចេញពីសារព័ត៌មានERN ខ្មែរ 00644730, បារាំង 00597847, អង់គ្លេស 00003282។ នេះជាអត្ថបទសារព័ត៌មានថ្ងៃទី២៤ មេសា ពាក់ព័ន្ធទៅនឹងសម្រង់នេះ។

[១៥:១៥:០៥]

"ហ្សង់ភ៉ាមី ប្រធានសមាគមកសិករជនជាតិបារាំង និងជាបុរសជនជាតិបារាំងមានឥទ្ធិពលបំផុតរបស់កម្ពុជាមកដល់ទីនេះក្រោយរយៈពេល១សប្តាហ៍នៅតាមដងផ្លូវនានា។ គាត់និយាយថា គាត់

ដឹងថាពួកខ្មែរក្រហមកំពុងសម្លាប់មន្ត្រីយោធានៅឯកន្លែងបណ្តុះកូនកៅស៊ូឯជាយក្រុង"។

ឯកសារបន្ទាប់គឺ E3/3372, ERN ភាសាខ្មែរ00831549, អង់គ្លេស 00445435។ នេះគឺជាសម្រង់ដែលចេញពីអត្ថបទសារព័ត៌មានវ៉ាស៊ីនតោនប៉ុស្តិ៍នៅថ្ងៃទី០៥ ឧសភា ឆ្នាំ១៩៧៥។ "០៤ មិថុនា ៧៥ មានរបាយការណ៍ដែលរួមទាំងការលបយកព័ត៌មាន ដែលថាពួកកុម្មុយនីស្តគឺបានសម្លាប់ក្រុមគ្រួសារទាំងមូលរបស់អតីតមន្ត្រីយោធា ហើយនិងមន្ត្រីរដ្ឋការស៊ីវិលដែលមានឋានន្តរស័ក្តិខ្ពស់"។

ឯកសារបន្ទាប់គឺ E3/3316។ ឯកសារយោងជាភាសាខ្មែរមួយគឺ 00591055, បារាំង 00607 928 ដល់ 29, អង់គ្លេស 00419920។ នេះជាសម្រង់ឯកសារចេញពី *អាមនេសធី អ៊ិនធើណាស្យូណាល* អង្គការលើកលែងទោសអន្តរជាតិ ចុះថ្ងៃទី៣០ ខែមីនា ១៩៧៨។ ចំណងជើងនៃសារព័ត៌មាននេះគឺថា "អង្គការលើកលែងទោសអន្តរជាតិ អំពាវនាវឲ្យប្រទេសកម្ពុជាឆ្លើយតបទៅនឹងការចោទប្រកាន់ថាមានការសម្លាប់ក្រៅផ្លូវតុលាការ" ហើយអត្ថបទនៃសម្រង់នេះគឺដូចខាងក្រោមនេះ៖

[១៥:១៧:៥៦]

"អេ.អាយ អង្គការលើកលែងទោសអន្តរជាតិ យោងទៅលើដំណើររឿងរៀបរាប់ដោយជនភៀសខ្លួន ដែលថាស្ថានភាពនៅក្នុងកម្ពុជាប្រជាធិបតេយ្យចាប់តាំងពីមានការផ្លាស់ប្តូររដ្ឋាភិបាលនៅក្នុងខែមេសា ៧៥ ត្រូវបានគេកត់សម្គាល់ឃើញថាមានការកាប់សម្លាប់យ៉ាងរង្គាល។ នៅក្នុងឆ្នាំ១៩៧៥ និងដើមឆ្នាំ១៩៧៦ ជនភៀសខ្លួនបានរាយការណ៍ថា មន្ត្រី និងទាហានជាច្រើននៃកងទ័ពរបស់របបសាធារណរដ្ឋដែលចុះចាញ់នេះគឺថាត្រូវបានគេប្រហារជីវិតចោល នៅក្នុងរយៈពេលប៉ុន្មានខែបន្តបន្ទាប់ពីខ្មែរក្រហមចូលកាន់អំណាចមក។ ជនភៀសខ្លួនជាច្រើននាក់បាននិយាយអំពីការប្រហារជីវិតកងទាហានសាធារណរដ្ឋ លន់ នល់ ខ្លះបានឮអំពីការសម្លាប់មនុស្សដែលគេស្គាល់គ្នា ឬត្រូវបានទាហានខ្មែរក្រហមខ្លួនឯងនិយាយប្រាប់។ អ្នកដទៃទៀតបាននិយាយថា ខ្លួនបានឃើញរណ្តៅសាកសពរួម ឬក៏ឃើញសាកសពដែលស្លៀកពាក់ឯកសណ្ឋានទាហាន។ កងទ័ពខ្មែរក្រហម និងមន្ត្រីមូលដ្ឋានបានស្វែងរកកំណត់អត្តសញ្ញាណប្រជាជនទាំងនោះដែលកាន់តួនាទីនៅក្នុងរដ្ឋបាលចាស់"។

[១៥:១៩:៤៤]

លោកប្រធាននេះគឺឯកសារពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃ គឺឯកសារបង្ហាញពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃ។ យើងខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញជូនអង្គជំនុំជម្រះនូវសម្រង់ឯកសារចេញពីក្នុងសំណុំរឿង "ថ្ងៃមួយនៅទួលពោធិ៍ជ្រៃ"។ ខ្ញុំសូមពន្យល់ទៅដល់មេធាវីការពារក្តីថា ខ្សែ

ភាពយន្តនេះគឺមានរយៈពេល២៦នាទី ដែលត្រូវបានពិនិត្យឡើងវិញ កាត់បន្ថយមកត្រឹមតែ១៩នាទី។ យើងខ្ញុំបានបង្ហាញជូនអ៊ីម៉ែល ដែលបានផ្ញើជូនភាគីទាំងអស់រួចហើយ។ នេះគឺជាវីដេអូលេខ១២ ដែលមានចំណងជើងថា "ថ្ងៃមួយនៅទួលពោធិ៍ជ្រៃ"។

បាទ យើងខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីចាក់បញ្ចាំងឃ្លីបវីដេអូនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីផ្នែកសោតទស្សន៍ឲ្យចាក់ផ្សាយនូវឃ្លីបវីដេអូ លើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១៥:២១:០៧]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធានខ្ញុំសូមបន្ថែមបន្តិចទៀត គឺនេះគឺជាខ្សែភាពយន្ត ឬក៏ឃ្លីបភាពយន្តដែលថតដោយ ថេត សម្បត្តិ។ គាត់មានឯកសារដាក់ចូលនៅក្នុងសំណុំរឿងហើយ ក៏ប៉ុន្តែនេះគឺជាឃ្លីបភាពយន្តដែលត្រូវចាក់បង្ហាញជូននេះ គឺសង្ខេប។ សូមអរគុណ។

*(ការរៀបចំបង្ហាញឯកសារជាវីដេអូលេខ១២)*

[១៥:២២:០០]

សូមអធ្យាស្រ័យលោកប្រធាន ឃ្លីបវីដេអូនេះគឺនិយាយជាភាសាខ្មែរ ដែលមានចំណងជើងជាភាសាអង់គ្លេស។ ដូច្នេះយើងខ្ញុំសុំឲ្យចាក់ទាំងសំឡេងផង។ ដូច្នេះ អ្នកតាមដានដំណើរការនីតិវិធីសាធារណជនទាំងអស់ គឺថាគាត់អាចស្តាប់បានជាភាសាខ្មែរ ហើយមានចំណងជើងខ្លីៗរបស់វាជាភាសាអង់គ្លេស។ សូមចាក់ទាំងសំឡេងផង។ អរគុណ។

**ប្រធានអង្គជំនុំ៖**

អ្នកបច្ចេកទេសអនុវត្តតាមការស្នើសុំនេះ!

[១៥:២២:៥០]

*(ការបង្ហាញឯកសារជាវីដេអូលេខ១២)*

"ឆ(១)៖ ប៉ា ចុះប៉ាឯងទៅហ្នឹងចង់រកអី?

សៈ សុំនិយាយបន្តិច។ អីចឹងបងឃើញគេដឹកហ្នឹង ដឹកទៅផ្លូវហ្នឹង?

ឆ(២)៖ ផ្លូវហ្នឹងតាមហ្នឹង។

សៈ កាលឆ្នាំ៧៥-៧៩?
ឆ(១)៖ ពេលជំនាន់អាពតចាស។
ឆ(២)៖ ជំនាន់អាពតតាមហ្នឹងដែរ។
ឆ(១)៖ ជ្រៃ ទៅពីព្រីងខ្ពស់ទៅក៏ជ្រៃ មាត់ទឹក។
សៈ ហើយឡានច្រើនទេ?
ឆ(១)៖ ច្រើន។
ឆ(២)៖ ច្រើន។
សៈ កាលដែលថាដឹកយកមនុស្សទៅ--
ឆ(១)៖ ហ្នឹងហើយច្រើន។
[១៥:២៣:២១]
សៈ យកទៅធ្វើអី?
ឆ(១)៖ យកទៅវៃ!
ឆ(២)៖ យកទៅរៀននៅហ្នឹងអ្ហ!
ឆ (១)៖ រៀនវៃចោល។
សៈ ហើយរៀនអី?
ឆ(២)៖ រៀនវៃចោល។
ឆ(៣)៖ ប៉ាខ្ញុំ (ឮមិនច្បាស់) ប៉ាខ្ញុំក៏មកងាប់ហ្នឹងដែរ នៅពោធិ៍ជ្រៃដែរ។
សៈ ឪពុកបងបង្កើតអី ឬក៏ឪពុក--
ឆ(៣)៖ បង្កើត។
សៈ ប៉ុន្មាននាក់ ស្លាប់ទៅប៉ុន្មាននាក់?
ឆ(៣)៖ តែម្នាក់ឯង។
សៈ ឪពុកហ្នឹង?
ឆ(៣)៖ ចាស។
សៈ គាត់ធ្វើទាហាន?
ឆ(៣)៖ ធ្វើទាហានស័ក្តិ៥ ពីសង្គម។

ឆ(២)៖ ថា អ្នក! អ្នកស័ក្តិ៥ ទៅរៀនៗ។ អ្នកណាឲ្យតែស័ក្តិ៥ ឲ្យទៅ។ អូ! ម្នាក់ៗសុំឡើងឡាន។

ឆ(៣)៖ អត់ទេ ថាទៅរៀន។

ស៖ ប្រាប់បងឯងដែរ?

ឆ(៣)៖ ចាស ប្រាប់ខ្ញុំថា កូនអើយខ្ញុំទៅហើយ អើក៏ទៅៗឪ។ ស្អែកថា មកវិញ។ ស្អែកមកវិញ អត់មកវិញឯណា ដល់ទៅបួនប្រាំថ្ងៃ លេងគរជើងនៅពោធិ៍ជ្រៃ។

ស៖ ប៉ាបងឯងឈ្មោះអី?

ឆ(៣)៖ សុក ញ៉ឹក។

ស៖ សុក?

ឆ(៣)៖ សុក ញ៉ឹក ចាស។

ស៖ អរគុណច្រើនណាស់បង។

ស៖ ទាន់ៗ -- (ឮមិនច្បាស់) ត្រង់នេះអំមិញ?

ឆ(២)៖ បោលទៅលិច។

------------

ស៖ ឈប់! ផ្ទះ ពូជាម នៅកន្លែងណាអាអូន?

ឆ៖ បាទ?

ស៖ ផ្ទះពូជាម!

ឆ៖ ជាម?

ស៖ អើ!

ឆ៖ នៅឯជើង

ស៖ ទៀត? អរគុណ។

-------------

ឆ៖ ខ្ញុំទៅនោះ ក្របីវាបោលចូលហ្នឹងណ៎ា ក្របីរត់ពីផ្ទះទៅហ្នឹង។ ក្របីរត់ពីផ្ទះទៅ ខ្ញុំរត់តាមក្របីទៅ មានដឹងអាគេសម្លាប់មនុស្សហ្នឹងអី។ ដល់តែឯងរត់ទៅបានឃើញរលេ ស្លាប់រលេ ចងជាប់គ្នា ដូចខ្ញុំថាធ្វើឲ្យលោកក្មួយឯងមើលអំមិញ។

ស៖ ហើយឃើញស្ថានភាពហ្នឹងម៉េច? ហើមអីយ៉ាងម៉េច តាឃើញ?

ឆ៖ ដែលខ្ញុំទៅមានទាន់ហើមអី បើសម្លាប់ថ្ងៃហ្នឹង ព្រឹកឡើងទៅដល់ មានទាន់ហើមអី ប៉ុន្តែឮតែគ្រឹកគ្រុកៗ ខ្យល់ហ្នឹងវាឮ ប៉ុន្តែហើម មិនទាន់ហើមទេ។

សៈ ឮអីគ្រឹកគ្រុកហ្នឹង?

ឆ៖ ខ្យល់យើង អាមនុស្សងាប់ហ្នឹង ដូចយើងកូរអ៊ីចឹង (អ្នកនិយាយមិនស្គាល់អត្តសញ្ញាណៈអាខ្លះវានៅអត់ទាន់ដាច់ខ្យល់ផង) អត់ទេ! អត់ទេដាច់ខ្យល់អស់បាត់ហើយ រឹងអស់បាត់ទៅហើយហ្នឹង។ ខ្យល់ៗមនុស្សយើងងាប់អាអ៊ីចឹងទៅ ដែលដួលរេលហាលថ្ងៃអ៊ីចឹង ខ្យល់គ្រឹកគ្រុកៗៗក្នុងខ្លួនហ្នឹង។ ក្មួយឯងបើនេះឃើញខ្លាច។ ខ្ញុំដើរទៅអើតមើលយី! ខ្ញុំស្មានមនុស្សរស់ វារត់មកផ្ទះវិញមកណ៎ា។

សៈ សុំៗខ្សែអីបន្តិចមើល៍! ខ្ញុំសូមបន្តិច! ឲ្យតាបន្តិចមើល៍! តាគាត់ធ្វើឧទាហរណ៍អំមិញ ហ្នឹងៗ ឲ្យតាហុចឲ្យតាមក ហុចឲ្យតា។ តាឃើញយ៉ាងម៉េចដែលឃើញនៅហ្នឹង? តាៗ ធ្វើដាក់ដៃ ដាក់តមកខ្ញុំបាទ។

[១៥:២៦:១៧]

ឆ៖ គេឡាក់ចងជាប់គ្នា ចងមកជាប់ដូចយើងអ៊ីចេះទៅណ៎ា។

សៈ ហើយម៉េចទៀត?

ឆ៖ គេចងសុទ្ធតែពីរបីជាន់ ចងឲ្យទាល់តែជាប់ៗអ៊ីចេះទៅណ៎ា។ ក្មួយឯងក៏គេរឹតអ៊ីចឹងដែរ។ គេរឹតអ៊ីចឹង។ ដាក់ឲ្យកៀកៗគ្នាអ៊ីចឹង ច្រវាក់អ៊ីចឹងទៅ ចងមកណេះ ជាប់ៗអ៊ីចឹងទៅ ចងរឹតជាប់អ៊ីចឹងណ៎ា។ ជាប់ៗអ៊ីចឹង ហូតអាកន្សែងខ្សែទៅអ៊ីចេះទៅទៀត ទៅជាប់ៗ ក្មួយឯង--

សៈ ប៉ែសតែម្តង?

ឆ៖ ប៉ែសអ៊ីចឹង ជិតគ្នាអ៊ីចឹងដៃ។

សៈ ប្រហែលប៉ុន្មាននាក់?

ឆ៖ ខ្ញុំមើលទៅ (ឮមិនច្បាស់) ខ្ញុំប៉ាន់មើលទៅប្រហែល២០នាក់ទេ មួយខ្សែហ្នឹង។ អាហ្នឹងគ្រាន់តែជាប់ដៃទាំងអស់អ៊ីចឹងណ៎ា។

[១៥:២៧:០៤]

សៈ បាទ តើអ្នកចងប៉ុន្មាននាក់ (ឮមិនច្បាស់)?

ឆ៖ អានេះអ៊ីចឹងទៅ ហូតកន្សែងអានេះទៅ ចងភ្ជាប់អានេះទៅ។ ហូតកន្សែងអាហ្នឹងភ្ជាប់ ចងភ្ជាប់អានេះអ៊ីចេះទៅ--

សៈ ណោះដាក់ទៅណោះ ដែងណោះ។

ឆៈ អាណោះអ៊ីចឹងទៅ ទៅភ្ជាប់អាណោះអ៊ីចឹងដូចតែគ្នាអ៊ីចឹងទៅ។

------------

ឆៈ ច្រូតក៏មុជ ស្ទូងក៏មុជដែរឲ្យតែក្តៅ។ ខ្ញុំអត់ដែលផឹកទេ ខ្ញុំដែលតែមុជហ្នឹង។ ដឹងថាស្រះហ្នឹងមានខ្មោច គេដាក់ក្នុង គេសម្លាប់ចោលក្នុងហ្នឹងដែរ ប៉ុន្តែអត់ប៉ានផឹក។

------------

ឆៈ ដែលគេប្រាប់ទៅ ២ថ្ងៃគេប្រជុំប្រាប់ ថាយើងក្រោកពីងងឹតម៉ោងបួនជួបជុំគ្នា ឆាប់ក្រោកជួបជុំគ្នាឡើងឡានទៅវ៉ៃបន្ទាយពោធិ៍ជ្រៃអ៊ីចឹង គេថាអ៊ីចឹង។ ដល់ពេលម៉ោងបួនហ្នឹង នាំគ្នាដើប ដើបទៅជុំគ្នាទាំងអស់គេឲ្យឡើងឡាន។ ឡើងពីពោធិ៍សាត់ហ្នឹងមក ដល់បន្ទាយពោធិ៍ជ្រៃហ្នឹង វាភ្លឺស្រាងៗ--

------------

[១៥:២៩:១០]

ឆៈ កាលហ្នឹង តាប៉ុ ខ្លឹម គេឡើងប្រកាសមីក្រូ។ តាប៉ុ ខ្លឹម គេវរសេនាធំអង្គាល់ហ្នឹង។ គេឡើងលើប្រឡូសកូសគេដាក់មីក្រូនិយាយបណ្តោយហ្នឹង។ គេនិយាយប្រកាស យកទ័ពយកមកតម្រៀបមនុស្ស។ វាជាប់ទាំងយើងផង ទាំងតំបន់ផង ជាប់១៨ផង ១៩ផង ចូលចង់១.០០០នាក់ណ៎ះ មកការពារហ្នឹង។ ហើយពួកខ្ញុំហ្នឹង គេឲ្យរៀប ប្រជុំកងការពារ គេហៅពួកខ្ញុំ ពួកការពារ។ ពួកការពារហ្នឹង បើសិនជាមានការផ្ទោះផ្តោយរួច គេប្រាប់ត្រង់ គេថាបើសិនជាអ្នកកម្ទេចរួច យើងអ្នកការពារហ្នឹងធ្វើម៉េចកុំឲ្យរួច តែរួចគឺបែកការណ៍ ខូចផែនការរបស់យើងហ្នឹង។

សៈ ជិតហើយ?

ឆៈ ហ្នឹងហើយ។ ស្រាប់តែដល់ម៉ោងប្រាំពីរអីហ្នឹងឮសូរស្នូរឡានមក អាហ្នឹងឡានធំមកមុន មកដំបូងឡានធំ មក។ ឮសូរឡានធំហ្នឹងជិតៗមកអ៊ីចឹង គេប្រាប់ថា "កងពិសេសប្រុងប្រៀប"។

------------

[១៥:៣០:១២]

ឆៈ ថ្ងៃទី៣ ហ្នឹងត្រូវដឹកមនុស្សចេញទៅៗពោធិ៍ជ្រៃហើយ ប៉ុន្តែយើងដឹងស្ថានការណ៍ហើយថា យកទៅហ្នឹងមិនមែនយកទៅអីទេ ពីព្រោះយើងដឹងផែនការថាគេត្រូវកម្ទេចហើយ ព្រោះសុទ្ធតែអ្នកសំខាន់ៗ។ គេដឹងថា អ៊ូ! ឃ្លាតពីម៉ាដាមមួយយប់ពីរយប់ចុះយ៉ាងយូរ។ ក្រោយពីបានជួបសម្តេចឪហើយមកកាន់

ការងាររៀងៗខ្លួន។ អ៊ីចឹងគេនិយាយអ៊ីចឹង គេអត់មានព្រួយបារម្ភពីបញ្ហាថាយ៉ាងណាៗ អត់ទេ។ ហើយគេនិយាយលេងធម្មតា លលេងគ្នាគេហ្នឹងៗ ម៉ាដាមឯងបានស្អីដាក់មក? អ៊ីចេះមួយអ៊ីចុះពីរអ៊ីចឹងទៅ តែតឺនុយស៊ីវិលទេណា។ ចៅហ្វាយខេត្តតឺនុយ ស្លៀកសពាក់ស ពាក់មួកស្លឹកត្នោត ធ្វើអាវបៀបគេហៅថាសាមញ្ញ។ ចុះបើខ្មែរក្រហមស្លៀកខោរីត អាវខ្មៅៗ បង់កន្សែងៗនៅលើ-ក។ អ៊ីចឹងគេអាវបៀបកសិករដែរ។ គេស្លៀកខោអាវសាមញ្ញអ៊ីចឹងទៅ គេពាក់មួកស្លឹកត្នោតអ៊ីចឹងដែរទៅ។ លេងសើចធម្មតាទៅក្នុងឡានហ្នឹង បង្កើតបរិយាកាសដូចរីករាយ ដូចអត់មានអ្វីសម្រាប់គេហៅថា នៅពេលខាងមុខហ្នឹងវាមានវិបត្តិយ៉ាងម៉េចៗ អត់ដឹងខ្លួនទេ។

[១៥:៣១:២៨]

ចុះពីលើឡាន គេភ្លង់តែម្តង គេប្រកាស គ្រាន់តែឡានឈប់ដល់គេប្រកាស។ គេប្រកាសមីក្រូថា "ឲ្យសមមិត្តយើងកុំភិតកុំភ័យអី" ប្រាប់បណ្តាលទាហានហ្នឹងណ៎ះ! តែទៅជួបអង្គការៗយើងអត់ទុកចិត្តទេ ព្រោះអីយើងនៅជាប់សមាសភាពទៅជួបសម្តេច គេថាអ៊ីចឹង ទាល់តែចង។ ឡានមួយចងអស់បណ្តើរទៅ ចងអស់មួយបានបណ្តើរទៅៗ។

ចុះៗ បើយើងដាក់ស្តែងអ៊ីចឹងថាវាលេងអ៊ីចឹង ដូចថាផ្លូង អ៊ីចឹងទៅមួយ ផ្លូងៗៗ ព្រួសៗ។ ហើយបើខួរក្បាលមនុស្សដូចថា ផ្លូងៗនុំងទៅ បាចឆាវ អាឈាម ហើយនិងខួរ សហើយក្រហមហ្នឹងមើលទៅថា --

វាមិនបាញ់ពាសវាល អ៊ីចឹងអាពួកឡានមកឃើញហើយ ដល់ចូលក្នុងស្រះហ្នឹងមើលអត់ឃើញដីវាជ្រៅប្អូនឯងទៅឃើញហើយ។ ចូលទៅអ៊ីចឹងទៅ អាឡាននៅឯណោះមើលអត់ឃើញទេ។ តែដល់លើទួលហ្នឹង ដល់ៗមត់ទួលហ្នឹងបានមើលឃើញខ្មោចបណ្តោយ។ ដើរលើទួលហ្នឹងមើលទៅឃើញខ្មោចនៅរណ្តៅហ្នឹង បានវាស្រែកយំ បានទទន់ដៃទន់ជើងហ្នឹង។ អាហ្នឹងវាអ៊ីចឹងពួកហ្នឹង។ មានអាខ្លះវាៗជេរទៀតណ៎ា អាទមិឡអត់សាសនា អាតិរច្ឆាន អាអីអ៊ីចឹង។ អាណាវានៅចាំស្មារតី គ្រាន់តែវាជិតឃើញខ្មោច គ្រាន់តែឃើញខ្មោចវាជេរតែម្តង ប៉ុន្តែអាខ្លះអត់ទេ អត់មាននិយាយអីកើត ដើរក៏អត់រួច។ គេវៃ គេទាត់អីទៅ បានទៅដល់កន្លែងហ្នឹង។

[១៥:៣៣:០៥]

ដល់តែជិះឡានតូចហើយដល់ឃើញគាត់ចេញមកៗ ខ្ញុំអើតកមក ខ្ញុំថា "ធឿន នោះដូចអ៊ំគ្នាតើ" ហើយមី ធឿន គេថា "ឯណា?" ថា "នោះ! អ៊ំខ្ពស់មួយនោះ អ៊ំមួយគាត់ខ្ពស់ អ៊ំនោះ នុត តើ?" អ៊ីចឹងខ្ញុំ

ដើរទៅប្រហែលប៉ុណ្ណឹងជម្រុកហ្នឹង ខ្ញុំដើរទៅអើតមើល ហើយឃើញប្អូនខ្ញុំស្រីមីសំណាងនោះមួយ កូនគាត់ហ្នឹងណ៎ះ! បាន អូ! អ៊ំបានដឹងអ៊ំ។ ខ្ញុំគេចមកវិញវឹង មិនប៊ានឲ្យគាត់ឃើញទេ វ៉ៗគាត់ស្រែកថា ក្មួយជួយអ៊ំផងហ្នឹង កុនទាំងខ្ញុំទៀតហើយ។ អ៊ីចឹងអ្ន៎ា ខ្ញុំសុខចិត្តគេចៗដើរចេញបណ្តោយ ដើរចេញពីមុខគាត់ហ្នឹងងាកមកហ្នឹង ដល់តែហើយទៅ ចងទាំងឪទាំងកូនហ្នឹងទៅសម្លាប់ទៅ។

ដល់តែមកទៀតដូចនឹកឃើញដូចជានៅថ្មីកន្លែងសម្លាប់មនុស្សដូចនៅថ្មីៗ។ លាក់ការណ៍ថាសម្លាប់តែក្នុងស្រះហ្នឹងទាំងអស់ ប៉ុន្តែដល់រកកន្លែង ដាក់មិនបានៗ បានដាក់មកក្រោយវាច្រើនពេកក្នុងស្រះហ្នឹងវាច្រើនពេកដាក់វាពេញ។ គេបាញ់ ខ្ញុំឈរហ្នឹង មុនដំបូងគេបាញ់អ៊ីចេះ ប៉ុន្តែទាហានដាក់មុខទៅនោះ ឲ្យលុតជង្គង់បែរមុខទៅនោះ អាខ្លះក៏បែកក្បាល អាខ្លះក៏រយះរយាយ ចុះគ្រាប់ៗកាំភ្លើងយើងពិបាកមើលណាស់ ហើយគ្រាន់តែឈរអ៊ីចឹង ឆ្អាបនៅឈរអត់បានយូរទេ ឈរមើលអត់បានយូរទេ ទាល់តែដើរទៅខាងណោះអ៊ីចេះ ទៅនៅពីលើខ្យល់គ្រាន់ណ៎ះ បើថានៅជិតអ៊ីចឹងទៅឆ្អាបនៅអត់បានទេ។

[១៥:៣៥:០៧]

សះ បង(ឮមិនច្បាស់)

ឆះ ខ្ញុំអ្ន៎! ដល់ពេលថ្ងៃល្ងាចអ្ន៎!

សះ នេះ(ឮមិនច្បាស់) ?

ឆះ អ្ន៎! កាលពីព្រឹក? បាទ កាលពីព្រឹក សាកសពមានតែៗក្នុងស្រះ និងពីលិចស្រះទេ ដល់ពេញស្រះវាដាក់ពីខាងលិច។ ដល់ថ្ងៃល្ងាចខ្ញុំដើរមក ដល់ថ្ងៃចាប់ពីម៉ោងបួនខ្ញុំដើរវិញ វារំសាយហើយរំសាយកន្លែងខ្សែត្រៀម។ ដល់ដើរមក តាមហ្នឹងសុទ្ធតែសាកសពហើយ ពីកើត ពីត្បូង ពីជើងអីសុទ្ធតែសាកសពជុំវិញទាំងអស់ ហើយខ្ញុំដើរក្បែរចុងខាងត្បូងណោះ អែបរបងណោះ ក្បែររបងណោះ។ អាតាមនេះដើរមិនរួចទេ សុទ្ធតែសាកសព ម្ល៉ោះហើយដើរអែបរបងណោះ ទៅកន្លែងប្រឡូកកូស ឡើងកន្លែងឡានណោះ ទៅជុំគ្នានៅកន្លែងឡាន។

សះ អ៊ីចឹងបងឯងចង់មកនេះដែរ តែសាកសពពេញ?

ឆះ សាកសពពេញដើរអត់រួចទេ។ ពិបាកដើរនឹងសាកសព ម្ល៉ោះហើយដើរទៅឯណោះ ទៅឡើងទៅជុំគ្នាឯណោះ។ សួរកងពិសេស សួរអាទ្រី អាទ្រីគេអ្នកបាញ់ហ្នឹង គេពួកទាហានដែលគេយកមកកម្ទេចហ្នឹងប៉ុន្មាន? ថា ខ្ទង់ជិត ១០.០០០នាក់ ដែរហ្នឹងណ៎ះ។

[១៥:៣៦:០៨]

សះ ចុះបងដែលៗខ្មោចដែលមកមើលឃើញស្លាប់នៅហ្នឹង ចំនួនប្រហែលប៉ុន្មានតាមបងមើលឃើញស្ថានភាពនៅហ្នឹងបាទ នេះតាមបង?

ឆះ ច្រើន មើលទៅវាច្រើន មនុស្សច្រើនពេញវាលអ៊ីចឹងមិនដឹងប៉ុន្មាន។ ប៉ុន្តែបើតាមគេនិយាយ សួរដែលអ្នកធ្វើហ្នឹងណា៎ះ ខ្ញុំសួរអ្នកគេធ្វើឃាតហ្នឹង ដូច អាបុល អីគេចាត់តាំងឲ្យធ្វើកងពិសេសកងអីហ្នឹងណា៎ះ ខ្ញុំសួរប្រហែលប៉ុន្មាន បុល ខ្លាំង ខ្ញុំនិយាយអ៊ីចឹង? ខ្ញុំថាប្រហែលប៉ុន្មានទៅ បុល? បុល ថា អ្ហឺ! បើខ្វះពី ១០.០០០ ក៏ខ្វះ ១.០០០ ដែរ។ គេនិយាយអ៊ីចឹង។ ខ្វះពី ១០.០០០ ខ្វះ ១.០០០អីហ្នឹង។

សះ សូមមានប្រសាសន៍ឲ្យឮបន្តិច ដែលតាមបងសួរអ្នកណា? សួរយ៉ាងម៉េចបាទ? ក្រោយពីបាញ់ហើយហ្នឹង?

ឆ ៖ មិនសួរពេលកន្លែងបាញ់ទេ ដល់ពេលយើងមកសម្រាកពេលហូបបាយថ្ងៃល្ងាច មកឡានគេដឹកមកដល់ខេត្តវិញហើយ។ ខ្ញុំសួរ អេ៎ បុល! ប្រហែលជាប៉ុន្មានមើលដូចក្រាលពេញវាលទាំងអស់អ៊ីចឹង? ខ្ញុំនៅក្រៅមិនដឹង វាថាប្រហែលជា -- វាថា តាមវាធ្វើបើគិតទៅប្រហែលជាថាធន់តូចប្រហែលត្រឹមពី ៨.០០០ វាថាក្រោមពី ១០.០០០ យ៉ាងច្រើន ១.០០០ វានិយាយអ៊ីចេះ។

----------

[១៥:៣៧:៣២]

ឆះ អ៊ីចឹងពេលនុ៎ងម្នាក់ៗទាហានស្មោះហ្នឹងចង់ទៅជួបសម្ដេចឪហ្នឹងដើម្បី ប្រវ៉ីយ៉ាលក្រឡុង ឃើញទេ! ចង់បានឋានន្តរស័ក្តិ អ៊ីចឹងអត់មានបណ្តាលស័ក្តិក៏ចេញទៅដែរ។ អ៊ីចឹងបានខ្ញុំចង់និយាយថា ស្លាប់ច្រើនអីច្រើនហ្នឹងគឺមូលហេតុអ៊ីចឹង អាខ្លះហ្នឹងអត់ទាហានសុទ្ធសាធផងទេ តែទិញស័ក្តិ ហើយស័ក្តិនឹងផ្សារខ្វះអីអាកាច់ជ្រុងផ្លូវមាត់ស្ទឹងពោធិ៍សាត់ហ្នឹង។ អាផ្លូវកាច់ជ្រុងចូលផ្សារអ៊ីចេះ នៅខាងណោះ លក់ស័ក្តិមួយជួរនុ៎ងទាំងអស់។ ពេលកំពុងតែ បញ្ហាហ្នឹងក៏នូវលក់ស័ក្តិនៅឡើយទេ។ ដល់ថ្ងៃទី៣ បានៗគេបាចលុយចោលពេញហ្នឹងទៅ គេមិនចាយលុយចាយអីទៅបានដឹងខ្លួនលែងលក់លែងអី។

----------

[១៥:៣៨:២៨]

ឆះ ខ្ញុំមកហ្នឹងដែលគេសម្លាប់រួចហើយ គេធ្វើសម្លាប់ទាហានហ្នឹងណា៎ះ! បាទ គេសម្លាប់រួចហើយ ខ្ញុំមកហ្នឹងឃើញ ដូចគេក្រាលកៅស៊ូអ៊ីចឹងណា៎ះ ពោះហើមប៉ោងអ៊ីចឹងទៅ(ឮមិនច្បាស់)។

សះ ពីដំបូងគេប្រាប់យ៉ាងម៉េច គេយើងមកធ្វើស្អី?

ឆ៖ គេថាឲ្យមករើផ្ទះ គេឲ្យមករើផ្ទះហ្នឹងណ៎ះ ផ្ទះកុម៉ង់ដូ គេឲ្យរើយកទៅវិញទាំងអស់បាទ គេឲ្យរើយកទៅវិញ។ រើយកទៅធ្វើផ្ទះអីណោះវិញទៅក៏នាំគ្នារើទៅ អាខ្មោចហ្នឹងនៅតែខ្មោចទៅ ឡានពួកវាមកឈូសកប់ទៅ។

សៈ ហើយមកដល់ដំបូងឃើញយ៉ាងម៉េច មើលទិដ្ឋភាពរៀបរាប់មើលបាទ? អត់ទេនិយាយមក១។

ឆ៖ ឃើញខ្មោចហ្នឹងណ៎ះ ឃើញខ្មោច ឃើញគេពោះវៀនអីចឹង វានៅហ្នឹងទៅ គេកាត់ក្បាលកាត់អីហ្នឹង ទៅ (ឮមិនច្បាស់)។

សៈ ឬមួយគេកាត់ដាក់ត្រង់ណា មើល៍បងរៀបរាប់ពីសកម្មភាព?

ឆ៖ នុះ១១ កាប់អានោះមួយអានោះមួយ នៅតាមមាត់ទ្វាររបង គេហ្នឹង។ កាត់ដាក់ផ្ទះខាងណេះមួយខាងត្បូងមួយ ខាងជើងមួយ។

សៈ ឈ្មោះអី? ហើយគេដកដាក់យ៉ាងម៉េចមើលបងបញ្ជាក់១មើល?

ឆ៖ ឈ្មោះលោក ប៉ែល, លោក រុន នៅពីរនាក់។

សៈ លោក ប៉ែល នៅខាងណា? លោក រុន នៅខាងណា?

ឆ៖ លោក រុន នៅខាងជើង។ លោក ប៉ែល នៅខាងត្បូង គេហាមមិនឲ្យចូល។ ដំណើរគេហ្នឹង បែបគេអត់ឲ្យចូល។

[១៥:៤០:០៤]

សៈ យ៉ាងម៉េច បងជួយធ្វើសម្ដែងឲ្យមើល!

ឆ៖ ដោតបង្គោល អាបង្គោលយើងសម្រួចទៅ គេដោតបញ្ចូលតាមស្បូវរង បំពង់កហ្នឹង ផ្កុក អំមិញបែរមុខទៅត្បូង។

សៈ ហើយបង ខ្មោច តារ៉ុន ដែលបងឯងឃើញហ្នឹងមុខហ្នឹង បងឯងឈរចម្ងាយណាដែលមើលហ្នឹង?

ឆ៖ ខ្ញុំទៅកាន់លេងនោះណា ទៅបង្វិលរបងលេខហ្នឹងណា អាដំបងគេដោតហ្នឹងណា--

សៈ បងឯងធ្វើមើល?

ឆ៖ ចម្រឹងរបងណ៎ា--

សៈ គេដាក់ក្បាលយ៉ាងម៉េច ហើយបងឯង (ឮមិនច្បាស់) បងឯងធ្វើមើល៍!

ឆ៖ គេដាក់ ខ្ញុំអង្រួនអាក្បាលខ្មោចហ្នឹង វានៅតែប្ដើក ចេះតែអង្រួនលេង ខោអាវគាត់អីហ្នឹង ឃើញគេកាត់-កគាត់ ចំណាំសាក់ទ្រូងគាត់ទៅ ដូចលោក តិល អីចឹងងាប់នៅត្រង់ណេះអីចឹងទៅ គេយកទៅ

ដោតក្បាលឯណោះអ៊ីចឹងទៅ មានតែស្អី។

សៈ ហើយកាលហ្នឹងបងឯងអាយុប្រហែលប៉ុន -- អាយុប៉ុន្មានកាលណោះៗ?

ឆៈ ខ្ញុំវានៅក្មេងតូចដែរហ្នឹង តូចៗដែរ ប្រហែលប៉ុនពួកមីតូចៗនេះ ប៉ុន្តែខ្ញុំវាម៉ាប់ជាង។

សៈ អាយុប៉ុន្មាន ដប់ មួយដណ្តប់ឆ្នាំអីទេ?

ឆៈ មួយដណ្តប់ ពីរដណ្តប់ឆ្នាំហ្នឹងអស់ហើយ។

[១៥:៤១:២១]

សៈ បងឃើញសាកសព មើលឃើញមានស្រីអីយ៉ាងម៉េច? ហើយសាកសពដេកនៅយ៉ាងម៉េចរដូករណែលម៉េច?

ឆៈ អត់ទេ ស្រីមានតែបីនាក់ទេ មកពោធិ៍ជ្រៃនោះ។ ឃើញស្លាប់ ខ្ញុំឃើញផ្ទាល់នេះ នៅត្រង់នេះ ស្លាប់នៅនេះ កប់នោះ កន្លែងកូនចារនោះ។ មានតែបីនាក់ទេ ស្រី។

សៈ (ឮមិនច្បាស់)

ឆៈ ស្រាត គ្មានសល់អស់។ ដំណើររួមភេទត្រង់ហ្នឹងហើយ ម្តប់ល្អណាស់។"

*(បញ្ចប់ការបង្ហាញឯកសារជាវីដេអូ)*

[១៥:៤១:៥៨]

**លោក ឃីត រេយ៉ន័រៈ**

សូមអរគុណលោកប្រធាន នេះបញ្ចប់ខ្សែវីដេអូពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃ។ នៅពេលនេះគឺខ្ញុំសូមឲ្យ -- សូមបង្ហាញឯកសារពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរទីលំនៅដំណាក់កាលទី២។

ឯកសារដំបូងគឺឯកសារ E3/216 ខ្មែរមានលេខ 00008485, អង់គ្លេសគឺមាន 00858973។ នេះគឺជារបាយការណ៍កំណត់ហេតុរបស់ទស្សនកិច្ចអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ នៅថ្ងៃទី២០ ដល់២៤ ខែសីហា ឆ្នាំ៧៥។ ចំណងជើងសរសេរថា "សេចក្តីរាយការណ៍អំពីសភាពការណ៍រួមនៅមូលដ្ឋាន ១) សភាពការណ៍ប្រជាជន"។ ការដកស្រង់ចំណុចនៅក្នុងនេះមានដូចតទៅ "ប្រជាជនថ្មីមានការខ្វះខាត ខ្វះស្បៀងផង ខ្វះថ្នាំសង្កូវផង"។

នៅក្នុងឯកសារដដែលខ្មែរ ERN មានលេខ 00008487, បារាំងមានលេខ 00343375, អង់គ្លេសមានលេខ 00800974។ ចំណងជើង "សភាពការណ៍សេដ្ឋកិច្ចបង្កបង្កើនផលកសិកម្ម ដំណាំស្រូវបានជំរុញនៅគ្រប់កន្លែង"។ ដីចាស់បានធ្វើទាំងអស់ កន្លែងខ្លះថែមដីទៀត។ កន្លែងភាគច្រើន នៅ

បាត់ដំបងធ្វើរួចហើយ ស្រែពង្រោះ ស្រូវសន្ទូង។ ស្រែជាច្រើនមានប្រឡាយ និងលើកភ្លឺជាកង់ៗ។ បញ្ហាទឹកម្ចាស់ការបានមួយកម្រិត"។

[១៥:៤៤:៤១]

ឯកសារដដែល ខ្មែរ ERN 00008488 រហូតទៅដល់ 89, បារាំងមានលេខ 00343376, អង់គ្លេស 00850975 ចំណងគឺថា "កិច្ចដំណើរការការពារប្រទេស", ចំណងជើងមួយទៀតគឺថា "បញ្ហាគន្លឹះ គឺដោយស្រាយស្ថានភាពប្រជាជន"។ ការដកស្រង់គឺមានដូចតទៅ "បញ្ហាសំខាន់ជាក់ស្តែង គឺត្រូវពង្រឹងពង្រីកសហករណ៍ យកកម្លាំងសហករណ៍ធ្វើជាស្នូល ធ្វើឲ្យស្នូលនេះរឹងៗ សម្រាប់ស្រូបប្រជាជនថ្មី"។

មួយទៀតគឺត្រង់ខ្មែរលេខ 00008489 ឯកសារនេះសរសេរថា "សហករណ៍ត្រូវបានបង្កើតដំណើរការរួចមកហើយ។ ២) តួនាទីរបស់សហករណ៍តាំងពីរំដោះទាំងស្រុកមក គឺដើម្បីប្រមូលកម្លាំងប្រជាជនថ្មី ដែលមកពីក្រុង ទីប្រជុំជននានា ជាពិសេសក្រុងភ្នំពេញ ហើយនៅពាយ័ព្យ គឺបាត់ដំបង។ ប្រជាជនថ្មីរាប់សែននាក់នៅបាត់ដំបងមានសមាសភាពអាក្រក់គ្រប់យ៉ាង តែសហករណ៍ស្រូបយកអស់ផ្គត់ផ្គង់ស្បៀង ព្រមទាំងចាត់ចែងកម្លាំងធ្វើការងារទៀត"។ ហើយកថាខណ្ឌមួយទៀត នៅក្នុងប្រអប់ដដែលសរសេរថា "ដូច្នេះត្រូវពង្រឹងពង្រីកសហករណ៍ថែមទៀត"។

ការដកស្រង់មួយទៀតគឺខ្មែរលេខ ERN 00008490, បារាំង 00343377 ដល់ 78, អង់គ្លេស 00850976 ដែលនិយាយអំពីភូមិភាគពាយ័ព្យថាត្រូវដោះស្រាយយ៉ាងម៉េច។ "ឥឡូវនៅជាប់ជើងបន្តិច តែឧបសគ្គនេះជាឧបសគ្គឆ្លងកាត់ទេ ប្រជាជនគេមានសង្ឃឹម។ នៅពាយ័ព្យលក្ខណៈភូមិសាស្ត្រ អំណោយ គេឃើញច្បាស់។ ប្រជាជនចាស់គេរីករាយណាស់ ឯប្រជាជនថ្មីក៏រីករាយ។ មិនដូចជានៅ ៤០៤ ទេ នៅកន្លែងនោះគេសង្ឃឹមតិច ដីតិច ទឹកតិច ស្រូវមិនល្អ។ នៅឯពាយ័ព្យគេសង្ឃឹមច្រើន គេឃើញលទ្ធភាពគេផ្តល់ឲ្យ -- ដែលផ្តល់ឲ្យគេ គេពេញចិត្តពេញថ្លើម។ ១ឆ្នាំ ២ឆ្នាំទៅទៀត ជីវភាពនឹងឡើង សហករណ៍ប្លែក ស្រែប្រែប្រួល ទឹកប្រែប្រួល ស្បៀងសម្បូរសប្បាយ ហើយកាន់តែឡើងខ្ពស់ទៅទៀត"។

[១៥:៤៩:៣០]

នៅក្នុងឯកសារដដែល ខ្មែរ ERN លេខ 00008491 រហូតទៅដល់ 92, បារាំងមានលេខ 00343378 ដល់ 79, អង់គ្លេសមានលេខ 00850977។ ក្រោមចំណងជើង អត្ថបទនេះសរសេរថា

"បញ្ហាសេដ្ឋកិច្ចបង្កបង្កើនផល៖ ទិសរបស់បក្សគឺបង្ករបង្កើនផល និងកសាងប្រទេស។ ត្រូវចែកកម្លាំងដែលមានដីទំនេរឲ្យបង្កបង្កើនផលផង ការពារប្រទេសផង។ ម្យ៉ាងទៀតត្រូវប្រមូលកម្លាំងទៅកន្លែងណាដែលមានលទ្ធភាពជាងគេ គឺដូច្នេះហើយឧត្តរ និងពាយ័ព្យ ពិសេសពាយ័ព្យដែលមានលក្ខណៈសម្បត្តិល្អច្រើនជាងគេខាងភូមិសាស្ត្រដីស្រែល្អហើយសល់ច្រើន។ ត្រូវទទួលប្រជាជនថែមទៀត។ ទី២ មានទុនជាស្រូវអាចចិញ្ចឹមប្រជាជនថ្មី។ ទី៣ មានទុនជាឧបករណ៍ផ្សេងៗ។ យើងវាយសម្រុកបង្កបង្កើនផលនៅពាយ័ព្យដើម្បី៖ ទី១ ដោះស្រាយជីវភាពប្រជាជនទូទាំងប្រទេស។ ទី២ រកទុនថ្មីទិញឧបករណ៍កសាងប្រទេស និងបង្កបង្កើនផលកសិកម្ម និងឧស្សាហកម្ម។ បើយកកម្លាំងទៅកន្លែងផ្សេងដែលមានលទ្ធភាពតិចនោះយើងខាតទាំងប៊ី ទាំងស្គរ មាគ៌ាប្រយុទ្ធរបស់យើងមិនត្រូវ ដូច្នេះត្រូវប្រយុទ្ធត្រង់ណាដែលមានប្រសិទ្ធភាព ព្រោះយើងអនុវត្តនយោបាយខ្លួនឧបត្ថម្ភខ្លួន យើងត្រូវទុនដោយខ្លួនយើង"។

[១៥:៥២:៤៦]

ហើយក្រោយមកនៅក្នុងចំណុចដែលសរសេរថា "ការរៀបចំកម្លាំងមនុស្ស៖ ភូមិភាគពាយ័ព្យមានស្ថានភាពគួរឲ្យមានប្រយោជន៍ និងមិនមានប្រយោជន៍ ជាទូទៅដីមានជីវជាតិ ហើយក៏ល្អដែរ ទោះបីជាមិនប្រើជីក៏ដោយ។ ទ២ កន្លែងនោះ គឺមានដីវាលៗទំនាបមិនមានភ្នំ ងាយស្រួលឲ្យយើងចាត់ចែងកម្លាំងភ្ជួររាស់ និងងប្រើប្រាស់ទឹក។ មានកម្លាំងមនុស្សដែរ យើងបន្ថែមទៀតរឹតតែល្អ។ កម្លាំងនេះក៏មានបទពិសោធន៍បង្កបង្កើនផល"។

ហើយចំណុចចុងក្រោយគេសរសេរថា "មានឧបករណ៍ម៉ាស៊ីនខ្លះ ចំណុចខ្វះខាតត្រូវចាប់អារម្មណ៍" ត្រង់ទំព័រខ្មែរ 00008492, បារាំងមានលេខ 00343379,អង់គ្លេសមានលេខ 00850978។ "ចំណុចខ្វះខាត ឬត្រូវចាប់អារម្មណ៍៖ ទី១ មិនទាន់ម្ចាស់ការលើទឹក, ទី២ កម្លាំងមនុស្សមិនគ្រប់ត្រូវបន្ថែមកម្លាំងពលកម្ម ៣00.000 ឬ៤00.000 ទៀតក៏មិនគ្រប់។ កម្លាំង១លាននាក់បច្ចុប្បន្នធ្វើមិនបាន ៥0ភាគរយទេ ត្រូវថែម ៤00.000 ឬ៥00.000ទៀត។

[១៥:៥៤:៥៩]

ឯកសារបន្ទាប់មួយទៀត ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ គឺឯកសារ E3/781 ការដកស្រង់ដំបូងនៅក្នុងខ្មែរ ERN 00072367, បារាំងមានលេខ 00543745 និងអង់គ្លេសមានលេខ 00523569 នេះគឺជាឯកសារបក្សកុម្មុយនីស្តកម្ពុជា ចុះខែកញ្ញា ឆ្នាំ៧៥។ ឯកសារទី៣ចំណងជើងឯកសារនេះសរសេរថា "ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយ ស្តារសេដ្ឋកិច្ច និង

រៀបចំកសាងប្រទេសគ្រប់ផ្នែក"។ ក្រោមចំណងជើង "ការក្តាប់ និងអនុវត្តមាគ៌ានយោបាយកសាងកសិកម្មរបស់បក្ស"។ គោលបំណងត្រូវបានសរសេរឡើងនៅក្នុងន័យដូចតទៅនេះថា "ពិនិត្យមើលការក្តាប់ ការជ្រួតជ្រាប និងការអនុវត្តនូវមាគ៌ាកសិកម្មរបស់បក្ស ដើម្បីជំរុញកសិកម្មនេះ ឲ្យបានចម្រើនលោតផ្លោះជាអតិបរិមាតាមទិសណែនាំរបស់បក្ស"។

[១៥:៥៧:០២]

ប្រអប់ពណ៌ក្រហមបន្ទាប់ទៀតសរសេរថា "យើងត្រូវតែត្រៀមខ្លួនឲ្យបានលឿនដើម្បីផ្លាស់ប្តូរពីកសិកម្មដើរថយក្រោយទៅជាកសិកម្មទំនើបក្នុងរយៈពេល១០ ទៅ ១៥ឆ្នាំ នេះជាសំណូមពរ"។ បើមើលពេលវេលានេះ យើងឃើញវារហ័សណាស់។ ខ្មែរ ERN មួយទៀតគឺ 00072368, បារាំងមានលេខ 00543745, អង់គ្លេសមានលេខ 00073570។ សំណូមពរលើកឡើងនេះ មានកម្រិតខ្ពស់ណាស់ យើងត្រូវធ្វើប្រញាប់ប្រញាល់មែនទែន ដើម្បីសម្រេចសំណូមពរនេះ។ បញ្ហានេះទាមទារកម្លាំងគ្រប់ផ្នែកឲ្យដើរជាខ្សែសង្វាក់មែនទែន ម៉ាស៊ីន ជី ទឹក ។ល។"

ហើយនៅក្នុងទំព័រនេះដដែលខាងក្រោមបន្តិច អត្ថបទនេះសរសេរដូច្នេះថា "បន្ថែមពីនេះយើងមានសហករណ៍ដែលជាទ្រព្យកម្មសិទ្ធិសមូហភាព ងាយស្រួលឲ្យយើងចាត់ចែងអ្វីៗបានទាំងអស់ យើងសព្វថ្ងៃមានកម្មសិទ្ធិសហករណ៍ប្រជាជននិងកម្មសិទ្ធិរបស់រដ្ឋប៉ុណ្ណោះ"។

មួយទៀតខ្មែរ ERN 00072369 ហើយទំព័រអង់គ្លេស និងបារាំងគឺបន្ទាប់ពីទំព័រអម្បាញ់មិញមួយទំព័រ។ "តាមពិសោធន៍ចិនគេចាត់តាំងសហករណ៍កម្រិតខ្ពស់នៅឆ្នាំ១៩៥១ ដល់ ឆ្នាំ១៩៥៨ គេចាត់តាំងសហគមន៍បន្តទៀត។ ចិនរំដោះបាន១ (ចំនួនឆ្នាំនេះគឺថាគេសរសេរតែមើលអត់ឃើញ) ហើយមិនទាន់មានការរៀបចំភ្លឺស្រែទេ ឯងយើងមានសហករណ៍ស្រេចមកហើយ"។

[១៥:៥៩:២៤]

ខ្មែរទំព័រ 00072370, បារាំងមានលេខ 00543747, អង់គ្លេសមានលេខ 00523571 មានសរសេរដូច្នេះតទៅទៀតថាក្រោមចំណងជើង "ចលនាលរបស់មហាជនក្នុងការអនុវត្តនូវមាគ៌ាកសិកម្មរបស់បក្សក្នុងរយៈពេល៤ ទៅ ៥ខែកន្លងមកនេះ ខែ៥ ៧៥។ តើយើងបានជ្រួតជ្រាបយ៉ាងម៉េច តើបក្សត្រូវជំរុញយ៉ាងម៉េចបន្តទៀត ក្រោយពីបក្សផ្សាយមាគ៌ានេះលេចចេញជាចលនាពីរ។ ចលនាផុសផុលខ្លាំងជាងមុនរដ្ឋប្រហារ។ បក្សហើយប្រជាជនយើងខិតខំអនុវត្តមាគ៌ានេះណាស់ ក្នុងសភាពការណ៍ដែលមានការខ្វះខាតខាងជីវភាពសព្វគ្រប់ ក្នុងនេះខ្វះទាំងសម្ភារៈបង្កបង្កើនផល គោក្របី ចប ។ល។

ចលនាផុសផុលនេះ នាំឲ្យយើងឃើញថា ឆ្នាំក្រោយយើងនឹងដោះស្រាយជីវភាពប្រជាជនបាន។ ឆ្នាំនេះយើងបាន យើងធ្វើបានច្រើន ហើយល្អទៀតផង។ ឧទាហរណ៍ មានកន្លែងខ្លះប្រមូលកម្លាំងប្រជាជនបានផុសផុលសម្រុកបង្កបង្កើនផលយ៉ាងសកម្មទាំងយប់ទាំងថ្ងៃ។ ដូច្នេះប្រជាជនថ្មីទាំងអស់ ទាំងចាស់ទាំងថ្មី ធ្វើយ៉ាងរឹងមាំ យ៉ាងរឹងប៉ឹងដោយគ្មានស្ទាក់ស្ទើរ។ ហើយមានឧទាហរណ៍លើកឡើងថា កន្លែងខ្លះគេរៀបចំសម្រាប់បង្កបង្កើនផលក្នុងវិធីថ្មី មានធ្វើភ្លឺសម័យសម្រាប់ថែរក្សាទឹក ចិញ្ចឹមទឹក បើធ្វើយ៉ាងនេះយើងដោះស្រាយទឹកបាន៥០ភាគរយ។

[១៦:០១:៥១]

លោកប្រធាន ខ្ញុំមើលឃើញថានៅពេលនេះ ដូចជាដល់ពេលវេលាហើយ។ ប្រសិនបើខ្ញុំបញ្ចប់ទាំងអស់នោះ គឺខ្ញុំគិតថានឹងត្រូវការពេលវេលាប្រហែលជាច្រើនដែរ។ ប្រហែលខ្ញុំសល់ឯកសារនៅក្នុងនេះប្រហែលប្រាំបីទំព័រ ត្រូវបង្ហាញ ហើយនិងខ្សែវីដេអូដែលត្រូវចាក់បញ្ចាំងផងដែរ។ ដោយហេតុថាពិនិត្យទៅឃើញពេលវេលាវាដូចជាដល់ហើយ ហើយប្រហែលជាលោកប្រធានអាចទំនងជាចង់ផ្អាកសវនាការត្រឹមថ្ងៃនេះ ឬក៏ទុកឲ្យខ្ញុំបន្តទៀត?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទពេលវេលាកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក។ ហើយនៅថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងបន្តការផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តនូវការដាក់បង្ហាញឯកសារពាក់ព័ន្ធនឹងអង្គហេតុនៃការបម្លាស់ទីប្រជាជនដំណាក់ទី២ បញ្ចប់។ ហើយបន្ទាប់មក អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសដាក់បង្ហាញបំពេញបន្ថែម ឬបង្ហាញឯកសារលើប្រធានបទដែលខ្លួនចង់លើកឡើងនៅលើប្រធានបទទាំងបួន ដែលសហព្រះរាជអាជ្ញាបានធ្វើការបង្ហាញរួចហើយនេះ។ ហើយនិងចុងក្រោយអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការធ្វើអត្ថាធិប្បាយ ឬក៏ជំទាស់ចំពោះបណ្តាលឯកសារទាំងឡាយដែលតំណាងសហព្រះរាជអាជ្ញា ឬសហមេធាវីនាំមុខតំណាងដើមបណ្តឹងដាក់បង្ហាញ ពាក់ព័ន្ធនឹងឯកសារនៃអង្គហេតុទាំងឡាយដែលបានដាក់បង្ហាញកន្លងមកនេះ។

សូមអញ្ជើញលោកមេធាវី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ជាការពិតស្អែកយើងខ្ញុំមានឯកសារសម្រាប់បង្ហាញនៅថ្ងៃស្អែកនេះ។ តែទន្ទឹមនឹងនេះ យើងខ្ញុំចង់សូមមានការបញ្ជាក់អំពីអង្គសវនាការ អំពីលទ្ធភាពនៅក្នុងការបង្ហាញនៅពេលខាងក្រោយទៀត។ ដោយសារថាសវនាការលើការបង្ហាញឯកសារនេះត្រូវបានគ្រោងសម្រាប់ខែកុម្ភៈទេ ហើយត្រូវបានលើកមកខែមករានេះ។ ដូច្នេះអាចមានឯកសារមួយចំនួនដែលមិនត្រូវបានរៀបចំរួចស្រេចបាច់សម្រាប់បង្ហាញសម្រាប់សប្តាហ៍នេះទេ។ ដូច្នេះខ្ញុំបាទចង់សូមសួរថា តើក្រោយពីពេលនេះទៅ អាចមានលទ្ធភាពនៅក្នុងការបង្ហាញឯកសារនៅពេលក្រោយៗដែរឬទេ? សូមអរគុណលោកប្រធាន។

[១៦:០៤:៤២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៧:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះឆ្លើយតបទៅនឹងការសំណួរ ដែលសួរអម្បាញ់មិញនេះដោយមេធាវីជាតិ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះបញ្ហាការដាក់បង្ហាញឯកសារដែលមានការបត់បែន ហើយភាគីដទៃទៀតឃើញថា គេបានរៀបចំបានល្អ ហើយនិងបានច្រើនជាអតិបរមា។ ជាកស្តែងគឺសហព្រះរាជអាជ្ញាជាឧទាហរណ៍ជាក់ច្បាស់ហើយ។ អ៊ីចឹងទេអង្គជំនុំជម្រះនឹងផ្តល់លទ្ធភាពនៅថ្ងៃស្អែក ឲ្យខាងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឹងប្រែងឲ្យអស់លទ្ធភាព តាមតែអាចធ្វើទៅបាន។ ដោយឡែកបញ្ហាផ្សេងទៀត ដែលនៅសេសសល់ក្នុងករណីធ្វើមិនបាន ឬក៏ភាពចាំបាច់យ៉ាងណានោះ អង្គជំនុំជម្រះនឹងពិចារណាសម្រេចនៅពេលក្រោយ។

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានពីចម្ងាយឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៨ នាទី)*